**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Universitié Royal de droit et des sciences Economoiques**

**Royal University of Law and Economic**

# សារណាបញ្ចប់ការសិក្សា

# ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយនិស្សិត៖

១.កោះ ច័ន្ទឫទ្ធិសក្តិ

២.លាង លីឌឺរ

សាស្ត្រាចារ្យណែនាំ

លោក ឈាន បូណា

ថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ

ជំនាន់ទី១៥

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ **កោះ ច័ន្ទឫទ្ធិសក្តិ** និង **លាង លីឌឺរ** ជានិស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជំនាញរដ្ឋបាលសាធារណៈ ឆ្នាំទី៤ ជំនាន់ទី១៥ ក្រុម P4B1 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំសូមធ្វើការសម្តែងនូវកតញ្ញូតាធម៌ និងការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ៖

- លោកឪពុក **កោះ សាលួត** អ្នកម្តាយ **លន់ ចាន់ធី** និង លោកឪពុក **អ៊ីុខ លាខ** អ្នកម្តាយ **ស៊ឹម សាវឿន** ដែលជាអ្នកមានគុណមិនអាចកាត់ថ្លៃបាន ដោយបានផ្តល់កំណើតដល់រូបយើងខ្ញុំ ព្រមទាំងបានចិញ្ចឹមបីបាច់ ថែរក្សាដោយក្តីស្រឡាញ់ ប្រកបដោយព្រហ្មវិហារធម៌ អប់រំទូន្មាន ប្រៀនប្រដៅ និងទំនុកបម្រុងគ្រប់បែបយ៉ាងទាំងអស់ ទាំងផ្នែកស្មារតី និងថវិកា សម្រាប់ផ្តល់ដល់យើងខ្ញុំ ឱ្យមានឱកាសបានបន្តការសិក្សាដល់ថ្នាក់បរិញ្ញាបត្រនេះ។
- ឯកឧត្តមបណ្ឌិត **លុយ ចន្ណា** សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស មន្ត្រីរាជការ សាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឱ្យយើងខ្ញុំបានចូលសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ នៅសាកលវិទ្យាល័យនេះ និងបង្កភាពងាយស្រួលដល់ការសិក្សារបស់យើងខ្ញុំកន្លងមក។
- លោក **ឈាន មូណា** សាស្ត្រាចារ្យណែនាំ ដែលបានឆ្លៀតពេលវេលាដ៏មានតម្លៃ និងមមាញឹកពីការងារ ដើម្បីមកដឹកនាំក្រុមយើងខ្ញុំសរសេរសារណាបញ្ចប់ឆ្នាំសិក្សា ដោយមិនខ្លាចនឿយហត់ ក្នុងការផ្តល់គំនិត មតិយោបល់ និងវិធីសាស្ត្រនានា តាំងពីការចាប់ផ្តើម រហូតដល់ការសរសេរសារណាមួយនេះបានបញ្ចប់សព្វគ្រប់។
- ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីនៃក្រសួងរ៉ែ និងថាមពល លោក **ផៃ ច័ន្ទត្រាសិទ្ធិ** ប្រធាននាយកដ្ឋាន និងអ្នកស្រី **ហេង សុនា** អនុប្រធាននាយកដ្ឋាន នៃនាយកដ្ឋាននីតិកម្ម ដែលបានផ្តល់ឱកាសឱ្យយើងខ្ញុំ ចុះមកសិក្សាស្រាវជ្រាវ និងស្វែងរកឯកសារ លិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងឆ្លៀតពេលវេលា មកជួយជ្រោមជ្រែងណែនាំពន្យល់បន្ថែមពីនីតិវិធីនៃការអនុវត្តការងារផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងប្រធានបទមួយនេះផងដែរ។
- ជាចុងបញ្ចប់នេះ យើងខ្ញុំសូមប្រសិទ្ធិពរជ័យបវរជូនដល់ លោកអ្នកមានគុណ ទ្រង់ឯកឧត្តម និងលោកសាស្ត្រាចារ្យ សូមជួបតែភាពជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាននូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ការសិក្សានៅថ្នាក់បរិញ្ញាបត្រ ដែលមានរយៈពេលបួនឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានកន្លងផុតទៅយ៉ាងឆាប់រហ័ស ដោយនៅក្នុងរយៈពេលសិក្សាមួយនេះបានផ្តល់នូវចំណេះដឹងថ្មីៗដល់យើងខ្ញុំ ក៏ដូចជាមិត្តនិស្សិតគ្រប់រូប ក្រោមការបង្ហាត់បង្រៀន យ៉ាងយកចិត្តទុកដាក់ពីសំណាក់ លោកគ្រូ អ្នកគ្រូ ដែលជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យ បានចំណាយពេលដ៏មានតម្លៃ ក្នុងការជួយបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីជំរុញដល់ការអភិវឌ្ឍប្រទេសជាតិឱ្យមានភាពរីកចម្រើន។ តាមរយៈកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ នៅឆ្នាំបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ តម្រូវឱ្យនិស្សិតធ្វើការប្រឡងបញ្ចប់ ឬការជ្រើសរើសការសរសេរសារណាដើម្បីធ្វើការការពារបញ្ចប់នូវការសិក្សារបស់ខ្លួន។ ដោយឡែកយើងខ្ញុំទាំងពីរអ្នក មានកិត្តិយស ដែលសាកលវិទ្យាល័យ បានផ្តល់ឱកាសឱ្យយើងខ្ញុំ បង្កើត និងសរសេរសារណាបញ្ចប់ការសិក្សា ក្នុងគោលបំណងចែករំលែកចំណេះដឹងដែលបានសិក្សាកន្លងមក ក្នុងថ្នាក់បរិញ្ញាបត្រជំនាញរដ្ឋបាលសាធារណៈជាពិសេសដើម្បីបង្ហាញពីសមត្ថភាព និងលទ្ធភាពនៃការយល់ដឹងទាក់ទងទៅនឹងប្រធានបទ "**ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល**"។ ការដែលយើងខ្ញុំទាំងពីរអ្នក លើកយកប្រធានបទមួយនេះសម្រាប់យកមកសរសេរសារណា និងធ្វើការការពារបញ្ចប់នៅថ្នាក់បរិញ្ញាបត្រនេះ គឺដើម្បីធ្វើការសិក្សាទៅលើការរៀបចំហេដ្ឋារចនាសម្ព័ន្ធរបស់ក្រសួងរ៉ែ និងថាមពល ព្រមទាំងសិក្សាស្វែងយល់ពីតួនាទីភារកិច្ចរបស់អង្គភាពមួយនេះ ដែលជាស្ថាប័នមានទំនួលខុសត្រូវទៅលើការគ្រប់គ្រង និងដឹកនាំការអភិវឌ្ឍវិស័យរ៉ែ និងថាមពល ក្នុងព្រះរាជាណាចក្រកម្ពុជា។

យើងខ្ញុំទាំងពីរអ្នកជឿជាក់យ៉ាងមុតមាំថា សារណាមួយនេះ នឹងផ្តល់ផលប្រយោជន៍ជាឯកសារស្រាវជ្រាវដ៏មានតម្លៃអំពីដំណើរនៃការរៀបចំរបស់ស្ថាប័នដែលគ្រប់គ្រងទៅលើវិស័យរ៉ែ និងថាមពល ក្នុងព្រះរាជាណាចក្រកម្ពុជា ដល់គ្រប់មជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវ ក៏ដូចជាសិស្ស និស្សិតជំនាន់ក្រោយបន្តការសិក្សាបន្ថែមតទៅទៀត។

ទន្ទឹមនឹងនេះ យើងខ្ញុំក៏សូមធ្វើការអភ័យទោសផងដែល ចំពោះរាល់កំហុសឆ្គង ឬភាពខ្វះខាតទាំងឡាយណាដែលកើតមានដោយអចេតនា តាមរយៈកំហុសអក្ខរាវិរុទ្ធ ការបកស្រាយ និងការប្រើប្រាស់ពាក្យពេចន៍មិនសមស្រប ឬក៏ជាកង្វះខាតនូវអត្ថន័យត្រង់ចំណុចណាមួយក្តីនៅក្នុងសារណានេះ យើងខ្ញុំទាំងពីររូបត្រៀមទទួលយកការរិះគន់ទាំងឡាយណាក្នុងន័យស្ថាបនា និងកែលម្អ ដើម្បីឱ្យយើងខ្ញុំអាចកែប្រែកំហុសទាំងអស់នោះ និងដើម្បីឱ្យការស្រាវជ្រាវកាន់តែមានភាពល្អប្រសើរជាងមុនទៅទៀត។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

១.ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

២.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២

៣.គោលបំណងនៃការសិក្សាស្រាវជ្រាវ ........ ២

៤.វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២

៥.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

**ជំពូកទី១**

**ប្រវត្តិសាវតា និងរចនាសម្ព័ន្ធរបស់ក្រសួងរ៉ែ និងថាមពល**

**១.ប្រវត្តិសាវតា** ........ ៤

**២.បេសកកម្ម មុខងារ និងភារកិច្ច** ........ ៥

២.១ បេសកកម្ម ........ ៥

២.២ មុខងារ និងភារកិច្ច ........ ៥

**៣.រចនាសម្ព័ន្ធ** ........ ៦

**ជំពូកទី២**

**ការរៀបចំ និងភារកិច្ចរបស់អង្គភាពក្រោមចំណុះក្រសួងរ៉ែ និងថាមពល**

**១.អង្គភាពថ្នាក់ជាតិ** ........ ៩

១.១. ខុទ្ទកាល័យ ........ ៩

១.២. អគ្គនាយកដ្ឋានកិច្ចការទូទៅ ........ ១០

១.៣. អគ្គនាយកដ្ឋានធនធានរ៉ែ ........ ១៤

១.៤. អគ្គនាយកដ្ឋានថាមពល ........ ១៧

១.៥.អគ្គនាយកដ្ឋានប្រេងកាត ........ ២២

១.៦.អគ្គាធិការដ្ឋាន ........ ២៥

១.៧.នាយកដ្ឋានសវនកម្មផ្ទៃក្នុង ........ ២៧

**២.អង្គភាពថ្នាក់ក្រោមជាតិ** ........ ២៩

២.១. ថ្នាក់រាជធានី-ខេត្ត ........ ២៩

២.២.ថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ .......... ៣៤

## ជំពូកទី៣
## សមិទ្ធផល បញ្ហាប្រឈម ដំណោះស្រាយ និងផែនការសកម្មភាព

**១.សមិទ្ធផល** .......... ៣៥
១.១. វិស័យថាមពល .......... ៣៦
១.២. វិស័យរ៉ែ .......... ៤០
១.៣. វិស័យប្រេងកាត .......... ៤៦
**២. បញ្ហាប្រឈម និងដំណោះស្រាយ** .......... ៥០
**៣. គោលដៅការងារ និងផែនការសកម្មភាពរបស់ក្រសួងរ៉ែ និងថាមពល** .......... ៥២
៣.១.វិស័យរ៉ែ .......... ៥២
៣.២. វិស័យថាមពល .......... ៦០
៣.៣.វិស័យប្រេងកាត .......... ៦១
**សេចក្តីសន្និដ្ឋាន** .......... ៦២
**ឯកសារយោង**
**សន្ទានុក្រម**
**បញ្ជីឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ធនធានរ៉ែ គឺជាសារធាតុទាំងឡាយណា ទោះជាក្នុងទម្រង់រឹង រាវ ឧស្ម័នដែលកកើតឡើងដោយធម្មជាតិ តាមដំណើរវិវត្តភូគព្ភសាស្ត្រ ឬជាលទ្ធផលនៃការជីកយកពីក្នុងដី លើដី ក្នុងសមុទ្រ ក្រោមបាតសមុទ្រ មានជាអាទិ៍ ត្បូងថ្ម រ៉ែអលោហៈ រ៉ែលោហៈ ទឹកខនិជ ថ្ម ក្រួស ខ្សាច់ ដីឥដ្ឋ ប្រេងកាត និងឧស្ម័ន[1]។ ម្យ៉ាងវិញទៀត ធនធានរ៉ែ គឺជាធនធានធម្មជាតិមិនកកើតឡើងវិញ ពោលកាលណាដែលយើងទាញយកវាមកប្រើប្រាស់ហើយ វានឹងអស់ និងមិនអាចកកើតឡើងវិញបានឡើយ ដូច្នេះទាមទារឱ្យមានការគ្រប់គ្រង ការប្រើប្រាស់ និងការទាញយក ធនធានរ៉ែ គឺតម្រូវឱ្យមានភាពប្រុងប្រយ័ត្នខ្ពស់បំផុត ជាពិសេសត្រូវធ្វើយ៉ាងណា ឱ្យការអភិវឌ្ឍធនធានរ៉ែ ប្រកបដោយចីរភាព និងយូរអង្វែង សម្រាប់ផ្តល់ផលប្រយោជន៍ក្នុងការអភិវឌ្ឍសង្គមជាតិ។ ធនធានរ៉ែទាំងអស់ ដែលឋិតនៅក្នុងដី លើដី ឬក្រោមដីនៃដែនគោក ភ្នំ ខ្ពង់រាប ដែនទឹក ដែនសមុទ្រ កោះ បាតសមុទ្រ ក្រោមបាត-សមុទ្រ ក្នុងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ជាសម្បត្តិរដ្ឋ[2]។ ដូច្នេះគ្មានរូបវន្តបុគ្គល ឬនីតិបុគ្គល ណាអាចធ្វើការស្វែងរុករក ឬធ្វើអាជីវកម្មធនធានរ៉ែ ដោយគ្មានអាជ្ញាបណ្ណធនធានរ៉ែ ដែលចេញដោយស្ថាប័ន មានសមត្ថកិច្ចឡើយ លើកលែងតែម្ចាស់កម្មសិទ្ធិ ឬអ្នកកាន់កាប់ស្របច្បាប់លើដីធ្លី ដែលជាឯកជនអាចប្រើប្រាស់ ក្រួស ខ្សាច់ ថ្ម ដីឥដ្ឋ ដោយមិនចាំបាច់មានអាជ្ញាបណ្ណ តែមិនអនុញ្ញាតឱ្យដឹកជញ្ជូនចេញផុតពីព្រំដែនដីធ្លីជា កម្មសិទ្ធិដើម្បីធ្វើអាជីវកម្មនោះទេ។ ប្រជាពលរដ្ឋខ្មែរអាចធ្វើបុរេសនានៅលើដីរបស់រដ្ឋឱ្យតែដីនោះ រដ្ឋមិនទាន់ ចេញអាជ្ញាបណ្ណធនធានរ៉ែទៅបុគ្គលដទៃ[3]។ ចំពោះស្ថាប័នសមត្ថកិច្ចដែលមានសិទ្ធិអំណាច ក្នុងការចេញអាជ្ញា-បណ្ណ សម្រាប់ការស្វែងរុករក ឬធ្វើអាជីវកម្មធនធានរ៉ែ គឺមានតែក្រសួងរ៉ែ និងថាមពលតែមួយប៉ុណ្ណោះ។

ក្រសួងរ៉ែ និងថាមពល បំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើបេសកកម្មដឹកនាំ និង គ្រប់គ្រងលើវិស័យរ៉ែ និងថាមពល រួមទាំងវិស័យប្រេងកាត ឧស្ម័ន និងអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា[4]។ ដោយសង្កេតឃើញថា ធនធានរ៉ែ ជាធនធានមួយដែលមិនកកើតឡើងវិញ ដូច្នេះត្រូវតែមានអ្នកទំនួលខុសត្រូវ ខ្ពស់ សម្រាប់ធ្វើការគ្រប់គ្រង ដឹកនាំការអភិវឌ្ឍវិស័យមួយនេះឱ្យមានភាពរីកចម្រើន ដើម្បីជាផលប្រយោជន៍ ដល់ការអភិវឌ្ឍសង្គមជាតិឱ្យមានលក្ខណៈកាន់តែប្រសើរឡើង។ ដោយមើលឃើញពីភាពចាំបាច់សម្រាប់ការ គ្រប់គ្រងធនធានរ៉ែ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើឱ្យក្រុមរបស់យើងខ្ញុំ សម្រេចចិត្តជ្រើសរើសយកប្រធានបទ ស្តីពី "**ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងរ៉ែ និងថាមពល**" ដើម្បីសរសេរជាសារណា ក្នុងកិច្ចការការពារ

[1] យោងតាមមាត្រា៣ នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ

[2] យោងតាមមាត្រា២ នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ

[3] យោងតាមមាត្រា៥ នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ

[4] យោងតាមមាត្រា៤អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងរ៉ែ និងថាមពល

បញ្ចប់ការសិក្សានៅថ្នាក់បរិញ្ញាបត្រ ជំនាញរដ្ឋបាលសាធារណៈ ជំនាន់ទី១៥ នៃសាកលវិទ្យាល័យភូមិន្ទនីតិ-សាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## ១.ចំណោទបញ្ហានៃការស្រាវជ្រាវ

ចំពោះចំណោទបញ្ហានៃប្រធានបទមួយនេះ ក្រុមរបស់យើងខ្ញុំនឹងធ្វើការចោទសួរទៅលើបញ្ហាមួយចំនួនដូចខាងក្រោម៖

- តើក្រសួងរ៉ែ និងថាមពល មានសារៈតាដូចម្តេច? និងបំពេញបេសកកម្មលើមុខងារអ្វីខ្លះ?
- តើក្រសួងរ៉ែ និងថាមពល មានរចនាសម្ព័ន្ធដូចម្តេចខ្លះ? និងធ្វើការបែងចែកតួនាទី ភារកិច្ចទៅឱ្យអង្គភាពនានាក្រោមចំណុះបែបណាខ្លះ?
- តើក្រសួងរ៉ែ និងថាមពលបានសម្រេចនូវសមិទ្ធផលអ្វីខ្លះ? ហើយជួបប្រទះបញ្ហាប្រឈមយ៉ាងដូចម្តេច? តើមានដំណោះស្រាយបែបណាចំពោះបញ្ហាប្រឈម និងមានផែនការសកម្មភាពសម្រាប់អនុវត្តបន្តយ៉ាងដូចម្តេចខ្លះ?

## ២.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល គឺជាការសិក្សាទៅលើប្រវត្តិសារៈតា និងបេសកកម្មរបស់ក្រសួង។ បន្ថែមពីនេះ ក៏សិក្សាទៅលើរចនាសម្ព័ន្ធ តួនាទីភារកិច្ចនៃអង្គភាពចំណុះក្រសួងដែលមានថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ទន្ទឹមនឹងនោះយើងខ្ញុំក៏ធ្វើការសិក្សាអំពីសមិទ្ធផលសំខាន់ៗ ដែលក្រសួងរ៉ែ និងថាមពលសម្រេចបានចាប់ពីឆ្នាំ២០១៧ ទៅដល់ឆ្នាំ២០២១ ព្រមទាំងសិក្សាអំពីបញ្ហាប្រឈមនានា ដែលក្រសួងបានជួបប្រទះ ក៏ដូចជាវិធីសាស្ត្រក្នុងការដោះស្រាយ និងផែនការសកម្មភាពសម្រាប់អភិវឌ្ឍនាឆ្នាំបន្តបន្ទាប់ទៀតរបស់ក្រសួងរ៉ែ និងថាមពល។

## ៣.គោលបំណងនៃការសិក្សាស្រាវជ្រាវ

គោលបំណងចម្បងនៃការសិក្សាស្រាវជ្រាវនេះ គឺធ្វើឡើងដើម្បីសិក្សាស្វែងយល់អំពីការបែងចែកតួនាទីភារកិច្ចនៃការគ្រប់គ្រងរបស់អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចំណុះឱ្យក្រសួងរ៉ែ និងថាមពល ជាពិសេសសិក្សាទៅលើសមិទ្ធផលដែលក្រសួងសម្រេចបាន ព្រមទាំងធ្វើការសិក្សាទៅលើបញ្ហាប្រឈម ដំណោះស្រាយ និងការលើកផែនការសកម្មភាពនៃការគ្រប់គ្រងរបស់ក្រសួងរ៉ែ និងថាមពល ទៅលើវិស័យរ៉ែ វិស័យប្រេងកាត និងវិស័យថាមពលនៅប្រទេសកម្ពុជា។

## ៤.វិធីសាស្ត្រនៃការស្រាវជ្រាវ

ចំពោះការសរសេរសារណានេះ គឺធ្វើឡើងតាមរយៈការសិក្សាស្រាវជ្រាវ ទៅលើការប្រមូលព័ត៌មាន និងជ្រើសរើសចេញពីសំណុំលិខិតបទដ្ឋានគតិយុត្ត របាយការណ៍បូកសរុបលទ្ធផលការងារ សៀវភៅ និងគេហទំព័រ

នានារបស់រាជរដ្ឋាភិបាល និងក្រសួងរ៉ែ និងថាមពល ជាពិសេសក្រុមរបស់យើងខ្ញុំក៏បានធ្វើការចុះសិក្សាស្រាវជ្រាវឯកសារ និងស្វែងយល់ពីការងារមួយចំនួនដែលពាក់ព័ន្ធទៅនឹងប្រធានបទ "**ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល**" នៅនាយកដ្ឋាននីតិកម្ម នៃអគ្គនាយកដ្ឋានកិច្ចការទូទៅ នៃក្រសួងរ៉ែ និងថាមពល ដូចមានលិខិត និងរូបថតភ្ជាប់មកជាមួយនៅឧបសម្ព័ន្ធទី៧ ទី៨ និងទី៩។

## ៥.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានភាពជោគជ័យល្អប្រសើរ និងប្រកបដោយគុណភាពប្រសិទ្ធិភាពខ្ពស់នោះ គឺចាំបាច់ក្នុងការកំណត់រចនាសម្ព័ន្ធដ៏ពិតប្រាកដមួយ ដើម្បីអាចបំពេញតាមលក្ខណៈវិធីសាស្ត្រស្រាវជ្រាវត្រឹមត្រូវរបស់សាកលវិទ្យាល័យ។ កិច្ចការស្រាវជ្រាវមួយនេះ បានធ្វើការបែងចែកជា ៣ជំពូកសំខាន់ៗ ដែលមានដូចខាងក្រោម៖

**ជំពូកទី១ ប្រវត្តិ និងរចនាសម្ព័ន្ធរបស់ក្រសួងរ៉ែ និងថាមពល**

១.ប្រវត្តិសាវតា

២.បេសកកម្ម ភារកិច្ច និងមុខងារ

៣.រចនាសម្ព័ន្ធ

**ជំពូកទី២ ការរៀបចំ និងភារកិច្ចរបស់អង្គភាពក្រោមចំណុះក្រសួងរ៉ែ និងថាមពល**

១.អង្គភាពថ្នាក់ជាតិ

២.អង្គភាពថ្នាក់ក្រោមជាតិ

**ជំពូកទី៣ សមិទ្ធផល បញ្ហាប្រឈម ដំណោះស្រាយ និងផែនការសកម្មភាព**

១.សមិទ្ធផលដែលសម្រេចបាន

២.បញ្ហាប្រឈម និងដំណោះស្រាយ

៣.គោលដៅ និងផែនការសកម្មភាព

**សេចក្តីសន្និដ្ឋាន**

**ឯកសារយោង**

**បញ្ជីឧបសម្ព័ន្ធ**

# ជំពូកទី១

# ប្រវត្តិសាវតា និងរចនាសម្ព័ន្ធរបស់ក្រសួងរ៉ែ និងថាមពល

## ១.ប្រវត្តិសាវតា

រាជរដ្ឋាភិបាលកម្ពុជានៅក្នុងនីតិកាលទី៥នៃរដ្ឋសភា បានសម្រេចបង្កើតក្រសួងរ៉ែ និងថាមពល ដែលត្រូវបានបង្កើតឡើងតាមរយៈព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ (ឧបសម្ព័ន្ធទី២)។ ការបង្កើតក្រសួងរ៉ែ និងថាមពល គឺជាការដាក់បញ្ចូលវិស័យបីចូលគ្នាឱ្យស្ថិតនៅក្នុងស្ថាប័នតែមួយ ដោយវិស័យទាំងបីនោះមាន វិស័យធនធានរ៉ែ វិស័យថាមពល និងវិស័យប្រេងកាត។

ចំពោះវិស័យបីខាងលើនេះ មុនឆ្នាំ២០១៣ ពោលមុនពេលបង្កើតក្រសួងរ៉ែ និងថាមពល គឺស្ថិតនៅក្រោមស្ថាប័នពីរផ្សេងៗគ្នា ដូចខាងក្រោម៖

- **វិស័យធនធានរ៉ែ និងវិស័យថាមពល** គឺជាវិស័យដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦។ ស្ថាប័នមួយនេះ មានសមត្ថកិច្ចដឹកនាំគ្រប់គ្រង លើវិស័យឧស្សាហកម្ម សិប្បកម្ម រ៉ែ និងថាមពល នៃព្រះរាជាណាចក្រកម្ពុជា។ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបានបំបែកចេញជាពីរស្ថាប័ន ក្នុងគោលបំណងផ្ដាច់ចេញវិស័យគ្រប់គ្រងទៅតាមស្ថាប័នរៀងៗខ្លួន គឺក្រសួងឧស្សាហកម្ម និងសិប្បកម្ម គ្រប់គ្រងទៅលើវិស័យឧស្សាហកម្ម និងសិប្បកម្ម (បច្ចុប្បន្នបានប្ដូរឈ្មោះមកជា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តាមរយៈព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ស្ដីពីច្បាប់បង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ) និងក្រសួងរ៉ែ និងថាមពល គ្រប់គ្រងលើវិស័យរ៉ែ និងវិស័យថាមពល។
- **វិស័យប្រេងកាត** ជាវិស័យមួយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ អតីតអាជ្ញាធរប្រេងកាតជាតិកម្ពុជា ដែលជាស្ថាប័នអចិន្ត្រៃយ៍ នៃរាជរដ្ឋាភិបាលកម្ពុជា ដែលបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ ជស/រតក/០១៩៨/០២០ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៨។ ស្ថាប័នមួយនេះមានភារកិច្ចរៀបចំ និងអភិវឌ្ឍការងារទាំងផ្នែកអាប់ស្ទ្រីម (Upstream) និងដោនស្ទ្រីម (Downstream) នៃឧស្សាហកម្មប្រេងកាត។ វិស័យប្រេងកាតត្រូវបានផ្ទេរ និងធ្វើសមាហរណកម្មអាជ្ញាធរប្រេងកាតជាតិកម្ពុជាទៅក្រោមក្រសួងរ៉ែ និងថាមពល[5]។

[5] យោងមាត្រា២ នៃព្រះរាជក្រឹត្យស្ដីពីការផ្ទេរ និងធ្វើសមាហរណកម្មអាជ្ញាធរប្រេងកាតជាតិកម្ពុជាទៅក្រោមក្រសួងរ៉ែ និងថាមពល

**<u>សំគាល់៖</u>** អាជ្ញាធរអគ្គិសនីកម្ពុជា ដែលត្រូវបានកំណត់ដោយច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រកម.០២០១.០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ត្រូវស្ថិតនៅក្រោមការដឹកនាំ និងគ្រប់គ្រងផ្នែកគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការរបស់ក្រសួងរ៉ែ និងថាមពល[6]។

## ២.បេសកកម្ម មុខងារ និងភារកិច្ច

### ២.១ បេសកកម្ម

ក្រសួងរ៉ែ និងថាមពលបំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាល ដែលមានបេសកកម្មដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យរ៉ែ និងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម និងអគ្គិសនី។ បេសកកម្មនេះត្រូវធ្វើឡើងតាមរយៈការរៀបចំ និងការអនុវត្តឱ្យបានត្រឹមត្រូវ នូវគោលនយោបាយក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិទាំងឡាយទាក់ទងនឹងការដឹកនាំ ការគ្រប់គ្រង និងការអភិវឌ្ឍ វិស័យរ៉ែ និងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី។

### ២.២ មុខងារ និងភារកិច្ច

ក្រសួងរ៉ែ និងថាមពលមានមុខងារភារកិច្ចដូចជា (១) រៀបចំ និងអនុវត្តគោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្ត្រ លើវិស័យរ៉ែ និងថាមពល រួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី (២) រៀបចំតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យរ៉ែ និងថាមពល រួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី (៣) អនុវត្តផែនការយុទ្ធសាស្ត្រ និងសហប្រតិបត្តិការជាមួយស្ថាប័ន ជាតិ និងអន្តរជាតិ សំដៅគ្រប់គ្រង និងអភិវឌ្ឍវិស័យរ៉ែ និងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី (៤) គ្រប់គ្រងការងារសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រ ផ្សព្វផ្សាយទិន្នន័យភូគព្ភសាស្ត្រ និងការសិក្សាស្រាវជ្រាវរុករធនធានរ៉ែ (៥) គ្រប់គ្រងការអភិវឌ្ឍ ការធ្វើអាជីវកម្ម ការប្រើប្រាស់ធនធានរ៉ែ ការប្រើប្រាស់អណ្តូងរ៉ែ ការបន្សុទ្ធ និងការចម្រាញ់រ៉ែ ព្រមទាំងរាល់សកម្មភាពទាំងឡាយដែលទាក់ទងទៅនឹងប្រតិបត្តិការធនធានរ៉ែ (៦) គ្រប់គ្រងការសិក្សាស្រាវជ្រាវអំពីប្រភពការផលិត ការចែកចាយ និងការប្រើប្រាស់ថាមពល ព្រមទាំងការការពារសុវត្ថិភាពក្នុងវិស័យថាមពល (៧) គ្រប់គ្រងការធ្វើផែនការ និងការអភិវឌ្ឍអគ្គិសនី ស្ថានីយផលិតអគ្គិសនី ប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនី ប្រព័ន្ធចែកចាយអគ្គិសនី និងវាយតម្លៃសក្តានុពលវារីអគ្គិសនីដើម្បីរៀបចំអភិវឌ្ឍទំនប់វារីអគ្គិសនីណា ដែលមានការផលិតថាមពលអគ្គិសនីជាគោលបំណងចម្បង (៨) គ្រប់គ្រងការងារប្រេងកាត ផ្នែកអាប់ស្ទ្រីម (Upstream) និងផ្នែកដោនស្ទ្រីម (Downstream)

[6] យោងមាត្រា៥ នៃច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល

ដែលរួមមានបុរេសនា ការស្វែងរុករក ការអភិវឌ្ឍ និងផលិតកម្មប្រេងកាត ការធ្វើប្រព្រឹត្តិកម្មប្រេងកាត និងគីមីប្រេងកាត ការដឹកជញ្ជូន និងចែកចាយ សន្និធិ ការនាំចេញ-ការនាំចូល និងការធ្វើពាណិជ្ជកម្មប្រេងកាត និងផលិតផលប្រេងកាត (៩) លើកកម្ពស់ការការពារ និងអភិរក្សគុណភាពបរិស្ថាន និងសុខុមាលភាពសង្គម ក្នុងវិស័យរ៉ែ និងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី (១០) កៀរគរចំណូលមិនមែនសារពើពន្ធពាក់ព័ន្ធនឹងវិស័យរ៉ែ និងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម និងអគ្គិសនី[7]។

## ៣.រចនាសម្ព័ន្ធ

ក្នុងការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល គឺមានពីរដំណាក់កាល ពោលដំណាក់កាលទី១ នៅឆ្នាំ២០១៣ តាមរយៈអនុក្រឹត្យលេខ ៥៧៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ និងដំណាក់កាលទី២ តាមរយៈអនុក្រឹត្យលេខ ១៣៧ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨។

ដំណាក់កាលទី១៖ ការរៀបចំរចនាសម្ព័ន្ធរបស់ក្រសួងរ៉ែ និងថាមពល មានរចនាសម្ព័ន្ធដូចខាងក្រោម

**ក.អង្គភាពថ្នាក់កណ្តាល**

១. ខុទ្ទកាល័យរដ្ឋមន្ត្រី

២. អគ្គនាយកដ្ឋានកិច្ចការទូទៅ ត្រូវបានបែងចែកចេញជា ០៥ នាយកដ្ឋានរួមមាន (១) នាយកដ្ឋានរដ្ឋបាល និងព័ត៌មានវិទ្យា (២) នាយកដ្ឋានបុគ្គលិក (៣) នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ (៤) នាយកដ្ឋាននីតិកម្ម និង(៥) នាយកដ្ឋានសហប្រតិបត្តិការ និងកិច្ចការអាស៊ាន។

៣. អគ្គនាយកដ្ឋានធនធានរ៉ែ ត្រូវបានបែងចែកចេញជា ០៥ នាយកដ្ឋានរួមមាន (១) នាយកដ្ឋានភូគព្ភសាស្ត្ររ៉ែ (២) នាយកដ្ឋានជំរុញ និងអភិវឌ្ឍធនធានរ៉ែ (៣) នាយកដ្ឋានគ្រប់គ្រងការស្វែងរុករករ៉ែ (៤) នាយកដ្ឋានរ៉ែសំណង់ និង(៥) នាយកដ្ឋានអាជីវកម្មរ៉ែ។

៤. អគ្គនាយកដ្ឋានប្រេងកាត ត្រូវបានបែងចែកចេញជា ០៥ នាយកដ្ឋានរួមមាន (១) នាយកដ្ឋានសិក្សាស្រាវជ្រាវប្រេងកាត (២) នាយកដ្ឋានជំរុញ និងអភិវឌ្ឍធនធានប្រេងកាត (៣) នាយកដ្ឋានគ្រប់គ្រងគម្រោងសម្បទានប្រេងកាត (៤) នាយកដ្ឋានកិច្ចការប្រេងកាតអន្តរជាតិ និង(៥) នាយកដ្ឋានបច្ចេកវិទ្យាប្រេងកាត គាំទ្រកិច្ចប្រតិបត្តិការ និងសន្តិសុខថាមពល។

៥. អគ្គនាយកដ្ឋានថាមពល ត្រូវបានបែងចែកចេញជា ០៤ នាយកដ្ឋានរួមមាន (១) នាយកដ្ឋានអភិវឌ្ឍថាមពល (២) នាយកដ្ឋានថាមពលកកើតឡើងវិញ និងថាមពលថ្មី (៣) នាយកដ្ឋានវារីអគ្គិសនី

[7] យោងមាត្រា៥ អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងរ៉ែ និងថាមពល

និង(៤) នាយកដ្ឋានបច្ចេកទេសថាមពល និងកិច្ចការថាមពលបរមាណូ។

៦. អគ្គាធិការដ្ឋាន

៧. នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**ខ.អង្គភាពថ្នាក់មូលដ្ឋាន**

នៅថ្នាក់មូលដ្ឋាន មានមន្ទីររ៉ែ និងថាមពល និងសាខាសមត្ថកិច្ចជំនាញរាជធានី ខេត្ត។

**រូបភាពទី១ អង្គការលេខរបស់ក្រសួងរ៉ែ និងថាមពល ដំណាក់កាលទី១**




<u>ដំណាក់កាលទី២៖</u> ការរៀបចំរចនាសម្ព័ន្ធរបស់ក្រសួងរ៉ែ និងថាមពល មានរចនាសម្ព័ន្ធដូចខាងក្រោម

**ក.អង្គភាពថ្នាក់កណ្ដាល**

១. ខុទ្ទកាល័យរដ្ឋមន្ត្រី

២. អគ្គនាយកដ្ឋានកិច្ចការទូទៅ ត្រូវបានបែងចែកចេញជា ០៦ នាយកដ្ឋានរួមមាន (១) នាយកដ្ឋានរដ្ឋបាល និងព័ត៌មានវិទ្យា (២) នាយកដ្ឋានបុគ្គលិក (៣) នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ (៤) នាយកដ្ឋានផែនការ (៥) នាយកដ្ឋាននីតិកម្ម (៦) នាយកដ្ឋានសហប្រតិបត្តិការ និងកិច្ចការអាស៊ាន

៣. អគ្គនាយកដ្ឋានធនធានរ៉ែ ត្រូវបានបែងចែកចេញជា ០៦ នាយកដ្ឋានរួមមាន (១) នាយកដ្ឋានភូគព្ភ-សាស្ត្ររ៉ែ (២) នាយកដ្ឋានផែនការសេដ្ឋកិច្ចធនធានរ៉ែ (៣) នាយកដ្ឋានឧស្សាហកម្មអាជីវកម្មធនធាន

រ៉ែ (៤) នាយកដ្ឋានអាជីវកម្មរ៉ែខ្សាច់សំណង់ (៥) នាយកដ្ឋានអាជីវកម្មរ៉ែថ្មសំណង់ (៦) នាយកដ្ឋានត្រួតពិនិត្យប្រតិបត្តិការធនធានរ៉ែ

៤. អគ្គនាយកដ្ឋានប្រេងកាត ត្រូវបានបែងចែកចេញជា ០៥ នាយកដ្ឋានរួមមាន (១) នាយកដ្ឋានសិក្សាស្រាវជ្រាវប្រេងកាត (២) នាយកដ្ឋានជំរុញ និងអភិវឌ្ឍធនធានប្រេងកាត (៣) នាយកដ្ឋានគ្រប់គ្រងគម្រោងសម្បទានប្រេងកាត (៤) នាយកដ្ឋានកិច្ចការប្រេងកាតអន្តរជាតិ (៥) នាយកដ្ឋានបច្ចេកវិទ្យាប្រេងកាត គាំទ្រកិច្ចប្រតិបត្តិការ និងសន្តិសុខថាមពល

៥. អគ្គនាយកដ្ឋានថាមពល ត្រូវបានបែងចែកចេញជា ០៦ នាយកដ្ឋានរួមមាន (១) នាយកដ្ឋានអភិវឌ្ឍថាមពល (២) នាយកដ្ឋានវារីអគ្គិសនី (៣) នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាបរមាណូ (៤) នាយកដ្ឋានថាមពលកំដៅ និងចំហេះ (៥) នាយកដ្ឋានថាមពលកកើតឡើងវិញ និងថាមពលផ្សេងទៀត (៦) នាយកដ្ឋានបច្ចេកទេស និងគោលនយោបាយអាជីវកម្មថាមពល

៦. អគ្គាធិការដ្ឋាន

៧. នាយកដ្ឋានសវនកម្មផ្ទៃក្នុង

## ខ.អង្គភាពថ្នាក់មូលដ្ឋាន

នៅថ្នាក់មូលដ្ឋាន មានមន្ទីររ៉ែ និងថាមពល និងសាខាសមត្ថកិច្ចជំនាញរាជធានី ខេត្ត។

**រូបភាពទី២ អង្គការលេខរបស់ក្រសួងរ៉ែ និងថាមពល ដំណាក់កាលទី២**



# ជំពូកទី២

# ការរៀបចំ និងភារកិច្ចរបស់អង្គភាពក្រោមចំណុះក្រសួងវ៉ៃ និងថាមពល

## ១.អង្គភាពថ្នាក់ជាតិ

### ១.១. ខុទ្ទកាល័យ

ខុទ្ទកាល័យ គឺជាកន្លែងដែលបំពេញបេសកកម្មជាជំនួយការដល់ថ្នាក់ដឹកនាំសាមី ដែលជាអ្នកដឹកនាំនយោបាយលើការងារក្នុងរង្វង់រាជរដ្ឋាភិបាល និង/ឬរដ្ឋសភា ក៏ដូចជាអ្នកដឹកនាំរដ្ឋបាលក្នុងរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន។ ខុទ្ទកាល័យរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យ នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការដែលជាប្រធានស្ថាប័ន[8]។

ដោយយោងទៅតាមអនុក្រឹត្យខាងលើ ភារកិច្ចរបស់ខុទ្ទកាល័យមានជាអាទិ៍៖ (១) រ៉ាប់រងទំនាក់ទំនងរវាងខុទ្ទកាល័យរបស់ថ្នាក់ដឹកនាំក្នុងរាជរដ្ឋាភិបាល ព្រមទាំងទំនាក់ទំនងជាមួយអ្នកតំណាងរាស្ត្រ អង្គភាពរដ្ឋបាលនៃស្ថាប័នសាធារណៈផ្សេងៗទៀត និងប្រព័ន្ធឃោសនាទាំងឡាយ (២) ផ្តល់ជូនយោបល់ជូននាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័នចំណុះរាជរដ្ឋាភិបាល ចំពោះកិច្ចការទូទៅក្នុងរង្វង់រាជរដ្ឋាភិបាល ឬក្រសួងស្ថាប័ន និងចំពោះសំណុំរឿងទាំងឡាយដែលនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័នបានប្រគល់ឱ្យពិនិត្យ។ ភារកិច្ចផ្តល់យោបល់នេះមិនផ្តល់សិទ្ធិឱ្យខុទ្ទកាល័យបំពេញការងារជំនួសក្រសួង ស្ថាប័ន ឬអង្គភាពមានសមត្ថកិច្ចនៅក្នុងក្រសួង ស្ថាប័ន ឬរដ្ឋលេខាធិការដ្ឋានឡើយ (៣) ផ្សព្វផ្សាយអំពីសកម្មភាព គោលដៅ និងការតម្រង់ទិសផ្សេងៗរបស់ថ្នាក់ដឹកនាំ (៤) រៀបចំកាលវិភាគរបស់នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន ព្រមទាំងសម្របសម្រួលការអនុវត្តការងារ ឱ្យស្របតាមកាលវិភាគដែលបានកំណត់ (៥) សម្របសម្រួលការរៀបចំសម័យប្រជុំការងាររបស់រាជរដ្ឋាភិបាល អន្តរក្រសួង ឬក្រសួង ស្ថាប័ន (៦) បញ្ជូនបទបញ្ជានាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័នដល់ក្រសួង ស្ថាប័នចំណុះរាជរដ្ឋាភិបាល ឬអង្គភាពទាំងឡាយក្នុងក្រសួង ឬរដ្ឋលេខាធិការដ្ឋាន ផ្អែកលើកម្រិតនៃសមត្ថកិច្ចរបស់ថ្នាក់ដឹកនាំនីមួយៗ (៧) តាមដាន និងសម្របសម្រួលសកម្មភាពផ្សេងៗរបស់រាជរដ្ឋាភិបាល ក្រសួង ឬរដ្ឋលេខាធិការដ្ឋានដើម្បីសម្រួលការងារឱ្យមានប្រសិទ្ធិភាព (៨) តាមដានការអនុវត្តបញ្ជារបស់នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័នក្នុងរង្វង់សមត្ថកិច្ច

[8] យោងមាត្រា៩ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល

នីមួយៗ (៩) បំពេញការងារផ្សេងៗទៀតតាមការណែនាំរបស់ថ្នាក់ដឹកនាំសាមី[9]។

## ១.២. អគ្គនាយកដ្ឋានកិច្ចការទូទៅ

អគ្គនាយកដ្ឋានកិច្ចការទូទៅ ជាអង្គភាពមួយស្ថិតនៅក្រោមចំណុះក្រសួងរ៉ែ និងថាមពលក្នុងការបំពេញតួនាទីជាសេនាធិការឱ្យក្រសួងរ៉ែ និងថាមពលដែលមានបេសកកម្មដឹកនាំលើការងាររដ្ឋបាល និងព័ត៌មានវិទ្យា បុគ្គលិក គណនេយ្យ និងហិរញ្ញវត្ថុ ផែនការ ថវិកា នីតិកម្ម សហប្រតិបត្តិការ និងកិច្ចការអាស៊ាន និងសម្របសម្រួលការងាររបស់មន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត។

អគ្គនាយកដ្ឋានកិច្ចការទូទៅមានភារកិច្ចដូចជា៖ (១) គ្រប់គ្រង និងសម្របសម្រួលរាល់សកម្មភាពរដ្ឋបាលរបស់ក្រសួង នៅថ្នាក់ជាតិ និងរវាងថ្នាក់ជាតិ និងអង្គភាពថ្នាក់ក្រោមជាតិ និងអង្គភាពដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងរ៉ែ និងថាមពល (២) រៀបចំ និងគ្រប់គ្រងបណ្តាញព័ត៌មានវិទ្យា និងគេហទំព័ររបស់ក្រសួងរ៉ែ និងថាមពល (៣) រៀបចំ និងគ្រប់គ្រងរាល់ការងារទាក់ទងថវិកា គណនេយ្យ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងរ៉ែ និងថាមពល (៤) គ្រប់គ្រងការកត់ត្រាចំណូលមិនមែនសារពើពន្ធរបស់ក្រសួងរ៉ែ និងថាមពល (៥) រៀបចំ និងគ្រប់គ្រងរាល់ការងារទាក់ទងនឹងមន្ត្រីរាជការ (៦) សហការពិនិត្យ និងផ្តល់យោបល់ និងការពារផលប្រយោជន៍ក្រសួងរ៉ែ និងថាមពលតាមផ្លូវច្បាប់ (៧) សហការសម្របសម្រួល និងគ្រប់គ្រងការងារទាក់ទងនឹងកិច្ចសហប្រតិបត្តិការ និងកិច្ចការអាស៊ានរបស់ក្រសួងរ៉ែ និងថាមពល (៨) រៀបចំផែនការ និងបូកសរុបលទ្ធផលការងាររបស់ក្រសួងរ៉ែ និងថាមពល (៩) បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់ថ្នាក់ដឹកនាំក្រសួងរ៉ែ និងថាមពល[10]។

អគ្គនាយកដ្ឋានកិច្ចការទូទៅ មាននាយកដ្ឋានក្រោមចំណុះចំនួន ០៦ ដែលរួមមាន នាយកដ្ឋានរដ្ឋបាល និងព័ត៌មានវិទ្យា នាយកដ្ឋានបុគ្គលិក នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នាយកដ្ឋានផែនការ នាយកដ្ឋាននីតិកម្ម និងនាយកដ្ឋានសហប្រតិបត្តិការ និងកិច្ចការអាស៊ាន[11]។

### ១.២.១. នាយកដ្ឋានរដ្ឋបាល និងព័ត៌មានវិទ្យា

បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅលើការងាររដ្ឋបាល និងព័ត៌មានវិទ្យាដែលមានភារកិច្ចដូចជា៖ (១) សម្របសម្រួលសកម្មភាពរដ្ឋបាលរបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាលជាមួយអង្គភាពថ្នាក់ក្រោមជាតិ និងអង្គភាពដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស (២) ដំណើរការ

[9] យោងតាមមាត្រា៧ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន

[10] យោងមាត្រា១០ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល

[11] យោងមាត្រា១១ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល

ច្រកចេញចូលតែមួយដើម្បីគ្រប់គ្រងការធ្វើចរាចររាល់លិខិត និងឯកសារនានា (៣) សហការរៀបចំគ្រប់គ្រង និងដំណើរការផ្នែកបច្ចេកទេសនូវគេហទំព័រ និងបណ្ដាញទំនាក់ទំនងសង្គមរបស់ក្រសួងសម្រាប់ដំណើរការ ការងាររបស់ក្រសួង (៤) ធានាប្រសិទ្ធិភាព សុវត្ថិភាពរដ្ឋបាល និងចូលរួមសម្របសម្រួលរៀបចំការងារសង្គម របស់ក្រសួង (៥) រៀបចំទុកដាក់ឯកសារ និងរៀបចំសម្របសម្រួលការងារពិធីការរបស់ក្រសួង (៦) គ្រប់គ្រង យានយន្តនិងទោចក្រយានយន្តគ្រប់ប្រភេទរបស់ក្រសួង ព្រមទាំងធ្វើផែនការតម្រូវការប្រេងឥន្ធនៈ និងលើក គម្រោងបែងចែកការប្រើប្រាស់ប្រេងឥន្ធនៈ និងគ្រឿងបន្លាស់ (៧) ទទួល និងលើកគម្រោងបែងចែកសម្ភារៈ បរិក្ខារជូនអង្គភាពក្រោមចំណុះក្រសួង (៨) រៀបចំ គ្រប់គ្រងដំណើរការ និងថែរក្សាបណ្ដាញប្រព័ន្ធព័ត៌មានវិទ្យា របស់ក្រសួង (៩) បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន[12]។

### ១.២.២. នាយកដ្ឋានបុគ្គលិក

បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅ លើការងារបុគ្គលិក ដែលមានភារកិច្ចដូចជា៖ (១) រៀបចំ និងគ្រប់គ្រងផ្នែករដ្ឋបាលមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈមិនមែនមន្ត្រីរាជការរបស់ក្រសួង (២) រៀបចំលិខិតបទដ្ឋាន និងលិខិតរដ្ឋបាលសម្រាប់គ្រប់គ្រងអាជីព (៣) គ្រប់គ្រងសំណុំលិខិតជីវប្រវត្តិមន្ត្រីរាជការ ស្ថិតក្នុងក្របខណ្ឌមុខងារសាធារណៈ (៤) រៀបចំធនធានមនុស្សរបស់ក្រសួងទៅតាមជំនាញឯកទេស (៥) លើកគម្រោងវាយតម្លៃតម្រូវការតែងតាំង ដំឡើងថ្នាក់ ឋានន្តរស័ក្តិ ការផ្លាស់ប្ដូរប្រភេទក្របខណ្ឌ ផ្ទេរប្ដូរ និង សម្រួលភារកិច្ចមន្ត្រីរាជការ (៦) លើកគម្រោងវាយតម្លៃ និងលើកសំណើដើម្បីផ្ដល់ប័ណ្ណសរសើរ និងគ្រឿង ឥស្សរិយយសផ្សេងៗជូនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួង និងជំនាញការបរទេសប្រចាំក្រសួងដែលមាន ស្នាដៃល្អ (៧) រៀបចំស្ថិតិមន្ត្រីរាជការ និងតារាងព័ត៌មានប្រតិបត្តិ (៨) រៀបចំការងារបៀវត្សពលកម្ម ប្រាក់កម្រៃ និងរបបឧបត្ថម្ភសន្តិសុខសង្គម (៩) រៀបចំ និងអនុវត្តកម្មវិធីបណ្ដុះបណ្ដាលដោយធ្វើការវាយតម្លៃលើតម្រូវការ និងលើកគម្រោងបណ្ដុះបណ្ដាលមន្ត្រីរាជការរយៈពេលខ្លី មធ្យម និងវែងតាមតម្រូវការជាក់ស្ដែងរបស់ក្រសួង (១០) បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន[13]។

### ១.២.៣. នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ

បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅ លើការងារគណនេយ្យ និងហិរញ្ញវត្ថុដែល មានភារកិច្ចដូចជា៖ (១) លើកគម្រោងកម្មវិធីនៃការអនុវត្តចំណូលចំណាយថវិកាក្រសួងប្រចាំត្រីមាស (២) គ្រប់គ្រងការអនុវត្តមាតិកាថវិកាប្រចាំឆ្នាំរបស់ក្រសួងស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងហិរញ្ញវត្ថុ (៣) រៀបចំ គ្រប់គ្រង ប្រព័ន្ធព័ត៌មានវិទ្យានៃសកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី (៤) ផ្ទៀងផ្ទាត់ និងបូកសរុបការអនុវត្តថវិកា

[12] យោងប្រការ៩ នៃប្រកាសស្ដីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានកិច្ចការទូទៅ

[13] យោងប្រការ១២ នៃប្រកាសស្ដីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានកិច្ចការទូទៅ

ប្រចាំឆ្នាំរបស់ក្រសួង (៥) តាមដានការគ្រប់គ្រងគណនីពិសេស (៦) ពិនិត្យ និងសម្របសម្រួលដោះស្រាយរាល់ការចំណាយរបស់ក្រសួង (៧) តាមដាន កត់ត្រា និងបូកសរុបការប្រមូលចំណូលប្រចាំឆ្នាំរបស់ក្រសួង (៨) ចងក្រងធ្វើបច្ចុប្បន្នភាព និងផ្ទៀងផ្ទាត់បញ្ជីចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងបញ្ជីសារពើភ័ណ្ឌផ្សេងៗ (៩) សម្របសម្រួល និងលើកស្នើធ្វើការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តរបស់ក្រសួង (១០) បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន[14]។

### ១.២.៤. នាយកដ្ឋានផែនការ

បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅ លើការងារផែនការ គម្រោងថវិកា និងបូកសរុប ដែលមានភារកិច្ចដូចជា៖ (១) សហការ សម្របសម្រួល និងផ្តល់ធាតុចូលជូនស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្នុងការងាររៀបចំចងក្រងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍជាតិនានា (២) សហការ និងសម្របសម្រួលជាមួយនឹងអង្គភាពពាក់ព័ន្ធ ក្នុងការងាររៀបចំគោលនយោបាយផែនការសកម្មភាព និងធ្វើបច្ចុប្បន្នភាពផែនការអភិវឌ្ឍពាក់ព័ន្ធនឹងវិស័យរបស់ក្រសួង (៣) តាមដានការអនុវត្តតាមផែនការសកម្មភាព និងផែនការអភិវឌ្ឍរបស់ក្រសួង (៤) សហការរៀបចំ ចងក្រង គ្រប់គ្រង ធ្វើបច្ចុប្បន្នភាព បោះពុម្ព និងផ្សព្វផ្សាយស្ថិតិពាក់ព័ន្ធ និងវិស័យរបស់ក្រសួង (៥) បូកសរុប និងធ្វើរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ៩ ខែ និងប្រចាំឆ្នាំស្តីពីសកម្មភាព និងលទ្ធផលការងាររបស់ក្រសួង (៦) រៀបចំចងក្រងឯកសារជាសៀវភៅ កម្រងរូបភាព និងឯកសារភាពយន្ត អំពីសកម្មភាព និងលទ្ធផលការងាររបស់ក្រសួង (៧) រៀបចំ សម្របសម្រួល និងបូកសរុបគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់ក្រសួង (៨) សហការ និងសម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីរៀបចំសំណើវិភាជថវិកា តាមមាតិកាកម្មវិធី និងមាតិកាសេដ្ឋកិច្ចជូនគ្រប់អង្គភាពថវិកាចំណុះក្រសួង (៩) ជំរុញ តាមដាន និងវាយតម្លៃតាមមាតិកាកម្មវិធីស្តីពីការអនុវត្តផែនការថវិការបស់គ្រប់អង្គភាពថវិកាចំណុះក្រសួង (១០) បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន[15]។

### ១.២.៥. នាយកដ្ឋាននីតិកម្ម

បំពេញមុខងារជាសេនាធិកាឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅ លើការងារនីតិកម្ម ដែលមានភារកិច្ចដូចជា៖ (១) ចូលរួមពិគ្រោះយោបល់ជាមួយអគ្គនាយកដ្ឋានជំនាញនូវរាល់ការរៀបចំ និងតាក់តែងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធវិស័យរ៉ែ និងថាមពល រួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម និងអគ្គិសនីក្នុងក្រសួងព្រមទាំងជាមួយនឹងស្ថាប័នពាក់ព័ន្ធ (២) ជាទីប្រឹក្សាផ្ទាល់ដល់ថ្នាក់ដឹកនាំក្រសួង (៣) ទទួលបន្ទុកត្រួតពិនិត្យលើទម្រង់ និងគតិច្បាប់នូវរាល់លិខិតបទដ្ឋានគតិយុត្តនានា ដែលអគ្គនាយកដ្ឋានជំនាញបាន

[14] យោងប្រការ១៥ នៃប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានកិច្ចការទូទៅ

[15] យោងប្រការ១៨ នៃប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានកិច្ចការទូទៅ

រៀបចំ និងតាក់តែងមុននឹងដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច (៤) សម្របសម្រួល និងរៀបចំកិច្ចប្រជុំក្រុម-ការងារ កិច្ចប្រជុំអន្តរក្រសួង ក្នុងដំណើរការនៃការឆ្លងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនានា (៥) ផ្តល់យោបល់លើការអនុវត្តវិធានការច្បាប់នូវរាល់ភាពមិនអនុលោម និងបទល្មើសផ្សេងៗក្នុងវិស័យរ៉ែ និងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិល រួមទាំងវិទ្យុសកម្មនិងអគ្គិសនី (៦) ការពារតាមផ្លូវច្បាប់នូវសេចក្តីសម្រេច សកម្មភាព ការអនុវត្តរបស់ក្រសួង និងសម្របសម្រួលដំណើរការដោះស្រាយវិវាទផ្សេងៗរវាងក្រសួងជាមួយភាគីពាក់ព័ន្ធ (៧) ធ្វើការសិក្សាវាយតម្លៃ និងតាមដានលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (៨) រៀបចំសិក្ខាសាលាពិគ្រោះយោបល់ និងសិក្ខាសាលាផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា (៩) ស្រាវជ្រាវ វិភាគ ចងក្រង ធ្វើបច្ចុប្បន្នភាព តម្កល់ឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិ អន្តរជាតិក្នុងវិស័យរ៉ែ និងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម និងអគ្គិសនី (១០) ទទួលបន្ទុកជាលេខាធិការដ្ឋាន នៃក្រុមការងារពង្រឹងយន្តការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហ-មជ្ឈការ (១១) បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន[16]។

### ១.២.៦. នាយកដ្ឋានសហប្រតិបត្តិការ និងកិច្ចការអាស៊ាន

ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់ដោយអគ្គនាយកដ្ឋានកិច្ចការទូទៅ ដែលមានភារកិច្ចពាក់ព័ន្ធការងារសហប្រតិបត្តិការលើវិស័យរ៉ែ និងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម និងអគ្គិសនីដូចជា៖ (១) ចូលរួមសិក្សាវិភាគ និងតស៊ូមតិក្នុងក្របខណ្ឌសហប្រតិបត្តិការតំបន់ និងអន្តរតំបន់ ដើម្បីការពារផលប្រយោជន៍ជាតិ (២) សហការ និងសម្របសម្រួលជាមួយអគ្គនាយកដ្ឋានជំនាញ និងស្ថាប័នពាក់ព័ន្ធក្នុងការជំរុញរៀបចំលើកគម្រោងសហប្រតិបត្តិការទ្វេភាគី ពហុភាគី អន្តរជាតិ និងជំរុញអនុវត្តន៍រាល់គំនិតផ្តួចផ្តើមនិងគម្រោងកម្មវិធីតំបន់ អន្តរតំបន់ (៣) តាមដាន បូកសរុប និងផ្សព្វផ្សាយពីលទ្ធផលនៃការអនុវត្តគម្រោងកម្មវិធីតំបន់ អន្តរតំបន់ (៤) រៀបចំបដិសណ្ឋារកិច្ច សំណុំលិខិតឯកសារផ្សេងៗ និងគ្រប់គ្រងគម្រោងចំណាយ សម្រាប់កិច្ចដំណើរការសហប្រតិបត្តិការ (៥) ចូលរួមក្នុងសកម្មភាពសហប្រតិបត្តិការលើវិស័យជំនាញផ្សេងៗ (៦) ចងក្រង គ្រប់គ្រង និងថែរក្សារាល់ឯកសារសហប្រតិបត្តិការផ្សេងៗ (៧) ដើរតួជាលេខាធិការដ្ឋានជូនថ្នាក់ដឹកនាំទទួលបន្ទុកអ្នកនាំពាក្យក្រសួង (៨) សហការរៀបចំ និងធ្វើបច្ចុប្បន្នភាពនូវអត្ថបទសកម្មភាពការងាររបស់ក្រសួង ដើម្បីផ្សព្វផ្សាយក្នុងគេហទំព័របណ្តាញទំនាក់ទំនងសង្គម និងការងារទំនាក់ទំនងសាធារណៈ (៩) បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន[17]។

[16] យោងប្រការ២១ នៃប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានកិច្ចការទូទៅ

[17] យោងប្រការ២៤ នៃប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានកិច្ចការទូទៅ

## ១.៣. អគ្គនាយកដ្ឋានធនធានរ៉ែ

អគ្គនាយកដ្ឋានធនធានរ៉ែ បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែ និងថាមពល លើបេសកកម្ម គ្រប់គ្រងការអភិវឌ្ឍ និងការធ្វើអាជីវកម្មធនធានរ៉ែ និងជំរុញការប្រើប្រាស់ ធនធានរ៉ែ ព័ត៌មានភូគព្ភសាស្ត្រ និង ធនធានរ៉ែ ដើម្បីចូលរួមចំណែកក្នុងកិច្ចអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដែលមាន ភារកិច្ចដូចជា៖ (១) រៀបចំ និងចងក្រងគោលនយោបាយ ច្បាប់ បទប្បញ្ញត្តិ និងផែនការយុទ្ធសាស្ត្រនានា ដើម្បី ជំរុញអភិវឌ្ឍវិស័យរ៉ែ (២) ជំរុញការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍបច្ចេកវិទ្យា ផ្នែកភូគព្ភសាស្ត្រ ការសិក្សាស្វែង រុករករ៉ែ និងការវាយតម្លៃទំហំសក្តានុពលធនធានរ៉ែ (៣) ជំរុញការកសាងសមត្ថភាពធនធានមនុស្ស និងការផ្ទេរ បច្ចេកវិទ្យាក្នុងវិស័យរ៉ែ (៤) ជំរុញការអភិវឌ្ឍ ការធ្វើអាជីវកម្ម និងការប្រើប្រាស់ធនធានរ៉ែ បម្រើឱ្យវិស័យសេដ្ឋកិច្ច និងសង្គម (៥) ជំរុញ និងគ្រប់គ្រងការវិនិយោគឯកជនក្នុងវិស័យធនធានរ៉ែ ចាប់ពីការសិក្សាស្វែងរុករករហូត ដល់ការធ្វើអាជីវកម្ម ការបិទការដ្ឋាន និងស្តារបរិស្ថានឡើងវិញ (៦) លើកកម្ពស់ការការពារគុណភាពបរិស្ថាន និងសុខុមាលភាពសង្គមនៅក្នុងសកម្មភាពអភិវឌ្ឍវិស័យរ៉ែ (៧) ធានាសុចរិតភាព ប្រសិទ្ធិភាព និងគណនេយ្យ ភាព ក្នុងការធ្វើអាជីវកម្ម និងប្រើប្រាស់ធនធានរ៉ែ (៨) កៀរគរគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធ ពាក់ព័ន្ធ និងវិស័យធនធានរ៉ែ (៩) គ្រប់គ្រងការនាំចេញ នាំចូលធនធានរ៉ែ និងផលិតផលរ៉ែ។[18]

អគ្គនាយកដ្ឋានធនធានរ៉ែ មាននាយកដ្ឋានក្រោមចំណុះចំនួន ០៦ ដែលរួមមាន នាយកដ្ឋានភូគព្ភ-សាស្ត្ររ៉ែ នាយកដ្ឋានផែនការសេដ្ឋកិច្ចធនធានរ៉ែ នាយកដ្ឋានឧស្សាហកម្មអាជីវកម្មរ៉ែ នាយកដ្ឋានអាជីវកម្មរ៉ែ ខ្សាច់សំណង់ នាយកដ្ឋានអាជីវកម្មរ៉ែថ្មសំណង់ និងនាយកដ្ឋានត្រួតពិនិត្យប្រតិបត្តិការធនធានរ៉ែ[19]។

### ១.៣.១. នាយកដ្ឋានភូគព្ភសាស្ត្ររ៉ែ

បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានធនធានរ៉ែ លើការងារភូគព្ភសាស្ត្រ សិក្សាស្រាវជ្រាវ និង អភិវឌ្ឍបច្ចេកវិទ្យាផ្នែកភូគព្ភសាស្ត្រ និងគ្រប់គ្រងដំណើរការមន្ទីរពិសោធន៍ភូគព្ភសាស្ត្ររ៉ែ។ បន្ថែមពីនេះនាយកដ្ឋាន មានភារៈកិច្ចដូចជា៖ (១) រៀបចំសេចក្តីព្រាងបទប្បញ្ញត្តិនានាដែលទាក់ទងដល់ការសិក្សាស្រាវជ្រាវភូគព្ភ-សាស្ត្ររ៉ែ (២) អនុវត្តច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានដែលទាក់ទងដល់ការធ្វើសម្រង់ទិន្នន័យភូគព្ភសាស្ត្រ និងបុរេសនាធនធានរ៉ែ (៣) ធ្វើការសិក្សាភូគព្ភសាស្ត្រ រូបភូគព្ភសាស្ត្រ គីមីភូគព្ភសាស្ត្រ និងភូគព្ភសាស្ត្រផ្សេងៗ ទៀត (៤) សំយោគទិន្នន័យភូគព្ភសាស្ត្រ សម្រាប់បម្រើផលប្រយោជន៍បរិស្ថាន សង្គម ទេសចរណ៍ បុរាណវិទ្យា រៀបចំក្រុងនិងសំណង់ និងការអភិវឌ្ឍផ្សេងៗទៀត (៥) ធ្វើការសិក្សាស្រាវជ្រាវ វាយតម្លៃ ការបំពុល និងផលប៉ះពាល់ ផ្សេងៗពីប្រតិបត្តិការរ៉ែ ចំពោះបរិស្ថាន និងសង្គម (៦) គ្រប់គ្រង និងដំណើរការមន្ទីរពិសោធន៍ភូគព្ភសាស្ត្ររ៉ែ

[18] យោងមាត្រា១៣ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល

[19] យោងមាត្រា១៤ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល

ដើម្បីវិភាគ កំណត់អត្តសញ្ញាណវាយតម្លៃលក្ខណៈមេកានិច-រូបសាស្ត្រ-គីមីសាស្ត្ររ៉ែ និងខនិជរ៉ែ និងវាយតម្លៃអត្រារ៉ែ (៧) គ្រប់គ្រង និងថែរក្សាសំណាក/គំរូភូគព្ភសាស្ត្រ-រ៉ែ និងប្រេងកាត-ឧស្ម័ន (៨) ប្រមូល រៀបចំ ចងក្រងរក្សាទុកបណ្ណ-សារដ្ឋានភូគព្ភសាស្ត្រ គ្រប់គ្រងការប្រើប្រាស់ និងការដោះដូរទិន្នន័យ ព័ត៌មានភូគព្ភសាស្ត្រ និងធនធានរ៉ែ (៩) ជំរុញការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍធនធានមនុស្សផ្នែកភូគព្ភសាស្ត្រ (១០) គ្រប់គ្រងការប្រើប្រាស់ និងថែទាំ គ្រឿងចក្រ សម្ភារ ឧបករណ៍ និងបរិក្ខារ សម្រាប់បម្រើឱ្យការសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រ និងស្វែងរុករករ៉ែ (១១) ធ្វើសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិលើការងារជំនាញរបស់នាយកដ្ឋាន[20]។

### ១.៣.២. នាយកដ្ឋានផែនការសេដ្ឋកិច្ចធនធានរ៉ែ

បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានធនធានរ៉ែ លើការងាររៀបចំផែនការយុទ្ធសាស្ត្រ ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែ ការជំរុញលើកកម្ពស់ផលសេដ្ឋកិច្ចសង្គម និងការងារសហ-ប្រតិបត្តិការក្នុងវិស័យរ៉ែ។ បន្ថែមពីនេះនាយកដ្ឋានមានភារៈកិច្ចដូចជា៖ (១) ធ្វើការវិភាគ និងរៀបចំគោល-នយោបាយ យុទ្ធសាស្ត្រ និងផែនការសេដ្ឋកិច្ចធនធានរ៉ែ (២) ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធផលនៃការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ និងផែនការសេដ្ឋកិច្ចធនធានរ៉ែ (៣) ជំរុញ និងសម្របសម្រួលឱ្យមានដំណើរការអភិបាលកិច្ចល្អក្នុងវិស័យធនធានរ៉ែ ការងារវិមជ្ឈការ និងភាពជាដៃគូរក្នុងការងារពហុភាគីរវាងវិស័យសាធារណៈ ឯកជន និងសង្គមស៊ីវិល (៤) ជំរុញ និងសម្របសម្រួលកម្មវិធីសហប្រតិបត្តិការជាតិ និងអន្តរជាតិលើវិស័យធនធានរ៉ែ និងអនុវត្តកម្មវិធីផ្សព្វផ្សាយជំរុញទាក់ទាញការវិនិយោគក្នុងវិស័យធនធានរ៉ែនៅកម្ពុជា (៥) លើកកម្ពស់លទ្ធភាពទទួលបាន និងឱកាសសេដ្ឋកិច្ចរបស់សហគមន៍មូលដ្ឋាននៅក្នុងតំបន់មូលដ្ឋានប្រតិបត្តិការធនធានរ៉ែ (៦) ត្រួតពិនិត្យវាយតម្លៃប្រសិទ្ធផលនៃការសម្រេចបានគោលដៅ បរិស្ថាន សង្គមធនធានរ៉ែ (៧) គ្រប់គ្រង កត់ត្រា តាមដាន និងបូកសរុបចំណូលផ្នែកមិនមែនសារពើពន្ធធនធានរ៉ែ និង (៨) ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបការងារអនុវត្តគម្រោងថវិកាកម្មវិធីរបស់អគ្គនាយកដ្ឋានធនធានរ៉ែ[21]។

### ១.៣.៣. នាយកដ្ឋានឧស្សាហកម្មអាជីវកម្មធនធានរ៉ែ

បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានធនធានរ៉ែ លើការងារគ្រប់គ្រងប្រតិបត្តិការស្វែងរុករក និងអាជីវកម្មធនធានរ៉ែ។ បន្ថែមពីនេះនាយកដ្ឋានមានភារៈកិច្ចដូចជា៖ (១) រៀបចំ វាយតម្លៃ និងដំណើរការផ្តល់ពន្យារបន្ត ផ្ទេរសិទ្ធិ ព្យួរ ដកហូត និងបញ្ចប់អាជ្ញាបណ្ណធនធានរ៉ែ សម្រាប់ប្រតិបត្តិការស្វែងរុករក និងការធ្វើអាជីវកម្មធនធានរ៉ែ ឧស្សាហកម្ម និងប្រភេទរ៉ែផ្សេងៗទៀតលើកលែងតែរ៉ែសំណង់ (២) វាយតម្លៃ និងផ្តល់មតិលើសេចក្តីព្រាងរបាយការណ៍ផលប៉ះពាល់បរិស្ថាន សង្គម និងផែនការការពារ និងស្តារបរិស្ថាននៃគម្រោង

[20] យោងប្រការ៩ នៃប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានធនធានរ៉ែ

[21] យោងប្រការ១២ នៃប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានធនធានរ៉ែ

ប្រតិបត្តិការធនធានរ៉ែ (៣) ជំរុញភាពអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងប្រតិបត្តិការធនធានរ៉ែ (៤) ជំរុញប្រសិទ្ធិភាពក្នុងការកៀរគរចំណូលមិនមែនសារពើពន្ធ និងភាពអនុលោមក្នុងការបំពេញកាតព្វកិច្ចហិរញ្ញវត្ថុក្នុងប្រតិបត្តិការធនធានរ៉ែ (៥) ជំរុញការរកឃើញជម្រករ៉ែថ្មីៗ និងការវាយតម្លៃទំហំសក្តានុពលធនធានរ៉ែ (៦) គ្រប់គ្រងប្រតិបត្តិការធនធានរ៉ែចាប់ពីការងារស្វែងរុករក ការអភិវឌ្ឍអណ្តូងរ៉ែ ឬការដ្ឋានរ៉ែ ការធ្វើប្រព្រឹត្តិកម្មរ៉ែ ការបន្សុទ្ធរ៉ែ ការចម្រាញ់រ៉ែ ការធ្វើពាណិជ្ជកម្មរ៉ែ និងការបិទការដ្ឋានរ៉ែ (៧) គ្រប់គ្រង និងជំរុញការងារស្តារឡើងវិញ ក្រោមប្រតិបត្តិការធនធានរ៉ែ (៨) ធ្វើសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិលើការងារជំនាញរបស់នាយកដ្ឋាន[22]។

### ១.៣.៤. នាយកដ្ឋានអាជីវកម្មរ៉ែខ្សាច់សំណង់

បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានធនធានរ៉ែ លើការងារគ្រប់គ្រងអាជីវកម្មរ៉ែខ្សាច់ ក្រួស និងល្បាប់ខ្សាច់ ភក់ ពីប្រភពសមុទ្រ ទន្លេ ស្ទឹង ព្រែក បឹង និងអូរសំដៅបម្រើឱ្យវិស័យសំណង់។ បន្ថែមពីនេះ នាយកដ្ឋានមានភារៈកិច្ចដូចជា៖ (១) រៀបចំ វាយតម្លៃ និងដំណើរការផ្តល់ ពន្យារបន្ត ផ្ទេរសិទ្ធិ ព្យួរ ដកហូត និងបញ្ចប់អាជ្ញាបណ្ណធនធានរ៉ែ សម្រាប់ប្រតិបត្តិការអាជីវកម្មរ៉ែខ្សាច់ ក្រួស និងល្បាប់ខ្សាច់ភក់ ពីប្រភពទន្លេ ស្ទឹង ព្រែក បឹង អូរ និងសមុទ្រ សំដៅបម្រើឱ្យវិស័យសំណង់ (២) វាយតម្លៃ និងផ្តល់មតិលើសេចក្តីព្រាងរបាយការណ៍ផលប៉ះពាល់បរិស្ថាន សង្គម ផែនការការពារ និងស្តារបរិស្ថាននៃគម្រោងប្រតិបត្តិការរ៉ែ (៣) ជំរុញភាពអនុលោមច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងប្រតិបត្តិការធនធានរ៉ែ (៤) ជំរុញប្រសិទ្ធិភាពនៃការគ្រប់គ្រង និងការអនុវត្តផែនការអភិវឌ្ឍអាជីវកម្មរ៉ែខ្សាច់ ក្រួស និងល្បាប់ខ្សាច់ភក់សម្រាប់គោលដៅផ្គត់ផ្គង់វិស័យសំណង់ (៥) ជំរុញប្រសិទ្ធិភាពក្នុងការកៀរគរចំណូលមិនមែនសារពើពន្ធ និងភាពអនុលោមក្នុងការបំពេញកាតព្វកិច្ចហិរញ្ញវត្ថុក្នុងអាជីវកម្មរ៉ែខ្សាច់ ក្រួស និងល្បាប់ខ្សាច់ភក់សម្រាប់គោលដៅផ្គត់ផ្គង់វិស័យសំណង់ (៦) ធ្វើការវាយតម្លៃទំហំសក្តានុពលរ៉ែខ្សាច់ ក្រួស និងល្បាប់ខ្សាច់ភក់ និងរៀបចំផែនការប្រើប្រាស់ធនធានរ៉ែក្នុងដែនអាជ្ញាបណ្ណ (៧) គ្រប់គ្រងការធ្វើអាជីវកម្មរ៉ែខ្សាច់ ក្រួស និងល្បាប់ខ្សាច់ភក់ ការធ្វើពាណិជ្ជកម្មធនធានរ៉ែ និងផលិតផលរ៉ែ (៨) គ្រប់គ្រងការបិទការដ្ឋានអាជីវកម្មរ៉ែ និងជំរុញការស្តារឡើងវិញក្រោយប្រតិបត្តិការធនធានរ៉ែ[23]។

### ១.៣.៥. នាយកដ្ឋានអាជីវកម្មរ៉ែថ្មសំណង់

បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានធនធានរ៉ែ លើការងារគ្រប់គ្រងអាជីវកម្មរ៉ែថ្មសំណង់ ថ្មអារ ឡាតេរីត ខ្សាច់បក និងអាចម៍ដី។ បន្ថែមពីនេះនាយកដ្ឋានមានភារៈកិច្ចដូចជា៖ (១) រៀបចំ វាយតម្លៃ និងដំណើរការផ្តល់ ពន្យារបន្ត ផ្ទេរសិទ្ធិ ព្យួរ ដកហូត និងបញ្ចប់អាជ្ញាបណ្ណធនធានរ៉ែ សម្រាប់ប្រតិបត្តិការអាជីវកម្ម

[22] យោងប្រការ១៥ នៃប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានធនធានរ៉ែ

[23] យោងប្រការ១៨ នៃប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានធនធានរ៉ែ

រ៉ែថ្មសំណង់ ថ្មអារ ឡាតេរីត ខ្សាច់បក និងអាចម៍ដីសម្រាប់គោលដៅផ្គត់ផ្គង់វិស័យសំណង់ (២) វាយតម្លៃ និងផ្តល់មតិលើសេចក្តីព្រាងរបាយការណ៍ផលប៉ះពាល់បរិស្ថាន សង្គម ផែនការការពារ និងស្តារបរិស្ថាននៃគម្រោងប្រតិបត្តិការរ៉ែ (៣) ជំរុញភាពអនុលោមច្បាប់ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងប្រតិបត្តិការធនធានរ៉ែ (៤) ជំរុញប្រសិទ្ធិភាពនៃការគ្រប់គ្រង និងការអនុវត្តផែនការអភិវឌ្ឍអាជីវកម្មរ៉ែថ្មសំណង់ ថ្មអារ ឡាតេរីត ខ្សាច់បក និងអាចម៍ដីសម្រាប់គោលដៅផ្គត់ផ្គង់វិស័យសំណង់ (៥) ជំរុញប្រសិទ្ធិភាពក្នុងការកៀរគរចំណូលមិនមែនសារពើពន្ធ និងភាពអនុលោមក្នុងការបំពេញកាតព្វកិច្ចហិរញ្ញវត្ថុក្នុងអាជីវកម្មរ៉ែថ្មសំណង់ (៦) ធ្វើការវាយតម្លៃទំហំសក្តានុពលរ៉ែថ្មសំណង់ ថ្មអារ ឡាតេរីត ខ្សាច់បក និងអាចម៍ដី ការធ្វើពាណិជ្ជកម្មធនធានរ៉ែ និងផលិតផលរ៉ែ (៧) គ្រប់គ្រងការបិទការដ្ឋានអាជីវកម្មរ៉ែ និងជំរុញការស្តារឡើងវិញ ក្រោយប្រតិបត្តិការធនធានរ៉ែ[24]។

### ១.៣.៦. នាយកដ្ឋានត្រួតពិនិត្យប្រតិបត្តិការធនធានរ៉ែ

បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានធនធានរ៉ែ លើការងារត្រួតពិនិត្យ និងជំរុញអនុលោមភាពស្របតាមវិធានបច្ចេកទេស សុវត្ថិភាព សុខភាព និងលក្ខខណ្ឌការងារ ព្រមទាំងការការពារបរិស្ថាន និងសុខុមាលភាពសង្គមនៅក្នុងប្រតិបត្តិការធនធានរ៉ែ។ បន្ថែមពីនេះនាយកដ្ឋានមានភារៈកិច្ចដូចជា៖ (១) កំណត់បទដ្ឋានសុវត្ថិភាព សុខភាព និងលក្ខខណ្ឌការងារក្នុងប្រតិបត្តិការធនធានរ៉ែគ្រប់ប្រភេទ (២) កំណត់វិធានការការពារបរិស្ថាន និងសង្គម ក្នុងប្រតិបត្តិការធនធានរ៉ែគ្រប់ប្រភេទ (៣) ជំរុញអនុលោមភាពស្របតាមវិធានការបច្ចេកទេសសុវត្ថិភាព សុខភាព និងលក្ខខណ្ឌការងារ និងវិធានការការពារបរិស្ថាន និងសង្គម ក្នុងប្រតិបត្តិការធនធានរ៉ែ (៤) សម្របសម្រួល ដឹកនាំការត្រួតពិនិត្យភាពអនុលោមក្នុងប្រតិបត្តិការធនធានរ៉ែគ្រប់ប្រភេទ (៥) ជំរុញលុបបំបាត់ភាពអសកម្មក្នុងប្រតិបត្តិការធនធានរ៉ែ (៦) ចូលរួមសហការអនុវត្តវិធានការច្បាប់ និងនីតិវិធីតុលាការ (៧) ជំរុញលុបបំបាត់សកម្មភាពអត់ច្បាប់ និងអនាធិបតេយ្យក្នុងវិស័យរ៉ែ (៨) ធ្វើសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិលើការងារជំនាញរបស់នាយកដ្ឋាន[25]។

## ១.៤. អគ្គនាយកដ្ឋានថាមពល

អគ្គនាយកដ្ឋានថាមពលបំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែ និងថាមពលដែលមានបេសកកម្មគ្រប់គ្រងលើវិស័យថាមពល ផ្នែកបរិមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី។ អគ្គនាយកដ្ឋានថាមពលមានភារកិច្ចដូចជា៖ (១) រៀបចំ និងកំណត់គោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់ បទប្បញ្ញត្តិ និងស្តង់ដារ ក្នុងវិស័យថាមពលផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី (២) ជំរុញការកសាងសមត្ថភាពធនធានមនុស្ស និងការផ្ទេរបច្ចេកវិទ្យាក្នុងវិស័យថាមពល ផ្នែកបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម និងអគ្គិសនី (៣) ធ្វើ

[24] យោងប្រការ២១ នៃប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានធនធានរ៉ែ

[25] យោងប្រការ២៤ នៃប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានធនធានរ៉ែ

កិច្ចសហប្រតិបត្តិការក្នុងវិស័យថាមពល ផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម អគ្គិសនីក្នុងតំបន់ និងអន្តរជាតិ (៤) ជំរុញការវិនិយោគ និងការធ្វើពាណិជ្ជកម្មក្នុងវិស័យថាមពល (៥) គ្រប់គ្រងការអភិវឌ្ឍវិស័យថាមពល (៦) គ្រប់គ្រងកិច្ចការផ្នែកថាមពលវារីអគ្គិសនី (៧) គ្រប់គ្រងកិច្ចការផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្មរួមមានកិច្ចការសុវត្ថិភាព ការការពារសុវត្ថិភាព និងសហការលើការងារសន្តិសុខបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្មជាមួយស្ថាប័នពាក់ព័ន្ធ (៨) គ្រប់គ្រងកិច្ចការផ្នែកថាមពលកំដៅ និងចំហេះ (៩) គ្រប់គ្រងកិច្ចការផ្នែកថាមពលកកើតឡើងវិញ និងថាមពលផ្សេងទៀត (១០) គ្រប់គ្រងបច្ចេកទេស និងគោលនយោបាយអាជីវកម្មក្នុងវិស័យថាមពល[26]។

អគ្គនាយកដ្ឋានថាមពល មាននាយកដ្ឋានក្រោមចំណុះចំនួន ០៦ ដែលរួមមាន នាយកដ្ឋានអភិវឌ្ឍថាមពល នាយកដ្ឋានវារីអគ្គិសនី នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាបរមាណូ នាយកដ្ឋានថាមពលកំដៅ និងចំហេះ នាយកដ្ឋានថាមពលកកើតឡើងវិញ និងថាមពលផ្សេងទៀត និងនាយកដ្ឋានបច្ចេកវិទ្យាប្រេងកាត គាំទ្រកិច្ចប្រតិបត្តិការ និងសន្តិសុខថាមពល[27]។

### ១.៤.១.នាយកដ្ឋានអភិវឌ្ឍថាមពល

បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថាមពល លើការងារតាមដានស្ថានភាពនៃការផ្គត់ផ្គង់ថាមពល ប្រមូលព័ត៌មាន និងទិន្នន័យក្នុងវិស័យថាមពល សិក្សា និងរៀបចំផែនការអភិវឌ្ឍវិស័យថាមពល សិក្សា និងរៀបចំផែនការវិនិយោគ រៀបចំការងារត្រួតពិនិត្យ ចរចារ និងឯកសារសម្រេចអនុញ្ញាតឱ្យវិនិយោគក្នុងវិស័យថាមពល។ បន្ថែមពីនេះនាយកដ្ឋានមានភារកិច្ចដូចជា ៖ (១) រៀបចំច្បាប់ គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យថាមពល (២) គ្រប់គ្រងប្រព័ន្ធទិន្នន័យ និងព័ត៌មានវិស័យថាមពល ព្យាករណ៍តម្រូវការថាមពល និងវិភាគអំពីតុល្យភាពរវាងប្រភពថាមពលដែលមាន និងតម្រូវការថាមពល (៣) រៀបចំការសិក្សា និងការអនុម័តផែនការមេដើម្បីធ្វើជាផែនទីបង្ហាញផ្លូវក្នុងការអភិវឌ្ឍវិស័យថាមពល (៤) រៀបចំផែនការ និងកម្មវិធីវិនិយោគដើម្បីអភិវឌ្ឍគម្រោងនានាក្នុងផែនការមេ (៥) ជំរុញការវិនិយោគគម្រោង រៀបចំកិច្ចការជ្រើសរើសអ្នកវិនិយោគ និងរៀបចំគោលការណ៍អនុញ្ញាតឱ្យវិនិយោគសម្រាប់គម្រោងអភិវឌ្ឍនីមួយៗ (៦) ត្រួតពិនិត្យការអនុវត្តគម្រោងអភិវឌ្ឍក្នុងដំណាក់កាលសាងសង់ (៧) ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ និងការធ្វើពាណិជ្ជកម្មក្នុងតំបន់ និងអន្តរជាតិលើវិស័យថាមពល[28]។

[26] យោងមាត្រា១៦ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល

[27] យោងមាត្រា១៧ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល

[28] យោងប្រការ៩ នៃប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានថាមពល

### ១.៤.២ នាយកដ្ឋានវារីអគ្គិសនី

បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថាមពល លើការងារស្រាវជ្រាវបច្ចេកវិទ្យា ធ្វើសហប្រតិបត្តិការ រៀបចំគោលនយោបាយ ច្បាប់ ស្តង់ដារ ផែនការ បណ្តុះបណ្តាល និងតាមដាន ត្រួតពិនិត្យ ការអនុវត្តគម្រោងវិនិយោគក្នុងវិស័យថាមពលវារីអគ្គិសនី។ បន្ថែមពីនេះនាយកដ្ឋានមានភារកិច្ចដូចជា៖ (១) ចូលរួមរៀបចំ និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍវិស័យថាមពល ពាក់ព័ន្ធជាមួយនឹងផ្នែកវារីអគ្គិសនី (២) ស្រាវជ្រាវ និងតាមដានការវិវត្តនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងស្តង់ដារផ្នែកវារីអគ្គិសនី (៣) ប្រមូលផ្តុំ និងចងក្រងទិន្នន័យ និងព័ត៌មានផ្នែកវារីអគ្គិសនី រៀបចំស្ថិតិសក្តានុពលប្រភពវារីអគ្គិសនី និងកំណត់គម្រោងអាទិភាពផ្នែកវារីអគ្គិសនីដែលអាចបញ្ចូលក្នុងផែនការមេដើម្បីធ្វើការអភិវឌ្ឍ (៤) ចូលរួមផ្តល់យោបល់ក្នុងការរៀបចំផែនការមេ ចូលរួមរៀបចំផែនការ និងកម្មវិធីវិនិយោគប្រភពថាមពល (៥) ចូលរួមក្នុងការងារជំរុញការ វិនិយោគគម្រោង រៀបចំកិច្ចការជ្រើសរើសអ្នកវិនិយោគ និងរៀបចំគោលការណ៍អនុញ្ញាតឱ្យវិនិយោគសម្រាប់គម្រោងអភិវឌ្ឍផ្នែកវារីអគ្គិសនី (៦) ចូលរួមក្នុងការត្រួតពិនិត្យការសាងសង់ និងការប្រគល់ទទួលនៃគម្រោងផ្នែកវារីអគ្គិសនី (៧) ត្រួតពិនិត្យ និងតាមដានការអនុវត្តគម្រោងវារីអគ្គិសនីក្នុងដំណាក់កាលនៃការដំណើរការ (៨) ចូលរួមសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមរបស់គម្រោងវារីអគ្គិសនី និងការរៀបចំផែនការកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងសង្គម។ (៩) ត្រួតពិនិត្យតាមដានការអនុវត្តផែនការកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងសង្គមរបស់គម្រោងវារីអគ្គិសនីទាំងក្នុងដំណាក់កាលសាងសង់ និងទាំងក្នុងដំណាក់កាលដំណើរការ[29]។

### ១.៤.៣ នាយកដ្ឋានវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាបរមាណូ

បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថាមពល លើការងារស្រាវជ្រាវបច្ចេកវិទ្យា ធ្វើសហប្រតិបត្តិការ រៀបចំគោលនយោបាយច្បាប់ ស្តង់ដារ ផែនការ បណ្តុះបណ្តាល និងតាមដាន ត្រួតពិនិត្យ ការអនុវត្តគម្រោងវិនិយោគក្នុងផ្នែកថាមពលបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម។ បន្ថែមពីនេះនាយកដ្ឋានមានភារកិច្ចដូចជា៖ (១) រៀបចំ និងកំណត់គោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់ បទប្បញ្ញត្តិ ស្តង់ដារ និងសេចក្តីណែនាំក្នុងផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម (២) ចូលរួមសិក្សា និងរៀបចំផែនការអភិវឌ្ឍវិស័យថាមពលពាក់ព័ន្ធនឹងផ្នែកថាមពលបរមាណូ (៣) ស្រាវជ្រាវ និងអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម (៤) ជំរុញការវិនិយោគ និងចូលរួមអនុវត្តគម្រោងទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យាបរមាណូស៊ីវិល សម្រាប់បម្រើឱ្យគោលបំណងសន្តិភាព (៥) រៀបចំ និងកំណត់ស្តង់ដារសម្រាប់ការពារបុគ្គល សាធារណៈជន និងបរិស្ថាន

[29] យោងប្រការ១២ នៃប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានថាមពល

ឱ្យចៀសផុតពីលទ្ធភាពរងផលប៉ះពាល់អាក្រក់ពីវិទ្យុសកម្ម (៦) អនុវត្តមុខងារបញ្ញត្តករគ្រប់គ្រង ការផ្ដល់ កែសម្រួល ព្យួរ ឬដកហូតអាជ្ញាបណ្ណ ការយកកម្រៃអាជ្ញាបណ្ណ និងត្រួតពិនិត្យការផ្ដល់សេវាទាំងឡាយដែលពាក់ព័ន្ធនឹងផ្នែកបរមាណូស៊ីវិល និងវិទ្យុសកម្ម (៧) ធ្វើអធិការកិច្ច និងចាត់វិធានការឱ្យអនុវត្ត អនុលោមទៅតាមសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង បទប្បញ្ញត្តិ ស្តង់ដារ និងអាជ្ញាបណ្ណចំពោះសកម្មភាព និងហេដ្ឋានរចនាសម្ព័ន្ធទាក់ទងនឹងផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្មក្នុងគោលបំណងរក្សាសុវត្ថិភាព សន្តិសុខ និងការការពារសុវត្ថិភាព និងអនុវត្តកិច្ចការដទៃទៀតដែលចាំបាច់សម្រាប់ការពារប្រជាជន និងបរិស្ថាន ក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យចៀសផុតពីគ្រោះថ្នាក់បរមាណូស៊ីវិល និងវិទ្យុសកម្ម (៨) គ្រប់គ្រងសន្និធិប្រភពវិទ្យុសកម្មជាតិ (៩) ធ្វើសហប្រតិបត្តិការជាមួយនឹងស្ថាប័នជាតិ អន្តរជាតិ និងប្រទេសដទៃទៀតពាក់ព័ន្ធនឹងការងារសុវត្ថិភាព សន្តិសុខ និងការការពារសុវត្ថិភាពផ្នែកបរមាណូស៊ីវិល និងវិទ្យុសកម្ម[30]។

### ១.៤.៤ នាយកដ្ឋានថាមពលកំដៅ និងចំហេះ

បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថាមពល លើការងារស្រាវជ្រាវបច្ចេកវិទ្យា ធ្វើសហប្រតិបត្តិការ រៀបចំគោលនយោបាយ ច្បាប់ ស្តង់ដារ ផែនការ បណ្តុះបណ្តាល និងតាមដាន ត្រួតពិនិត្យ ការអនុវត្តគម្រោងវិនិយោគក្នុងវិស័យថាមពលកំដៅ និងចំហេះ។ បន្ថែមពីនេះនាយកដ្ឋានមានភារកិច្ចដូចជា៖ (១) ចូលរួមរៀបចំ និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍវិស័យថាមពល ពាក់ព័ន្ធជាមួយនឹងផ្នែកថាមពលកំដៅ និងចំហេះ (២) ស្រាវជ្រាវ និងតាមដានការវិវត្តនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងស្តង់ដារផ្នែកថាមពលកំដៅ និងចំហេះ (៣) ប្រមូលផ្តុំចងក្រងទិន្នន័យ និងព័ត៌មានផ្នែកថាមពលកំដៅ និងចំហេះ រៀបចំស្ថិតិសក្តានុពលប្រភពថាមពលកំដៅ និងចំហេះ និងកំណត់គម្រោងអាទិភាពផ្នែកថាមពលកំដៅ និងចំហេះដែលអាចបញ្ចូលក្នុងផែនការមេដើម្បីធ្វើការអភិវឌ្ឍ (៤) ចូលរួមផ្តល់យោបល់ក្នុងការរៀបចំផែនការមេ និងចូលរួមរៀបចំផែនការ និងកម្មវិធីវិនិយោគប្រភពថាមពល (៥) ចូលរួមជំរុញការវិនិយោគគម្រោង រៀបចំកិច្ចការជ្រើសរើសអ្នកវិនិយោគ និងរៀបចំគោលការណ៍អនុញ្ញាតឱ្យវិនិយោគសម្រាប់គម្រោងអភិវឌ្ឍផ្នែកថាមពលកំដៅ និងចំហេះ (៦) ចូលរួមត្រួតពិនិត្យការសិក្សា ការសាងសង់ និងការប្រគល់ទទួលគម្រោងប្រភពថាមពលកំដៅ និងចំហេះ (៧) ត្រួតពិនិត្យតាមដានការអនុវត្តគម្រោងប្រភពថាមពលកំដៅ និងចំហេះក្នុងដំណាក់កាលនៃការដំណើរការ (៨) ចូលរួមសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមរបស់គម្រោងប្រភពថាមពលកំដៅ និងចំហេះ ព្រមទាំងការរៀបចំផែនការកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងសង្គម (៩) ត្រួតពិនិត្យតាមដានការអនុវត្តផែនការកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងសង្គមរបស់គម្រោងប្រភពថាមពលកំដៅ និងចំហេះទាំងក្នុង

[30] យោងប្រការ១៥ នៃប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានថាមពល

ដំណាក់កាលសាងសង់ និងទាំងក្នុងដំណាក់កាលដំណើរការ[31]។

### ១.៤.៥ នាយកដ្ឋានថាមពលកកើតឡើងវិញ និងថាមពលផ្សេងទៀត

បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថាមពល លើការងារស្រាវជ្រាវបច្ចេកវិទ្យា ធ្វើសហប្រតិបត្តិការ រៀបចំគោលនយោបាយ ច្បាប់ ស្តង់ដារ ផែនការ បណ្តុះបណ្តាល និងតាមដាន ត្រួតពិនិត្យ ការអនុវត្តគម្រោងវិនិយោគក្នុងវិស័យថាមពលកកើតឡើងវិញ និងថាមពលផ្សេងទៀត។ បន្ថែមពីនេះនាយកដ្ឋានមានភារកិច្ចដូចជា៖ (១) ចូលរួមរៀបចំ និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការ ពាក់ព័ន្ធជាមួយនឹងការអភិវឌ្ឍនិងការប្រើប្រាស់ថាមពលកកើតឡើងវិញ និងថាមពលផ្សេងទៀត (២) ស្រាវជ្រាវ និងតាមដានការវិវត្តវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងស្តង់ដារនៃថាមពលកកើតឡើងវិញ និងថាមពលផ្សេងទៀត (៣) រៀបចំការសិក្សាអំពីសក្តានុពលនៃថាមពលកកើតឡើងវិញ និងថាមពលផ្សេងទៀត ដែលអាចមាននៅកម្ពុជាសម្រាប់ការប្រើប្រាស់គ្រប់ប្រភេទដែលមានប្រយោជន៍ (៤) ប្រមូលផ្តុំចងក្រងទិន្នន័យ និងព័ត៌មាន រៀបចំស្ថិតិសក្តានុពលនៃថាមពលទាំងនេះដែលអាចអភិវឌ្ឍភ្ជាប់បញ្ចូលក្នុងប្រព័ន្ធបណ្តាញជាតិ ឬអាចអភិវឌ្ឍសម្រាប់ការប្រើប្រាស់ដោយឡែក (៥) ផ្តល់យោបល់អំពីការបញ្ចូលការអភិវឌ្ឍប្រភពថាមពលកកើតឡើងវិញ និងថាមពលផ្សេងទៀតទៅក្នុងផែនការមេ ចូលរួមរៀបចំផែនការមេ និងចូលរួមរៀបចំផែនការ និងកម្មវិធីវិនិយោគប្រភពថាមពល (៦) សហការជាមួយនាយកដ្ឋានអភិវឌ្ឍថាមពលក្នុងការជំរុញការវិនិយោគ រៀបចំជ្រើសរើសអ្នកវិនិយោគ ត្រួវត្រួតពិនិត្យការសាងសង់ និងការប្រគល់ទទួលសម្រាប់គម្រោងអភិវឌ្ឍផ្នែកថាមពលកកើតឡើងវិញ និងថាមពលផ្សេងទៀត (៧) ត្រួតពិនិត្យ និងតាមដានការដំណើរការស្ថានីយអគ្គិសនីដើរដោយថាមពលកកើតឡើងវិញ និងថាមពលផ្សេងទៀតបន្ទាប់ពីអភិវឌ្ឍរួច (៨) សិក្សាវាយតម្លៃផលប្រយោជន៍ និងផលប៉ះពាល់នៃការប្រើប្រាស់ថាមពលកកើតឡើងវិញ និងថាមពលផ្សេងទៀត ធ្វើការផ្សព្វផ្សាយ និងសហប្រតិបត្តិការ ដើម្បីជំរុញការអភិវឌ្ឍ និងការប្រើប្រាស់ថាមពលនេះ[32]។

### ១.៤.៦ នាយកដ្ឋានបច្ចេកទេស និងគោលនយោបាយអាជីវកម្មថាមពល

បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថាមពល លើការងាររៀបចំ និងត្រួតពិនិត្យការអនុវត្តស្តង់ដារបច្ចេកទេស និងស្តង់ដារសុវត្ថិភាព រៀបចំ និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ និងយន្តការសន្សំសំចៃថាមពល និងប្រសិទ្ធិភាពថាមពល រៀបចំ និងត្រួតពិនិត្យការអនុវត្តស្តង់ដារបច្ចេកទេសអគ្គិសនីសម្រាប់រៀបចំបណ្តាញ និងសុវត្ថិភាពអគ្គិសនីក្នុងអគារ និងលំនៅដ្ឋាន រៀបចំ និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ និងយន្តការធ្វើអាជីវកម្ម និងការផ្តល់សេវាក្នុងវិស័យថាមពល ព្រមទាំងត្រួតពិនិត្យការអនុវត្ត

[31] យោងប្រការ១៨ នៃប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានថាមពល

[32] យោងប្រការ២១ នៃប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានថាមពល

គម្រោងវិនិយោគប្រព័ន្ធបណ្តាញផ្គត់ផ្គង់ និងការពង្រឹងស្ថិរភាពនៃការផ្គត់ផ្គង់។ បន្ថែមពីនេះនាយកដ្ឋានមានភារកិច្ចដូចជា៖ (១) ចូលរួមរៀបចំ និងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍវិស័យថាមពលពាក់ព័ន្ធជាមួយនិងការបញ្ជូន ការចែកចាយ និងការធ្វើអាជីវកម្មថាមពល (២) ស្រាវជ្រាវ និងតាមដានការវិវត្តនៃបច្ចេកវិទ្យា និងស្តង់ដារនៃការបញ្ជូន និងចែកចាយថាមពល (៣) រៀបចំ និងត្រួតពិនិត្យការអនុវត្តស្តង់ដារបច្ចេកទេស និងស្តង់ដារសុវត្ថិភាពក្នុងការបញ្ជូននិងចែកចាយអគ្គិសនី និងការតបណ្តាញអគ្គិសនីក្នុងអាគារ និងលំនៅដ្ឋាន (៤) ប្រមូលផ្តុំ និងចងក្រងទិន្នន័យ និងព័ត៌មាននៃការបញ្ជូន ការចែកចាយ និងការធ្វើអាជីវកម្មថាមពល រៀបចំសេចក្តីត្រូវការហេដ្ឋារចនាសម្ព័ន្ធបញ្ជូន និងចែកចាយដែលត្រូវបញ្ចូលក្នុងផែនការមេដើម្បីធ្វើការអភិវឌ្ឍ (៥) ចូលរួមផ្តល់យោបល់ក្នុងការរៀបចំផែនការមេ ផែនការកម្មវិធីវិនិយោគប្រព័ន្ធបញ្ជូន និងចែកចាយ (៦) ចូលរួមជំរុញការវិនិយោគគម្រោង រៀបចំកិច្ចការជ្រើសរើសអ្នកវិនិយោគ និងរៀបចំគោលការណ៍អនុញ្ញាតឱ្យអ្នកវិនិយោគ សម្រាប់គម្រោងអភិវឌ្ឍផ្នែកបញ្ជូន និងចែកចាយអគ្គិសនី (៧) ចូលរួមត្រួតពិនិត្យការសិក្សា ការសាងសង់ និងការប្រគល់ទទួលគម្រោងអភិវឌ្ឍផ្នែកបញ្ជូន និងចែកចាយ (៨) រៀបចំកំណត់គោលនយោបាយ និងសេចក្តីសម្រេចនានាពាក់ព័ន្ធជាមួយអាជីកម្ម និងការផ្តល់សេវាផ្គត់ផ្គង់ (៩) ត្រួតពិនិត្យ តាមដានការអនុវត្តគោលនយោបាយ និងសេចក្តីសម្រេចពាក់ព័ន្ធជាមួយ និងអាជីវកម្ម និងការផ្តល់សេវាផ្គត់ផ្គង់ (១០) រៀបចំ និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ និងយន្តការសន្សំសំចៃថាមពល និងប្រសិទ្ធិភាពថាមពល[33]។

### ១.៥.អគ្គនាយកដ្ឋានប្រេងកាត

អគ្គនាយកដ្ឋានប្រេងកាត បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែ និងថាមពល ដោយមានភារកិច្ចអនុវត្តគោលនយោបាយបម្រើវិស័យប្រេងកាត និងគ្រប់គ្រងប្រេងកាតផ្នែកអាប់ស្ទ្រីម (Upstream) និងផ្នែកដោនស្ទ្រីម (Downstream) ដែលរួមមានបុរេសនា ការស្វែងរុករក ការអភិវឌ្ឍ និងផលិតប្រេងកាត ការធ្វើប្រព្រឹត្តកម្មប្រេងកាត និងគីមីប្រេងកាត ការដឹកជញ្ជូន និងចែកចាយ សន្និធិ ការនាំចេញ-នាំចូល និងការធ្វើពាណិជ្ជកម្មប្រេងកាត និងផលិតផលប្រេងកាត។[34]

អគ្គនាយកដ្ឋានប្រេងកាត មាននាយកដ្ឋានក្រោមចំណុះចំនួន ០៥ ដែលរួមមាន នាយកដ្ឋានសិក្សាស្រាវជ្រាវប្រេងកាត នាយកដ្ឋានជំរុញ និងអភិវឌ្ឍធនធានប្រេងកាត នាយកដ្ឋានគ្រប់គ្រងគម្រោងសម្បទានប្រេងកាត នាយកដ្ឋានកិច្ចការប្រេងកាតអន្តរជាតិ និងនាយកដ្ឋានបច្ចេកវិទ្យាប្រេងកាត គាំទ្រកិច្ចប្រតិបត្តិការ និងសន្តិសុខថាមពល[35]។

[33] យោងប្រការ២៤ នៃប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានថាមពល
[34] យោងមាត្រា១៩ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល
[35] យោងមាត្រា២០ នៃអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល

### ១.៥.១ នាយកដ្ឋានសិក្សាស្រាវជ្រាវប្រេងកាត

បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រេងកាត លើការងារផ្នែកអាប់ស្ទ្រីម (Upstream) និងមានភារៈកិច្ចដូចជា៖ (១) សិក្សាស្រាវជ្រាវលក្ខណៈភូគព្ភសាស្ត្រ និងវាយតម្លៃសក្តានុពលធនធានប្រេងកាត (២) សិក្សាវិភាគលក្ខណៈជម្រកប្រេងកាត (៣) សិក្សាវិភាគលក្ខណៈវិស្វកម្មរបស់អាងប្រេងកាត (៤) សិក្សា រៀបចំ និងត្រួតពិនិត្យការវិភាគសេដ្ឋកិច្ចធនធានប្រេងកាត (៥) រៀបចំលិខិតបទដ្ឋានបច្ចេកទេស និងស្តង់ដារប្រតិបត្តិសម្រាប់ការអនុវត្តសកម្មភាពសិក្សាស្វែងរុករកអភិវឌ្ឍ ផលិតកម្ម រុះរើបោសសម្អាតការដ្ឋានប្រេងកាត និងបោះបង់អណ្តូងប្រេងកាត (៦) សិក្សាវាយតម្លៃ និងត្រួតពិនិត្យគំនូសប្លង់បច្ចេកទេសសាងសង់ និងដំឡើងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗពាក់ព័ន្ធនឹងការស្វែងរុករក ការអភិវឌ្ឍ និងការធ្វើផលិតកម្ម (៧) ត្រួតពិនិត្យ និងធ្វើរបាយការណ៍លទ្ធផលសកម្មភាពសិក្សាស្វែងរុករក ការអភិវឌ្ឍ ផលិតកម្មប្រេងកាត ការរុះរើបោសសម្អាតការដ្ឋានប្រេងកាត និងការបោះបង់អណ្តូងប្រេងកាត (៨) រៀបចំ គ្រប់គ្រង និងថែរក្សាទិន្នន័យរូបភូគព្ភសាស្ត្រ អណ្តូងប្រេងកាត និងអាងប្រេងកាត។ (៩) សិក្សាវិភាគសមាសធាតុប្រេងកាត[36]។

### ១.៥.២ នាយកដ្ឋានជំរុញ និងអភិវឌ្ឍធនធានប្រេងកាត

បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រេងកាត លើការងារទាក់ទាញអ្នកវិនិយោគ និងការរៀបចំផ្តល់កិច្ចព្រមព្រៀងប្រេងកាតតាមវិធីសាស្ត្រដេញថ្លៃ ឬចរចាផ្ទាល់។ បន្ថែមពីនេះនាយកដ្ឋានមានភារៈកិច្ចដូចជា៖ (១) រៀបចំ និងចាត់ចែងព័ត៌មានប្រេងកាត ដើម្បីជំរុញតម្លាភាព និងការយល់ដឹងជាសាធារណៈ (២) រៀបចំ ផ្សព្វផ្សាយគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្តិ និងព័ត៌មានប្រេងកាត និងជំរុញទាក់ទាញការ វិនិយោគក្នុងវិស័យប្រេងកាត ទាំងក្នុងក្របខណ្ឌជាតិ និងអន្តរជាតិ (៣) សម្របសម្រួលរៀបចំផែនការអភិវឌ្ឍវិស័យប្រេងកាតជាតិ (៤) ផ្តល់សេវាពិគ្រោះយោបល់អំពីព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងការវិនិយោគក្នុងវិស័យប្រេងកាត (៥) ជំរុញ និងសម្របសម្រួលភាពជាដៃគូក្នុងការងារពហុភាគីរវាងផ្នែកសាធារណៈ ផ្នែកឯកជន និងអង្គការសង្គមស៊ីវិល (៦) វាយតម្លៃផលប៉ះពាល់នៃបញ្ញត្តិកម្មចំពោះធុរកិច្ចនៃវិស័យប្រេងកាត (៧) សម្របសម្រួលការងារបើកតំបន់សម្បទានប្រេងកាត វិភាគសេដ្ឋកិច្ច រៀបចំកិច្ចព្រមព្រៀងប្រេងកាត ការធ្វើលទ្ធកម្មប្លុកប្រេងកាត និងការចរចាកិច្ចព្រមព្រៀងប្រេងកាត[37]។

### ១.៥.៣ នាយកដ្ឋានគ្រប់គ្រងគម្រោងសម្បទានប្រេងកាត

បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រេងកាត លើការងារតាមដានត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងប្រេងកាតរួមទាំងការងារគ្រប់គ្រងការអភិវឌ្ឍ និងផលិតកម្មប្រេង និងឧស្ម័ន។ បន្ថែមពីនេះនាយកដ្ឋាន

[36] យោងប្រការ៩ នៃប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានប្រេងកាត

[37] យោងប្រការ១២ នៃប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានប្រេងកាត

មានភារៈកិច្ចដូចជា៖ (១) ត្រួតពិនិត្យ និងវាយតម្លៃភាពអនុលោមនៃប្រតិបត្តិការប្រេងកាតរបស់អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតធៀបទៅនឹងកិច្ចព្រមព្រៀងប្រេងកាត (២) វាយតម្លៃភាពអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងការអនុវត្តកិច្ចព្រមព្រៀងប្រេងកាត (៣) សិក្សាវិភាគ វាយតម្លៃ និងត្រួតពិនិត្យចំណូល ចំណាយ និងស្ថានភាពហិរញ្ញវត្ថុរបស់អ្នកចុះកិច្ចព្រមព្រៀងប្រេងកាត (៤) រៀបចំផែនការ គ្រប់គ្រង កត់ត្រា តាមដាន និងបូកសរុបចំណូលមិនមែនសារពើពន្ធវិស័យប្រេងកាត (៥) ពិនិត្យ វាយតម្លៃ និងផ្តល់យោបល់លើការផ្ទេរ ពន្យារបន្ត ឬបញ្ចប់កិច្ចព្រមព្រៀងប្រេងកាត (៦) រៀបចំការផ្តល់លិខិតអនុញ្ញាតអភិវឌ្ឍ និងផលិតកម្មប្រេងកាត (៧) ត្រួតពិនិត្យតាមដានការប្រើប្រាស់ទំនិញ និងសេវាកម្មតាមគម្រោងផែនការ និងថវិការបស់ក្រុមហ៊ុន (៨) រៀបចំចុះបញ្ជី ត្រួតពិនិត្យ និងរៀបចំការផ្តល់ការអនុញ្ញាតដល់បណ្តាក្រុមហ៊ុនដែលបង្កើតមូលដ្ឋានផ្គត់ផ្គង់ ឬក្រុមហ៊ុនដែលធ្វើការផ្គត់ផ្គង់ទំនិញ ឧបករណ៍ សម្ភារៈ សេវាកម្ម និងពលកម្មបម្រើឱ្យវិស័យប្រេងកាតផ្នែកអាប់ស្ទ្រីម (Upstream) (៩) ពិនិត្យបញ្ជីសារពើភ័ណ្ឌរបស់អ្នកចុះកិច្ចព្រមព្រៀងប្រេងកាត (១០) សម្របសម្រួលដោះស្រាយផលប៉ះពាល់ និងការផ្តល់សំណងទូទាត់ដល់ម្ចាស់កម្មសិទ្ធិ ដែលទទួលរងផលប៉ះពាល់ដោយប្រតិបត្តិការប្រេងកាត (១១) ជំរុញ និងលើកកម្ពស់ផលប្រយោជន៍ដល់សហគមន៍មូលដ្ឋាននៅក្នុងតំបន់ប្រតិបត្តិការប្រេងកាត[38]។

### ១.៥.៤ នាយកដ្ឋានកិច្ចការប្រេងកាតអន្តរជាតិ

បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រេងកាត លើការងារស្រាវជ្រាវច្បាប់ គោលនយោបាយយុទ្ធសាស្ត្រ និងការងារសហប្រតិបត្តិការក្នុងវិស័យប្រេងកាតផ្នែកអាប់ស្ទ្រីម (Upstream)។ បន្ថែមពីនេះនាយកដ្ឋានមានភារៈកិច្ចដូចជា៖ (១) ចូលរួម និងរៀបចំការងារពាក់ព័ន្ធនឹងសន្ធិសញ្ញា ច្បាប់អន្តរជាតិ និងការចរចាអន្តរជាតិផ្សេងៗក្នុងវិស័យប្រេងកាត (២) សម្របសម្រួល និងការរៀបចំការងារចរចារអន្តរជាតិពាក់ព័ន្ធនឹងតំបន់ទាមទារត្រួតគ្នា និងកិច្ចការអភិវឌ្ឍធនធានប្រេងកាតរួមគ្នា (៣) ទំនាក់ទំនង និងសហប្រតិបត្តិការក្នុងតំបន់ និងអន្តរជាតិលើវិស័យប្រេងកាត[39]។

### ១.៥.៥ នាយកដ្ឋានបច្ចេកវិទ្យាប្រេងកាត គាំទ្រកិច្ចប្រតិបត្តិការ និងសន្តិសុខថាមពល

បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រេងកាត លើការងារផ្នែកដោនស្ទ្រីម (Downstream) ដែលរួមមាន ការធ្វើប្រព្រឹត្តិកម្ម ការដឹកជញ្ជូន សន្និធិ ការនាំចូលប្រេងកាត និងផលិតផលប្រេងកាតបច្ចេកទេសសុវត្ថិភាព និងសន្តិសុខថាមពល។ បន្ថែមពីនេះនាយកដ្ឋានមានភារៈកិច្ចដូចជា៖ (១) គ្រប់គ្រង និងរៀបចំផ្តល់ការអនុញ្ញាតពាក់ព័ន្ធសកម្មភាពផ្នែកដោនស្ទ្រីម (Downstream) និងសកម្មភាពផ្គត់ផ្គង់ទំនិញ ឧបករណ៍

[38] យោងប្រការ១៥ នៃប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានប្រេងកាត
[39] យោងប្រការ១៨ នៃប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានប្រេងកាត

សម្ភារៈ សេវាកម្ម និងពលកម្មបម្រើឱ្យសកម្មភាពផ្នែកដោនស្ទ្រីម (Downstream) (២) រៀបចំបទប្បញ្ញត្តិ បទដ្ឋានបច្ចេកទេស និងត្រួតពិនិត្យភាពអនុលោមនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធ ប្រេងកាតផ្នែកដោនស្ទ្រីម (Downstream) ដែលរួមមាន រោងចក្រប្រព្រឹត្តិកម្មប្រេងកាត និងគីមីប្រេងកាតបណ្តាញបំពង់បង្ហូរប្រេងកាត និងផលិតផលប្រេងកាត បំពង់បណ្តាញចែកចាយ មណ្ឌលសន្និធិ មធ្យោបាយដឹកជញ្ជូន ស្ថានីយប្រេង និងឧស្ម័នឥន្ធនៈ ទីតាំងបញ្ចូលឧស្ម័នក្នុងដប និងធុង (៣) រៀបចំយថាប្រភេទគុណភាពផលិតផលប្រេងកាត និងត្រួត-ពិនិត្យភាពអនុលោមនៃផលិតផលប្រេងកាតតាមយថាប្រភេទ (៤) សិក្សា និងកំណត់បរិមាណសន្និធិយុទ្ធសាស្ត្រប្រេងកាត និងផលិតផលប្រេងកាត[40]។

## ១.៦.អគ្គាធិការដ្ឋាន

អគ្គាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែ និងថាមពលលើការងារអធិការកិច្ច ដោយក្នុងនោះមានមុខងារ ភារកិច្ច និងសិទ្ធិអំណាចដូចខាងក្រោម៖

- អគ្គាធិការដ្ឋាន មានមុខងារ និងភារកិច្ចដូចតទៅ៖ (១) ធ្វើអធិការកិច្ចជាប្រចាំទៅលើគ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាព មន្ទីររាជធានី ខេត្ត និងក្នុងករណីចាំបាច់អាចចុះពិនិត្យ និងដោះស្រាយការងារតាមអង្គភាព ដែលជួលឱ្យឯកជនគ្រប់គ្រងក្រោមឱវាទក្រសួងតាមសមត្ថកិច្ចរបស់ខ្លួន (២) ធ្វើរបាយ-ការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តទៅរបស់អង្គភាព ដែលបានធ្វើអធិការកិច្ច និងពីវិធានការកែលម្អការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ (៣) រាល់របាយការណ៍អធិការកិច្ច ត្រូវបានរក្សាជាការសម្ងាត់សំរាប់ក្រសួង (៤) ប្រតិបត្តិភារកិច្ចតាមការងារផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន[41]។
- អគ្គាធិការដ្ឋាន មានសិទ្ធិ (១) ធ្វើអធិការកិច្ច គ្រប់ផ្នែកក្នុងវិស័យរ៉ែ និងថាមពល ដោយរួមទាំងវិស័យអគ្គិសនី ប្រេងកាត និងឧស្ម័ន គ្រប់អង្គភាពក្រោមឱវាទក្រសួងដោយមិនចាំបាច់ជូនដំណឹងជាមុននៅក្នុងករណីពិសេស (២) ធ្វើការអញ្ជើញ ឬសំណូមពរទៅឱ្យអង្គភាព ដែលត្រូវធ្វើអធិការកិច្ចដើម្បីឱ្យរាយការណ៍ផ្ទាល់មាត់ ឬលាយល័ក្ខអក្សរអំពីការងាររបស់ខ្លួន ព្រមទាំងបង្ហាញ ទីតាំងឯកសារចាំបាច់សៀវភៅបញ្ជី សាលាប័ត្រ និងប្រាក់បេឡា ប្រាក់បញ្ញើ ដើម្បីបង្កលក្ខណៈងាយស្រួលដល់កិច្ច-ការចុះធ្វើអធិការកិច្ច និងបញ្ជូនមន្ត្រីរាជការឱ្យចូលរួមសហការ តាមសំណូមពរនៃការធ្វើអធិការកិច្ច។ (៣) ក្នុងករណីចាំបាច់អាចស្នើសុំយោបល់រដ្ឋមន្ត្រីឱ្យផ្អាក និងបញ្ឈប់ជាបណ្តោះអាសន្ន នូវរាល់សកម្មភាព ធ្វើចលនាផ្សេងៗ ដែលជាប់ពាក់ព័ន្ធក្នុងពេលកំពុងធ្វើអធិការកិច្ច។ (៤) ធ្វើការថតរូបភាព

[40] យោងប្រការ២១ នៃប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានប្រេងកាត

[41] ប្រការ៣ នៃប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គាធិការដ្ឋានចំណុះក្រសួងរ៉ែ និងថាមពល

ថតសំឡេង និងថតចម្លងឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងការធ្វើអធិការកិច្ច (៥) ក្រោយការធ្វើអធិការកិច្ច មួយលើកៗ អគ្គាធិការដ្ឋាន មានសិទ្ធិសន្និដ្ឋាន លើការធ្វើខុស ឬត្រូវ និងលើកសំណូមពរ សសើរ កែលម្អ ឬពិន័យ ស្នើសុំមតិសម្រេចពីរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល[42]។

អគ្គាធិការដ្ឋាន បានធ្វើការបែងចែករចនាសម្ព័ន្ធជាបីការិយាល័យដូចជា ការិយាល័យអធិការកិច្ចរដ្ឋបាល ការិយាល័យអធិការកិច្ចហិរញ្ញវត្ថុ និងការិយាល័យអធិការកិច្ចបច្ចេកទេស។

### ១.៦.១ ការិយាល័យអធិការកិច្ចរដ្ឋបាល

- តួនាទី៖ ជាអង្គភាពសេនាធិការជំនួយការឱ្យថ្នាក់ដឹកនាំអគ្គាធិការដ្ឋាន លើការងារអធិការកិច្ចរដ្ឋបាល បុគ្គលិក និងការងារបូកសរុបរបាយការណ៍
- ភារកិច្ច៖ (១) រៀបចំ ឬបង្កើតកម្មវិធីការងារ លើគ្រប់វិស័យ ដែលទាក់ទងនឹងការចុះធ្វើអធិការកិច្ច សមស្រប តាមនីតិវិធី និងកាលៈទេសៈជាក់ស្តែង (២) ធ្វើអធិការកិច្ចលើការអនុវត្តគោលការណ៍ គោលនយោបាយ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីសម្រេច សារាចរ សេចក្តីណែនាំ បទបញ្ជា កិច្ចព្រមព្រៀង ឧបសម្ព័ន្ធ លិខិតបទដ្ឋានផ្សេងៗ របស់ក្រសួង (៣) ធ្វើអធិការកិច្ចលើការងារគ្រប់គ្រងផ្នែករដ្ឋបាល របស់អង្គភាពក្រោមឱវាទក្រសួង នូវរាល់ការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន (៤) ពិនិត្យរាល់លិខិតស្នាម ដែលទាក់ទងនឹងបណ្តឹងតវ៉ា រួចលើកមតិជូនថ្នាក់ដឹកនាំ ដើម្បីពិនិត្យ និងសម្រេច (៥) គ្រប់គ្រង និងចរាចរឯកសារផ្សេងៗរបស់អគ្គាធិការដ្ឋាន (៦) ប្រមូលព័ត៌មាន និងឯកសារផ្សេងៗពីមន្ត្រីរាជការ ឬជនដែលជាប់ពាក់ព័ន្ធនឹងការធ្វើអធិការកិច្ច (៧) សហការ និងបង្កលក្ខណៈងាយស្រួលដល់ប្រតិភូដែលចុះធ្វើអធិការកិច្ច (៨) ចងក្រងរៀបចំ និងតាក់តែងលិខិតស្នាមពាក់ព័ន្ធនឹងការងារជំនាញ (៩) ចងក្រងរៀបចំ និងថែរក្សាសំណុំលិខិត ឯកសារពាក់ព័ន្ធនឹងការងារជំនាញដោយសម្ងាត់ (១០) ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីលទ្ធផលដែលបានចុះធ្វើអធិការកិច្ច នៅតាមបណ្តាអគ្គនាយកដ្ឋាន នាយកដ្ឋាន អង្គភាព មន្ទីររាជធានី ខេត្ត និងក្នុងករណីចាំបាច់ធ្វើរបាយការណ៍ពីលទ្ធផលអធិការកិច្ចលើអង្គភាពរដ្ឋ ដែលជួលឱ្យឯកជនគ្រប់គ្រងក្រោមឱវាទក្រសួង (១១)ប្រតិបត្តិភារកិច្ចតាមការងារផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

### ១.៦.២ ការិយាល័យអធិការកិច្ចហិរញ្ញវត្ថុ

- តួនាទី៖ ជាសេនាធិការជំនួយឱ្យថ្នាក់ដឹកនាំ អគ្គាធិការដ្ឋាន លើការងារបច្ចេកទេសក្នុងវិស័យរ៉ែ និងថាមពល ដោយរួមទាំងវិស័យអគ្គិសនី ប្រេងកាត និងឧស្ម័ន។

[42] ប្រការ៤ នៃប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អគ្គាធិការដ្ឋានចំណុះក្រសួងរ៉ែ និងថាមពល

- ភារកិច្ច៖ (១) ធ្វើអធិការកិច្ចលើការទូទាត់ និងការអនុវត្តបេបចំណូល ចំណាយថវិការដ្ឋ (២) ធ្វើអធិការកិច្ចលើការអនុវត្តបេបគណនេយ្យ ហិរញ្ញវត្ថុ ប្រាក់សេវា បេឡា របស់ក្រសួង និងអង្គភាពក្រោមឱវាទ (៣) ធ្វើអធិការកិច្ចលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការសន្សំសំចៃ ការប្រើប្រាស់សម្ភារៈ ប្រាក់ទុនឥណទាន ថវិកា និងការងារលទ្ធកម្ម នៅក្រសួង និងអង្គភាពក្រោមឱវាទ (៤) ធ្វើអធិការកិច្ចលើលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធនឹងការងារសេដ្ឋកិច្ច គណនេយ្យ និងហិរញ្ញវត្ថុ (៥) សហការតាក់តែងលិខិតស្នាមពាក់ព័ន្ធនឹងការងារជំនាញ (៦) សហការ និងបង្កលក្ខណៈងាយស្រួលដល់ប្រតិភូដែលចុះធ្វើអធិការកិច្ច (៧) ធ្វើរបាយការណ៍សរុបអំពីសកម្មភាព និងលទ្ធផលការងារអធិការកិច្ចជូនរដ្ឋមន្ត្រី (៨) ប្រតិបត្តិភារកិច្ចតាមការងារផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

### ១.៦.៣ ការិយាល័យអធិការកិច្ចបច្ចេកទេស

- តួនាទី៖ ជាសេនាធិការជំនួយការឱ្យថ្នាក់ដឹកនាំ អគ្គាធិការដ្ឋាន លើការងារបច្ចេកទេសក្នុងវិស័យរ៉ែ និងថាមពល ដោយរួមទាំងវិស័យអគ្គិសនី ប្រេងកាត និងឧស្ម័ន។
- ភារកិច្ច៖ (១) ធ្វើអធិការកិច្ចលើការងារអនុវត្តន៍បច្ចេកទេសក្នុងវិស័យរ៉ែ និងថាមពល ដោយរួមទាំងវិស័យអគ្គិសនី ប្រេងកាត និងឧស្ម័ន (២) ធ្វើអធិការកិច្ចលើគម្រោងនានា និងការអនុវត្តគម្រោងទាំងនោះ (៣) សហការតាក់តែងលិខិតស្នាមពាក់ព័ន្ធនឹងការងារជំនាញ (៤) ប្រតិបត្តិភារកិច្ចតាមការងារផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន[43]។

## ១.៧.នាយកដ្ឋានសវនកម្មផ្ទៃក្នុង

នាយកដ្ឋានសវនកម្មផ្ទៃក្នុង បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែ និងថាមពលលើការងារសវនកម្មផ្ទៃក្នុងដោយមានភារកិច្ចដូចជា៖ (១) អនុវត្តន៍មុខងារសវនកម្មផ្ទៃក្នុងលើការពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ក្រសួង (២) វាយតម្លៃអំពីប្រសិទ្ធិភាពនៃការអនុវត្តប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់អង្គភាពក្រោមឱវាទក្រសួងសំដៅដល់ការពង្រឹងអភិបាលកិច្ចល្អ (៣) ធ្វើរបាយការណ៍គ្រង់ទៅប្រធានស្ថានប័ន ដោយផ្ញើច្បាប់ចម្លងទៅអាជ្ញាធរសវនកម្មជាតិ និងសម្របសម្រួលការងារជាមួយសមត្ថកិច្ចត្រួតពិនិត្យនានា[44]។

នាយកដ្ឋានសវនកម្មផ្ទៃក្នុងដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងមានការិយាល័យចំណុះដូចខាងក្រោម៖

### ១.៧.១ លេខាធិការដ្ឋាន

- តួនាទី៖ ជាសេនាធិការជំនួយការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានលើការងាររដ្ឋបាល និងការងារគ្រប់គ្រង

[43] ប្រការ៧ នៃប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គាធិការដ្ឋានចំណុះក្រសួងរ៉ែ និងថាមពល
[44] យោងមាត្រា២៣ អនុក្រឹត្យស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល

ធនធានមនុស្ស និងឯកសាររបស់នាយកដ្ឋាន មានឋានៈស្មើការិយាល័យ។

- ❖ ភារកិច្ចៈ (១) រៀបចំផែនការ និងកម្មវិធីការងារសម្រាប់ធ្វើសវនកម្មប្រចាំឆ្នាំរបស់នាយកដ្ឋាន (២) រៀបចំគម្រោង គ្រប់គ្រងទ្រព្យសម្បត្តិ និងបញ្ជីសារពើភ័ណ្ឌរបស់នាយកដ្ឋាន (៣) គ្រប់គ្រង និងចរាចរឯកសារផ្សេងៗរបស់នាយកដ្ឋាន (៤) តាក់តែងលិខិតស្នាមនានាពាក់ព័ន្ធ និងការងារជំនាញ (៥) ថែរក្សាសំណុំលិខិត ឯកសារពាក់ព័ន្ធនឹងការងារជំនាញដោយសម្ងាត់ (៦) គ្រប់គ្រងធនធានមនុស្ស ស្ថិតិ មន្ត្រី ការរៀបចំតួនាទី ការបណ្តុះបណ្តាលការងារ និងការងារសង្គមកិច្ចនៅក្នុងនាយកដ្ឋាន (៧) បូកសរុបរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង អំពីលទ្ធផលការងារដែលបានចុះធ្វើសវនកម្មនៅតាមបណ្តាអង្គភាពនានា ក្រោមឱវាទក្រសួង (៨) រៀបចំការងារដែលពាក់ព័ន្ធដល់ការងារសវនកម្មផ្ទៃក្នុង ជាមួយអាជ្ញាធរសវនកម្មជាតិ។

### ១.៧.២ ការិយាល័យបច្ចេកទេសសវនកម្ម

- ❖ <u>តួនាទីៈ</u> ជាសេនាធិការជំនួយការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានលើការងារបច្ចេកទេសសវនកម្ម និងកសាងផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងរបស់ក្រសួងរ៉ែ និងថាមពល។
- ❖ <u>ភារកិច្ចៈ</u> (១) រៀបចំការងារសវនកម្មដែលពាក់ព័ន្ធដល់ការអនុវត្តន៍គោលការណ៍ គោលនយោបាយ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីសម្រេច សារាចរ សេចក្តីណែនាំ បទបញ្ជា កិច្ចព្រមព្រៀង កិច្ចសន្យា ឧបសម្ព័ន្ធ និងលិខិតបទដ្ឋានផ្សេងៗ នៅតាមបណ្តាអង្គភាពត្រូវធ្វើសវនកម្ម (២) សិក្សាស្រាវជ្រាវ ចងក្រងឯកសារនានា ដែលពាក់ព័ន្ធលើការងារសវនកម្ម (៣) ផ្តល់យោបល់លើបច្ចេកទេសសវនកម្ម ដើម្បីធានាឱ្យការងារសវនកម្មប្រព្រឹត្តទៅបានយ៉ាងល្អប្រសើរ (៤) រៀបចំផែនការសវនកម្មប្រចាំឆ្នាំ ដោយការកំណត់លើហានិភ័យតាមបណ្តាអង្គភាពក្រោមឱវាទក្រសួង (៥) ពិនិត្យលើគម្រោងនានា និងតាមដានការអនុវត្តគម្រោងទាំងនោះ ដើម្បីឱ្យការធ្វើសវនកម្មមានប្រសិទ្ធិភាព (៦) ជំរុញការអភិវឌ្ឍជំនាញសវនកម្មតាមរយៈការស្រាវជ្រាវ ការផ្លាស់ប្តូរបទពិសោធន៍ ការផ្សព្វផ្សាយ ការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស និងការទាក់ទាញជំនួយបច្ចេកទេស ទាក់ទងលើវិស័យសវនកម្ម (៧) ធ្វើសវនកម្មលើប្រព័ន្ធកុំព្យូទ័រតាមការិយបរិច្ឆេទ និងធ្វើការវាយតម្លៃលើប្រព័ន្ធដំណើរការទិន្នន័យសំខាន់ៗ (៨) ពិនិត្យលើប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីដកស្រង់ព័ត៌មានបម្រើឱ្យការងារសវនកម្ម (៩) រៀបចំ និងតាក់តែងលិខិតស្នាមពាក់ព័ន្ធនឹងការងារជំនាញ (១០) រៀបចំនិងថែរក្សាសំណុំឯកសារពាក់ព័ន្ធនឹងការងារជំនាញដោយសម្ងាត់ (១១) ផ្ញើរបាយការណ៍សរុបអំពីសកម្មភាព និងលទ្ធផលការងារសវនកម្មជូនថ្នាក់ដឹកនាំ។

### ១.៧.៣ ការិយាល័យសវនកម្មគណនេយ្យហិរញ្ញវត្ថុ

- តួនាទី៖ ជាសេនាធិការជំនួយការឱ្យថ្នាក់ដឹកនាំនាយកដ្ឋាន លើការងារសវនកម្មគណនេយ្យហិរញ្ញវត្ថុ និងកសាងផែនការចំណាយថវិការដ្ឋប្រចាំឆ្នាំរបស់នាយកដ្ឋាន។
- ភារកិច្ច៖ (១) រៀបចំគម្រោង និងត្រួតពិនិត្យ ការអនុវត្តចំណាយថវិកាប្រចាំឆ្នាំរបស់នាយកដ្ឋាន (២) ធ្វើសវនកម្មលើការទូទាត់ និងការអនុវត្តរបបចំណូល-ចំណាយថវិការដ្ឋ (៣) ធ្វើសវនកម្មលើការអនុវត្ត របបគណនេយ្យ-ហិរញ្ញវត្ថុ ប្រាក់សេវា បេឡារបស់ក្រសួង និងបណ្តាអង្គភាពក្រោមឱវាទក្រសួង (៤) ធ្វើសវនកម្មលើការងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការប្រើប្រាស់សម្ភារៈ ថវិកានៅអង្គភាពថ្នាក់កណ្តាល និងបណ្តាអង្គភាព ក្រោមឱវាទក្រសួងរ៉ែ និងថាមពល (៥) ធ្វើសវនកម្មលើការងារលទ្ធកម្មសាធារណៈនានា ដែលទាក់ទងដល់កិច្ចប្រតិបត្តិការការងាររបស់ក្រសួងរ៉ែ និងថាមពល (៦) ពិនិត្យវាយតម្លៃពីភាពសមស្រប និងប្រសិទ្ធិភាពខ្ពស់លើប្រព័ន្ធគ្រប់គ្រងគណនេយ្យ និងកិច្ចប្រតិបត្តិការបញ្ជីការគណនេយ្យរបស់បណ្តាអង្គភាពចំណុះក្រសួង (៧) ពិនិត្យ និងវាយតម្លៃពីភាពសមស្របលើការថែទាំទ្រព្យសម្បត្តិរដ្ឋ និងកិច្ចប្រតិបត្តិការកម្មវិធីគម្រោងចំណូល-ចំណាយថវិការដ្ឋ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវវិជ្ជមាន ឬអវិជ្ជមានតាមការិយបរិច្ឆេទនីមួយៗ នៃរបាយការណ៍ហិរញ្ញវត្ថុ របស់អង្គភាពក្រោមឱវាទក្រសួង (៨) ផ្តល់អនុសាសន៍ដល់បណ្តាអង្គភាព ដែលមានរបបចំណូល-ចំណាយថវិការដ្ឋ តាមគោលការណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំដៅកៀរគរប្រមូលចំណូលចូលថវិការដ្ឋឱ្យមានប្រសិទ្ធិភាពខ្ពស់ (៩) ធ្វើរបាយការណ៍អំពីសកម្មភាព និងលទ្ធផលការងារសវនកម្មជូនថ្នាក់ដឹកនាំ[45]។

## ២.អង្គភាពថ្នាក់ក្រោមជាតិ

ក្រសួងរ៉ែ និងថាមពល មានអង្គភាពថ្នាក់ក្រោមជាតិដែលជាមន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត ដើម្បីបំពេញមុខងារពាក់ព័ន្ធនឹងវិស័យរបស់ក្រសួងរ៉ែ និងថាមពលនៅថ្នាក់ក្រោមជាតិ។ ដើម្បីពង្រឹងសកម្មភាពការងារនៅថ្នាក់ក្រោមជាតិ និងសមស្របទៅតាមការធ្វើកំណែទម្រង់រដ្ឋបាល ក្រសួងរ៉ែ និងថាមពល បានធ្វើការបែងចែកជាពីរថ្នាក់គឺ ថ្នាក់រាជធានី-ខេត្ត និងថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

### ២.១. ថ្នាក់រាជធានី-ខេត្ត

សំដៅដល់មន្ទីររ៉ែ និងថាមពលរាជធានី-ខេត្តដែលមានមុខងារ និងភារកិច្ចដូចតទៅ៖ (១) ចូលរួមកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍមូលដ្ឋានរាជធានី ខេត្ត និងចូលរួមក្នុងការរៀបចំ និងអនុវត្តគោលនយោបាយរ៉ែ និង

[45] ប្រការ នៃប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង

ថាមពល រួមទាំងប្រេងកាត ឧស្ម័ន រ៉ែ អគ្គិសនីរបស់ក្រសួង ពិសេសចូលរួមជំរុញវិស័យឯកជនក្នុងការវិនិយោគ (២) ចូលរួមរៀបចំ និងសមាហរណកម្មវិស័យធនធានរ៉ែ និងថាមពល ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ កម្មវិធីវិនិយោគសាធារណៈ (៣) គ្រប់គ្រង និងផ្សព្វផ្សាយនយោបាយការពារបរិស្ថានរបស់ក្រសួង (៤) អនុវត្តន៍វិធានការអប់រំ និងបញ្ជ្រាបការយល់ដឹងជាសាធារណៈដល់សហគមន៍នៅក្នុងតំបន់ជុំវិញជិតខាងការដ្ឋានរ៉ែ (៥) ចូលរួមទប់ស្កាត់ និងបង្ក្រាបអាជីវកម្មរ៉ែអនាធិបតេយ្យក្នុងរាជធានី ខេត្តដែលមន្ទីរគ្រប់គ្រង (៦) គ្រប់គ្រងការធ្វើអាជីវកម្ម និងប្រើប្រាស់ធនធានរ៉ែសំណង់ (ខ្សាច់ ក្រួស ថ្ម) សំដៅធានាការគោរពច្បាប់ បរិស្ថាន និងប្រើប្រាស់វត្ថុធាតុដើមអោយចំទិសដៅ (៧) ចូលរួមវាយតម្លៃ ប្រមូលចំណូលឱ្យបានសមស្របតាមច្បាប់ដែលបានកំណត់ពាក់ព័ន្ធនឹងវិស័យធនធានរ៉ែ (៨) គ្រប់គ្រងច្បាប់ បរិស្ថាន និងប្រើប្រាស់វត្ថុធាតុដើមឱ្យចំទិសដៅ (៩) គ្រប់គ្រង អនុវត្តន៍ សិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយទិន្នន័យភូគព្ភសាស្ត្រ (១០) ចូលរួមសិក្សាស្រាវជ្រាវប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី និងវាយតម្លៃរៀបចំអនុវត្តន៍គម្រោងប្រព័ន្ធអគ្គិសនីណាដែលផលិតថាមពលអគ្គិសនី ជាគោល-បំណងចម្បង (១១) ចូលរួមអនុវត្តន៍ការងារពាក់ព័ន្ធនឹងអាងទន្លេមេគង្គស្របតាមភារកិច្ចរបស់មន្ទីរ (១២) ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ៩ខែ ឆ្នាំមកក្រសួងតាមកម្មវិធីកំណត់ (១៣) សិក្សាវាយតម្លៃ ប្រសិទ្ធិភាព និងផលប៉ះពាល់នៃគោលនយោបាយ កម្មវិធីការងារ និងការអនុវត្តបញ្ញត្តិកម្មនានាក្នុងវិស័យរ៉ែ និងថាមពល ចំពោះជីវភាពសង្គម និងសេដ្ឋកិច្ច របស់សហគមន៍មូលដ្ឋាន និងរាជធានី ខេត្ត (១៤) សម្របសម្រួល និងជំរុញកិច្ចសហប្រតិបត្តិការរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តគោលនយោបាយ ផែនការការងារ និងគោលនយោបាយច្បាប់ពាក់ព័ន្ធនិងវិស័យរ៉ែ និងថាមពល(១៥) ចូលរួមរៀបចំ អនុវត្តសកម្មភាពយេនឌ័រក្នុងវិស័យរ៉ែ និងថាមពល (១៦) អនុវត្តន៍ភារកិច្ចផ្សេងទៀតអនុលោមតាមប្រកាសប្រតិភូកម្មការងាររបស់ក្រសួងរ៉ែ និងថាមពល[46]។

រចនាសម្ព័ន្ធរបស់មន្ទីររ៉ែ និងថាមពលតាមបណ្តារាជធានីខេត្ត ត្រូវបានរៀបចំចេញជា ០៤ ការិយាល័យ ដូចជា ការិយាល័យរដ្ឋបាល បុគ្គលិក ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ ការិយាល័យធនធានរ៉ែ និងការិយាល័យថាមពល និងប្រេងកាត[47]។ ចំពោះតួនាទី និងភារកិច្ចរបស់ការិយាល័យក្រោមចំណុះរបស់មន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត ត្រូវបានធ្វើការបែងចែកដូចខាងក្រោម៖

### ២.១.១. ការិយាល័យរដ្ឋបាល បុគ្គលិក

បំពេញតួនាទីជាសេនាធិការជំនួយការឱ្យថ្នាក់ដឹកនាំមន្ទីរលើកិច្ចការរដ្ឋបាល សន្តិសុខ ការងារបុគ្គលិក

[46] ប្រការ៣ នៃប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមន្ទីររ៉ែថាមពលរាជធានីខេត្ត

[47] យោងប្រការ៥ ថ្មី ប្រកាសស្តីពីការកែសម្រួលប្រការ៥ ប្រការ៦ និងតារាងឧបសម្ព័ន្ធនៃប្រកាសលេខ ០៩២ រថ.បល.ប្រក ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមន្ទីររ៉ែ និងថាមពលរាជធានី ខេត្ត

បៀវត្សពលកម្ម។ ទន្ទឹមនឹងនេះ ការិយាល័យរដ្ឋបាល បុគ្គលិក មានភារកិច្ចដូចជា (១) សម្របសម្រួល សកម្មភាពគ្រប់ផ្នែករបស់មន្ទីរនៅថ្នាក់ខេត្ត និងរវាងថ្នាក់ខេត្តរបស់មន្ទីរជាមួយក្រសួង និងជាមួយថ្នាក់ ខណ្ឌ ក្រុង ស្រុក (២) គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗ របស់មន្ទីរ (៣) ធានាប្រសិទ្ធិភាព សុវត្ថិភាព រដ្ឋបាល អនាម័យ និងគ្រប់គ្រងការងារសង្គមរបស់មន្ទីរ (៤) គ្រប់គ្រងយានជំនិះគ្រប់ប្រភេទរបស់រដ្ឋដែលប្រគល់ជូនមន្ទីរ ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ ទទួល និងបែងចែកសំភារៈបរិក្ខាជូនដល់បណ្តាអង្គភាព និងសាខាសមត្ថកិច្ចជំនាញ (៥) រៀបចំលិខិតបទដ្ឋានគ្រប់គ្រងមន្ត្រីរាជការក្របខណ្ឌ កម្លាំងពលកម្មរបស់មន្ទីរដោយទំនាក់ទំនងជាមួយក្រសួង (៦) អនុវត្តការងារបៀវត្សពលកម្ម ប្រាក់បៀវត្ស ប្រាក់កម្រៃ របបឧបត្ថម្ភ របបធានារ៉ាប់រងសង្គម គោលនយោបាយ សង្គម ជូនមន្ត្រីរាជការក្នុងមន្ទីរ (៧) រៀបចំសំណើតែងតាំង ដំឡើងថ្នាក់មន្ត្រីរាជការ ព្រមទាំងការផ្តល់គ្រឿងឥស្សរិយយសលើកសរសើរ ឬដាក់វិន័យ (៨) រៀបចំគម្រោងផែនការបណ្តុះបណ្តាលមន្ត្រីរាជការ ដោយទំនាក់ទំនងជាមួយក្រសួង និងតាមដានត្រួតពិនិត្យការអនុវត្ត (៩) គ្រប់គ្រងសំណុំលិខិតឯកសារ មន្ត្រីរាជការក្នុងមន្ទីរ (១០) សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់មន្ទីរ។

### ២.១.២. ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ

បំពេញតួនាទីជាសេនាធិការជំនួយការឱ្យថ្នាក់ដឹកនាំមន្ទីរលើកិច្ចការគណនេយ្យ និងហិរញ្ញវត្ថុ និងមានភារកិច្ចមួយចំនួនដូចជា (១) ប្រមូលចំណូលឱ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ ដែលបានកំណត់ (២) លើកគម្រោងថវិការបស់មន្ទីរ និងតាមដានរំលឹកពីការប្រតិបត្តិ (៣) ប្រមូលផ្តុំ និងសម្របសម្រួលជំពូកថវិកា (៤) តាមដានរំលឹកការគ្រប់គ្រងគណនីពិសេស (៥) ប្រមូលផ្តុំ និងសម្របសម្រួលរាល់ការចំណាយរបស់មន្ទីរ (៦) ប្រមូលផ្តុំតម្រូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំជួសជុលសំភារៈ និងបរិក្ខាររបស់មន្ទីរ (៧) គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើព័ណ្ឌ (៨) កាន់បញ្ជីជាប្រចាំនូវសោលាប័ត្រ និងគណនេយ្យរូបធាតុ (៩) ព័ត៌មានវិទ្យា សកម្មភាពហិរញ្ញវត្ថុ និងបន្ទុកគណនី (១០) ត្រួតពិនិត្យបច្ចេកទេសផែនការប្រតិបត្តិលទ្ធកម្មសាធារណៈ (១១) គ្រប់គ្រងបន្ទុកគណនី និងការអនុវត្តលទ្ធកម្មសាធារណៈ។

### ២.១.៣. ការិយាល័យធនធានរ៉ែ

បំពេញតួនាទីជាសេនាធិការជំនួយការឱ្យថ្នាក់ដឹកនាំមន្ទីរលើការងារធនធានរ៉ែ ភូគព្ភសាស្ត្រ និងការងារអភិវឌ្ឍធនធានរ៉ែ និងមានភារកិច្ចមួយចំនួនដូចជា (១) សិក្សា ប្រមូលចងក្រងទិន្នន័យ និងព័ត៌មាន អំពីស្ថានភាពមូលដ្ឋាន ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍមូលដ្ឋាន និងចូលរួមផ្តល់មតិក្នុងការរៀបចំ និងអនុវត្តគោលនយោបាយ និងផែនការវិស័យរ៉ែ ពាក់ព័ន្ធនឹងដែនដីរាជធានី ខេត្ត (២) ធ្វើបណ្ណាល័យគំរូរ៉ែ ដែលខ្លួនមានក្នុងទឹកដី រាជធានី ខេត្ត (៣) ចងក្រងឯកសាររ៉ែ និងក្រុមហ៊ុនរ៉ែ ដែលអនុវត្តន៍បានក្នុងទឹកដីដែលខ្លួនគ្រប់គ្រង (៤) សិក្សា និងចូលរួមផ្តល់មតិរៀបចំ និងសមាហរណកម្មសកម្មភាពអភិវឌ្ឍវិស័យរ៉ែ ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច

សង្គម និងការប្រើប្រាស់ដីធ្លីនៅមូលដ្ឋាន រាជធានី ខេត្ត (៥) គ្រប់គ្រង និងអនុវត្តការផ្សព្វផ្សាយគោលនយោបាយ នីតិវិធី លិខិតបទដ្ឋាន និងបទប្បញ្ញត្តិនានាក្នុងវិស័យរ៉ែ និងការការពារបរិស្ថាន (៦) ចូលរួមជាមួយមន្ត្រីជំនាញរបស់ក្រសួងដើម្បីត្រួតពិនិត្យ ការសិក្សា ស្រាវជ្រាវ រុករកអភិវឌ្ឍ ការជីកយក ប្រព្រឹត្តកម្ម ការបន្សុទ្ធ និងអាជីវកម្មលើវិស័យរ៉ែ (៧) អនុវត្តវិធានការអប់រំ និងបញ្ជ្រាបការយល់ដឹងជាសាធារណៈដល់សហគមន៍នៅក្នុងតំបន់ជុំវិញជិតខាងការដ្ឋានរ៉ែ (៨) អនុវត្តន៍វិធានការទប់ស្កាត់ និងបង្ក្រាបអាជីវកម្មរ៉ែអនាធិបតេយ្យ (៩) គ្រប់គ្រងអនុវត្តន៍សិក្សាស្រាវជ្រាវ ផ្សព្វផ្សាយទិន្នន័យភូគព្ភសាស្ត្រ (១០) រៀបចំចងក្រង បូកសរុបរបាយការណ៍ការងារវិស័យរ៉ែនៅក្នុងរាជធានី ខេត្ត (១១) សហការជាមួយក្រសួង ដើម្បីរៀបចំកម្មវិធីបណ្តុះបណ្តាលធនធានមនុស្សលើជំនាញដែលចាំបាច់បម្រើការងារឱ្យការងារធនធានរ៉ែ និងភូគព្ភសាស្ត្រ (១២) អនុវត្តភារកិច្ចមួយចំនួនទៀតតាមប្រកាសប្រតិភូកម្មការងារក្នុងវិស័យរ៉ែ ក្រសួងរ៉ែ និងថាមពល។

### ២.១.៤. ការិយាល័យថាមពល និងប្រេងកាត

បំពេញតួនាទីជាសេនាធិការជំនួយការឱ្យថ្នាក់ដឹកនាំមន្ទីរក្នុងវិស័យថាមពល លើការងារអភិវឌ្ឍថាមពល ការងារថាមពលកកើតឡើងវិញ និងថាមពលថ្មី វារីអគ្គិសនី និងការងារបច្ចេកទេស បច្ចេកវិទ្យាថាមពល និងការងារថាមពលបរមាណូ និងប្រេងកាត។ បន្ថែមពីនេះ ការិយាល័យថាមពល និងប្រេងកាតមានភារកិច្ចដូចខាងក្រោម ៖

**ក. ការងារអភិវឌ្ឍថាមពល** បំពេញទៅលើការងារដូចជា (១) ចូលរួមសិក្សារៀបចំ និងអនុវត្តគោល-នយោបាយយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍវិស័យថាមពល ថាមពលអគ្គិសនី និងអគ្គិសនីភាវូបនីយកម្មជនបទដោយសហប្រតិបត្តិការជាមួយមន្ទីរជំនាញពាក់ព័ន្ធ អាជ្ញាធរដែនដី និងជាមួយអង្គការអន្តរជាតិ (២) ចូលរួមជំរុញការអភិវឌ្ឍ និងអនុវត្តន៍បច្ចេកទេសវិទ្យាសាស្ត្រ ដែលពាក់ព័ន្ធនឹងថាមពលអគ្គិសនី (៣) ចូលរួមជំរុញការអនុវត្តលិខិតបទដ្ឋានផ្សេងៗ ពាក់ព័ន្ធនឹងវិស័យថាមពល អគ្គិសនី និងថាមពលផ្សេងៗទៀត (៤) ចូលរួមសិក្សាវាយតម្លៃ និងប្រមូលទិន្នន័យលើសក្តានុពលធនធានថាមពល សេចក្តីត្រូវការថាមពល ដើម្បីជាមូលដ្ឋានសម្រាប់បម្រើដល់ការអភិវឌ្ឍវិស័យថាមពលក្នុងរាជធានី-ខេត្ត។

**ខ. ការងារថាមពលកកើតឡើងវិញ និងថាមពលថ្មី** បំពេញទៅលើការងារដូចជា (១) ចូលរួមផ្សព្វផ្សាយ និងអនុវត្តគោលការណ៍សន្សំសំចៃ ប្រសិទ្ធិភាព និងអភិរក្សថាមពល (២) ចូលរួមសហការសិក្សាស្រាវជ្រាវប្រសិទ្ធិភាពប្រព័ន្ធផ្គត់ផ្គង់ និងចែកចាយថាមពលនៅក្នុងតំបន់របស់ខ្លួន (៣) ចូលរួមសហការ និងសិក្សាស្រាវជ្រាវរុករក និងកំណត់សក្តានុពលក្នុងការអភិវឌ្ឍវិស័យថាមពល ដោយកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ដល់សង្គម និងបរិស្ថាន (៤) ចូលរួមសិក្សាស្រាវជ្រាវ និងពិសោធន៍រកបច្ចេកវិទ្យាថាមពលថ្មី ដោយសហការជាមួយស្ថាប័នជាតិ និងអន្តរជាតិ (៥) ចូលរួមត្រួតពិនិត្យ និងតាមដានការធ្វើអាជីវកម្ម សេវាកម្មអគ្គិសនី លើ

លក្ខណៈបច្ចេកទេស (៦) ចូលរួមសិក្សា ប្រមូលទិន្នន័យពាក់ព័ន្ធនឹងវិស័យថាមពលកកើតឡើងវិញ ថាមពលថ្មី និងប្រសិទ្ធិភាពថាមពល។

**គ. ការងារវារីអគ្គិសនី** បំពេញទៅលើការងារដូចជា (១) ចូលរួមអនុវត្តគោលនយោបាយថាមពលជាតិដែលទាក់ទងនឹងវារីអគ្គិសនី (២) ចូលរួមប្រមូល និងរក្សាទុកប្រើប្រាស់នូវរាល់ទិន្នន័យ សម្រាប់ការសិក្សា និងការអភិវឌ្ឍវិស័យវារីអគ្គិសនី (៣) ចូលរួមសិក្សា ជ្រើសរើសទីតាំង គម្រោងអាទិភាព (៤) ចូលរួមអនុវត្តន៍នូវផែនការអភិវឌ្ឍវារីអគ្គិសនី និងត្រួតពិនិត្យ តាមដានការអភិវឌ្ឍសាងសង់គម្រោង ស្ថានីយវារីអគ្គិសនីក្នុងតំបន់របស់ខ្លួន (៥) ចូលរួមសហការជាមួយស្ថាប័នជាតិ និងអន្តរជាតិក្នុងការពិនិត្យវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គមក្នុងវិស័យថាមពល។

**ឃ. ការងារបច្ចេកទេសថាមពល និងកិច្ចការថាមពលបរមាណូ** បំពេញទៅលើការងារដូចជា (១) អនុវត្តន៍គោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិដែលទាក់ទងបច្ចេកទេសថាមពល និងថាមពលបរមាណូ (២) ចូលរួមអនុវត្តន៍ តាមដាន ត្រួតពិនិត្យការនាំចេញ នាំចូល ការដឹកជញ្ជូន ការឆ្លងកាត់ ការប្រើប្រាស់ ប្រភពសាធាតុ និងឧបករណ៍សម្ភារបរិក្ខារថាមពលបរមាណូ និងវិទ្យុសកម្ម (៣) ចូលរួមផ្សព្វផ្សាយអំពីការការពារសុវត្ថិភាព សុខ-មាលភាពមនុស្ស សត្វក្នុងការប្រើប្រាស់ឧបករណ៍សម្ភារៈបរិក្ខារវិទ្យុសកម្ម (៤) ចូលរួមសិក្សាស្រាវជ្រាវអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកទេសថាមពល (៥) ចូលរួមសហការរៀបចំបទដ្ឋាន ស្តង់ដារ និងសុវត្ថិភាពថាមពល។

**ង. ការងារប្រេងកាត** បំពេញទៅលើការងារដូចជា (១) សិក្សាប្រមូលចងក្រងទិន្នន័យ និងព័ត៌មានអំពីស្ថានភាពមូលដ្ឋាន ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍមូលដ្ឋាន និងចូលរួមផ្តល់មតិក្នុងការរៀបចំ និងអនុវត្តគោល-នយោបាយ និងផែនការវិស័យប្រេងកាត និងឧស្ម័ន ពាក់ព័ន្ធដែនដីរាជធានី ខេត្ត (២) សិក្សា និងចូលរួមផ្តល់មតិក្នុងការរៀបចំ និងសមាហរណកម្មសកម្មភាពអភិវឌ្ឍវិស័យប្រេងកាត និងឧស្ម័នទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ចសង្គម នៅមូលដ្ឋានរាជធានី ខេត្ត (៣) គ្រប់គ្រង និងអនុវត្តការផ្សព្វផ្សាយគោលនយោបាយនីតិវិធី លិខិតបទដ្ឋាន និងបទប្បញ្ញត្តិនានាក្នុងវិស័យប្រេងកាត និងឧស្ម័ន និងការពារបរិស្ថាន (៤) ចូលរួមជាមួយមន្ត្រីជំនាញរបស់ក្រសួងដើម្បីត្រួតពិនិត្យ ការសិក្សាស្រាវជ្រាវ រុករក អភិវឌ្ឍ ការជីកយក ប្រព្រឹត្តកម្ម ការបន្សុទ្ធ និងអាជីវកម្ម លើវិស័យប្រេងកាត និងឧស្ម័ន (៥) ចូលរួមវាយតម្លៃ និងផ្តល់អនុសាសន៍ទាក់ទងការគ្រប់គ្រងការបើកស្ថានីយ និងឃ្លាំងស្តុកប្រេង និងឧស្ម័នឥន្ធនៈ (៦) រៀបចំចងក្រងបូកសរុបរបាយការណ៍ការងារវិស័យប្រេងកាត និងឧស្ម័ន ក្នុងរាជធានីខេត្ត (៧) សហការជាមួយក្រសួងដើម្បីរៀបចំកម្មវិធីបណ្តុះបណ្តាលធនធានមនុស្សលើជំនាញ ដែលចាំបាច់បម្រើឱ្យការងារធនធានប្រេងកាត (៨) អនុវត្តភារកិច្ចមួយចំនួនទៀត

តាមប្រកាសប្រតិភូកម្មការងារក្នុងវិស័យប្រេងកាត និងឧស្ម័ន របស់ក្រសួងរ៉ែ និងថាមពល[48]។

## ២.២.ថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

នៅក្នុងថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ គឺសំដៅដល់ការិយាល័យរ៉ែ និងថាមពល ដែលជាសាខាសមត្ថកិច្ចជំនាញ ទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពរបស់មន្ទីរ។ ចំពោះការរៀបចំ និងការប្រព្រឹត្តទៅការិយាល័យរ៉ែ និងថាមពល ក្រុង ស្រុង ខណ្ឌ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានមន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត[49]។

[48] ប្រការ៦ថ្មី នៃប្រកាសការកែសម្រួលប្រកាល៥ ប្រការ៦ និងតារាងឧបសម្ព័ន្ធនៃប្រកាសលេខ០៩២ រថ.បល.ប្រក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ ស្តីពីរៀបចំ និងការប្រព្រឹត្តទៅនៃមន្ទីររ៉ែថាមពលរាជធានី-ខេត្ត

[49] យោងប្រការ៧ និងមាត្រា៨ នៃប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត

# ជំពូកទី៣
# សមិទ្ធផល បញ្ហាប្រឈម ដំណោះស្រាយ និងផែនការសកម្មភាព

## ១.សមិទ្ធផល

នៅក្នុងនីតិកាលទី៦ នៃរដ្ឋសភានេះ រាជរដ្ឋាភិបាល បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលតម្រូវឱ្យក្រសួងរ៉ែ និងថាមពលអនុវត្តការងារពាក់ព័ន្ធការអភិវឌ្ឍវិស័យឧស្សាហកម្មនិស្សារណកម្ម (រ៉ែ និងប្រេងកាត) ជាមួយនឹងការគ្រប់គ្រងធនធានទាំងនេះប្រកបដោយចីរភាព និងប្រសិទ្ធិភាព និងការគ្រប់គ្រង និងអភិវឌ្ឍវិស័យថាមពល ជាពិសេសថាមពលអគ្គិសនីដែលជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ និងជាចលករនៃឃ្មាស់សេដ្ឋកិច្ចជាតិទាំងមូល។ តាមរយៈយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ខាងលើ វិស័យថាមពលស្ថិតក្នុងចតុកោណទី២ មុំទី១ អាទិភាពទី៣ <<ការបន្តបញ្ចុះថ្លៃអគ្គិសនី ពង្រីកបណ្តាញគ្របដណ្តប់ និងការបង្កើនស្ថិរភាពអគ្គិសនី ដោយសាងសង់អនុស្ថានីយបន្ថែមឱ្យដល់តំបន់ប៉ូលសេដ្ឋកិច្ច និងតំបន់សក្តានុពលសេដ្ឋកិច្ចខ្ពស់ ក្នុងចតុកោណទី៣ មុំទី១ អាទិភាពទី៧ <<ការបន្តពង្រីកការតបណ្តាញអគ្គិសនីដោយតម្លៃទាបជូនកម្មករ និយោជិត សិស្ស និស្សិតនៅតាមផ្ទះជួល>> ក្នុងចតុកោណទី៤ មុំទី១ អាទិភាពទី១០ <<ការបន្តជំរុញការអភិវឌ្ឍជនបទឱ្យរស់រវើក ដោយបន្តពង្រីកការគ្របដណ្តប់ការប្រើប្រាស់អគ្គិសនី>> និងមុំទី៤ អាទិភាពទី៨ <<ការបន្តលើកទឹកចិត្ត និងបង្កើនការវិនិយោគលើថាមពលស្អាត និងថាមពលកកើតឡើងវិញ ជាពិសេសថាមពលពន្លឺព្រះអាទិត្យ ទន្ទឹមនឹងការកាត់បន្ថយការផលិតថាមពលប្រភពមិនស្អាត ដើម្បីធានាសន្តិសុខថាមពលរយៈពេលវែង>>។ រីឯវិស័យរ៉ែស្ថិតក្នុងចតុកោណទី៤ មុំទី២ អាទិភាពទី១ <<ជំរុញការអនុវត្ត (គោល-នយោបាយជាតិស្តីពីធនធានរ៉ែឆ្នាំ២០១៨-២០២៨ ដោយពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងធនធាន និងអាជីវកម្មរ៉ែ ទន្ទឹមនឹងការជំរុញការចូលរួមពីសហគមន៍ដើម្បីកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន សង្គម និងពង្រឹងការប្រមូលចំណូលថវិកាជាតិ>> និងអាទិភាពទី២ <<ការពង្រឹងយន្តការគ្រប់គ្រងធនធាន និងអាជីវកម្មខ្សាច់ដោយកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម>>។ ចំពោះវិស័យប្រេងកាត ស្ថិតក្នុងចតុកោណទី២ មុំទី២ អាទិភាពទី៦ <<ការជំរុញការអភិវឌ្ឍវិស័យប្រេងកាត និងឧស្ម័នជាពិសេសការដាក់ដំណើរការអណ្តូងប្រេងដំបូងឱ្យបានឆាប់ ទន្ទឹមគ្នានឹងការពង្រឹងការគ្រប់គ្រងចំណូល ដែលបានមកពីធនធានទាំងនេះប្រកបដោយប្រសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព>>។

តាមរយៈផែនការសកម្មភាពយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ខាងលើនេះ ក្រសួងរ៉ែ និងថាមពលបានខិតខំប្រឹងប្រែងអនុវត្តការងារ ប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ ដែលជាលទ្ធផលក្រសួងសម្រេចបាននូវផ្លែផ្កាដូចខាងក្រោមនេះ៖

### ១.១. វិស័យថាមពល

ក្នុងរយៈពេល៥ឆ្នាំ ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ ការអភិវឌ្ឍវិស័យថាមពលរបស់រាជរដ្ឋាភិបាល ក្នុងក្របខណ្ឌនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នីតិកាលទី៦នៃរដ្ឋសភា បានទទួលនូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដូចខាងក្រោម៖

#### ១.១.១. តម្លៃអគ្គិសនី និងការងារសង្គមកិច្ច

**ក.ការបន្ថយថ្លៃ និងការអនុគ្រោះថ្លៃអគ្គិសនី**

- ទិញពីទ្វារចរន្តតង់ស្យុងខ្ពស់ ត្រូវបានកាត់បន្ថយពី ០,១២៤០ ដុល្លារក្នុងមួយគីឡូវ៉ាត់ម៉ោង ($/kWh) នៅឆ្នាំ២០១៧ មក ០,១១៧០ ដុល្លារក្នុងមួយគីឡូវ៉ាត់ម៉ោង ($/kWh) នៅឆ្នាំ២០២១។
- ទិញពីទ្វារចរន្តតង់ស្យុងមធ្យម ត្រូវបានកាត់បន្ថយពី ០,១២៦០ $/kWh នៅឆ្នាំ២០១៧ មក ០,១២១០ $/kWh នៅឆ្នាំ២០២១។
- ឧស្សាហកម្ម និងកសិកម្មភ្ជាប់ពីខ្សែបណ្តាញតង់ស្យុងមធ្យម ត្រូវបានកាត់បន្ថយពី ០,១៦៥០ $/kWh នៅឆ្នាំ២០១៧ មក ០,១៣៧០ $/kWh នៅឆ្នាំ២០២១។
- ពាណិជ្ជកម្ម និងរដ្ឋបាលភ្ជាប់ពីខ្សែបណ្តាញតង់ស្យុងមធ្យម ត្រូវបានកាត់បន្ថយពី ០,១៦៥០ $/kWh នៅឆ្នាំ២០១៧ មក ០,១៥៨០ $/kWh នៅឆ្នាំ២០២១។
- ឧស្សាហកម្ម និងកសិកម្មភ្ជាប់ពីក្រោមតង់ស្យូចែកចាយ ត្រូវបានកាត់បន្ថយពី ០,១៧១៩ $/kWh នៅឆ្នាំ២០១៧ មក ០,១៤២៤៨ $/kWh នៅឆ្នាំ២០២១។
- ពាណិជ្ជកម្ម និងរដ្ឋបាលភ្ជាប់ពីក្រោមត្រង់ស្វូចែកចាយ ត្រូវបានកាត់បន្ថយពី ០,១៧១៩ $/kWh នៅឆ្នាំ២០១៧ មក ០,១៦៤៣ $/kWh នៅឆ្នាំ២០២១។
- អ្នកប្រើប្រាស់ទូទៅទិញពីខ្សែបណ្តាញចែកចាយតង់ស្យុងទាប ត្រូវបានកាត់បន្ថយពី ៧៧០ រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង (៛/kWh) នៅឆ្នាំ២០១៧ មក ៧៣០ រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង (៛/kWh) នៅឆ្នាំ២០២១។

ដើម្បីសម្រេចបានការកាត់បន្ថយថ្លៃអគ្គិសនីខាងលើ រាជរដ្ឋាភិបាលបានចំណាយថវិកា ១ ៤៦៥,៨ ពាន់លានរៀល ស្មើនឹង ៥ ៥២៥,៤ លានគីឡូវ៉ាត់ម៉ោង ក្នុងការអនុវត្តឧបត្ថម្ភធនដល់គ្រួសារក្រីក្រនៅតំបន់ជនបទចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២០។

**ខ.ការងារសង្គមកិច្ចក្នុងវិស័យថាមពល**

រាជរដ្ឋាភិបាល បានបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ (ម.អ.ជ.) ចំណុះក្របខណ្ឌអគ្គិសនី

កម្ពុជា ដើម្បីជួយផ្តល់នូវកម្មវិធីគាំពារសង្គមក្នុងវិស័យថាមពល ដែលក្នុងរយៈពេល៥ឆ្នាំ គិតចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ ម.អ.ជ. បានអនុវត្តកម្មវិធីរួមមាន៖

- ផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយការផ្តល់ប្រាក់កម្ចីអនុគ្រោះគ្មានការប្រាក់ ដើម្បីជួយដល់គ្រួសារក្រីក្របង់ថ្លៃសេវាភ្ជាប់ចរន្តអគ្គិសនី ថ្លៃប្រាក់កក់ឱ្យអ្នកផ្គត់ផ្គង់ ចំណាយលើការទិញ និងរាយខ្សែពីចំណុចភ្ជាប់ចរន្តមកដល់ផ្ទះ និងចំណាយលើការរៀបចំខ្សែបណ្តាញ និងឧបករណ៍អគ្គិសនីក្នុងផ្ទះ ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលក្នុងផ្ទះ។ ប្រាក់កម្ចីនេះ គឺមិនលើសពី ៤៨០ ០០០ រៀល ក្នុងមួយគ្រួសារ ដែលមានគ្រួសារជនបទចំនួន ៨៥១គ្រួសារ ស្មើនឹង ៣ ៩១៥ នាក់ បានទទួលផលប្រយោជន៍ដោយផ្ទាល់ក្រោមកម្មវិធីនេះ។
- កម្មវិធីផ្តល់ចរន្តដល់គ្រួសារក្រីក្រ ដោយផ្តល់ថវិកាឧបត្ថម្ភធនសម្រាប់ការចំណាយលើសម្ភារៈ និងឈ្នួលពលកម្ម ដើម្បីតភ្ជាប់អគ្គិសនីចូលក្នុងផ្ទះ។ កម្មវិធីនេះ មានគ្រួសារជនបទក្រីក្រ ចំនួន ២០ ៣១៩ គ្រួសារ ស្មើនឹង ៩៣ ៤៩៨ នាក់ បានទទួលផលប្រយោជន៍ដោយផ្ទាល់។
- កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះដោយផ្តល់ប្រាក់ឧបត្ថម្ភធនចំនួន ១០០ ដុល្លារអាមេរិកក្នុងមួយប្រព័ន្ធ ដល់គ្រួសារជនបទដែលបានទិញប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ។ កម្មវិធីនេះមានគ្រួសារជនបទចំនួន ៦៩ ២៧៤ គ្រួសារ (១គ្រួសារ ១ប្រព័ន្ធ) ស្មើនឹង ៣១៨ ៦៦០ នាក់ បានទទួលផលប្រយោជន៍ដោយផ្ទាល់នៅក្នុងភូមិចំនួន៦៩៧ភូមិ។
- កម្មវិធីផ្តល់ការផ្គត់ផ្គង់អគ្គិសនី ដើម្បីបូមទឹកធ្វើកសិកម្ម និងអ្នកប្រើប្រាស់ផ្សេងទៀតក្នុងវិស័យកសិកម្មនូវតម្លៃអនុគ្រោះត្រឹមតែ ៤៨០ រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោងសម្រាប់ការប្រើប្រាស់ពីម៉ោង៩យប់ ដល់ម៉ោង៧ព្រឹក។ មកទល់ពេលនេះបានសាងសង់ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី ដើម្បីបូមទឹកក្នុងវិស័យកសិកម្មដល់អ្នកកាន់អាជ្ញាបណ្ណចំនួន ១៥ តំបន់ សរុបបានប្រវែង ៥៣៨ គ.ម. រួមមានខ្សែបណ្តាញតង់ស្យុងមធ្យម ប្រវែង ២៣៣ គ.ម. និងខ្សែចែកចាយតង់ស្យុងទាប ប្រវែង ៣០៥ គ.ម. ដែលគ្របដណ្តប់លើខេត្តចំនួន ៦ បានទទួលផលប្រយោជន៍ដោយផ្ទាល់។ បន្ថែមពីលើនោះរាជរដ្ឋាភិបាល ក៏បានធ្វើការអនុគ្រោះថ្លៃអគ្គិសនីឱ្យលំនៅឋានដែលប្រើប្រាស់ថាមពល មិនលើសពី ១០ គីឡូវ៉ាត់ម៉ោងក្នុងមួយខែ ឱ្យបង់ថ្លៃ ៣៨០ រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង និងលំនៅឋានដែលប្រើប្រាស់ពី១១ ដល់ ៥០ គីឡូវ៉ាត់ម៉ោង ក្នុងមួយខែ ឱ្យបង់ថ្លៃ ៤៨០ រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង និងលំនៅឋានដែលប្រើប្រាស់ពី៥១ ដល់ ២០០ គីឡូវ៉ាត់ម៉ោងក្នុងមួយខែ ឱ្យបង់ថ្លៃ ៦១០ រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង។ សាលារៀន មន្ទីរពេទ្យ និងមណ្ឌលសុខភាពនៅជនបទឱ្យបង់ថ្លៃត្រឹម ៦១០ រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង។ ដើម្បី

រួមចំណែកលើកស្ទួយក្នុងវិស័យការងារ រាជរដ្ឋាភិបាលបានជំរុញការពង្រីកខ្សែបណ្តាញអគ្គិសនី ដោយតម្លៃទាបជូនកម្មករ និយោជិត សិស្ស និស្សិត នៅតាមផ្ទះជួល បន្ទប់ជួល ដោយគិតមកដល់ត្រឹមចុងឆ្នាំ២០២១ បានចំនួន ៣៤៩ ៨៥៨ បន្ទប់ជួល។

### ១.១.២. ការពង្រីកតំបន់គ្របដណ្តប់

#### ក.ការអភិវឌ្ឍប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនី

ប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនី (បណ្តាញជាតិ) មានហេដ្ឋារចនាសម្ព័ន្ធសំខាន់ចំនួន៣ គឺបណ្តាញបញ្ជូនតង់ស្យុងខ្ពស់ អនុស្ថានីយ និងមជ្ឈមណ្ឌលបញ្ជា។ ការអភិវឌ្ឍប្រព័ន្ធបណ្តាញបញ្ជូនក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ បានធ្វើឱ្យខ្សែបណ្តាញបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់កម្ពុជាកើតឡើងពី ១ ៩៥៧ គ.ម. នៅឆ្នាំ ២០១៧ រហូតដល់ ៣ ៥៥៣ គ.ម. នៅឆ្នាំ២០២១ កំណើនប្រមាណ ៨១,៦% និងធ្វើឱ្យចំនួនអនុស្ថានីយ កើនឡើងពី ៣០ កន្លែង នៅឆ្នាំ២០១៧ រហូតដល់ ៥៥ កន្លែង នៅឆ្នាំ២០២១ កំណើនប្រមាណ ៨៣,៣% ដែលធ្វើឱ្យការផ្គត់ផ្គង់អគ្គិសនីរបស់បណ្តាញជាតិគ្របដណ្តប់ត្រឹមតែ១៩រាជធានី ខេត្តនៅឆ្នាំ ២០១៧ ឡើងដល់ ២៤ រាជធានីខេត្ត នៅឆ្នាំ២០២១ (នៅសល់ខេត្តប៉ៃលិនមួយប៉ុណ្ណោះ) ដែលកំណើននេះបានបង្កើនស្ថិរភាព គុណភាព និងនិរន្តភាពនៃការផ្គត់ផ្គង់អគ្គិសនី។ តាមរយៈកម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ មានអ្នកកាន់អាជ្ញាបណ្ណចំនួន ២៥៨ ស្មើនឹង ៨ ៤៦៧,៦៩ គ.ម. រួមមានខ្សែបណ្តាញតង់ស្យុងមធ្យមប្រវែង ២ ៨៨២,៥៩ គ.ម. និងខ្សែចែកចាយតង់ស្យុងទាបប្រវែង ៥ ៥៨៥,១០ គ.ម ដោយគ្របដណ្តប់ចំនួន ២៣ ខេត្ត បានទទួលផលប្រយោជន៍ដោយផ្ទាល់។

#### ខ.ការអភិវឌ្ឍប្រព័ន្ធបណ្តាញបញ្ជូនរង និងប្រព័ន្ធចែកចាយអគ្គិសនី

ការអភិវឌ្ឍប្រព័ន្ធបណ្តាញបញ្ជូនរង និងប្រព័ន្ធចែកចាយអគ្គិសនី ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ បានធ្វើឱ្យប្រវែងខ្សែបណ្តាញតង់ស្យុងមធ្យមកើនឡើងពី ២៨ ៩៧៥ គ.ម. នៅឆ្នាំ២០១៧ រហូតដល់ ៤១ ៤៨៨ គ.ម. នៅឆ្នាំ២០២១ និងដែលធ្វើឱ្យប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងទាបកើនឡើងពី ២៧ ៨៦២ គ.ម. នៅឆ្នាំ ២០១៧ រហូតដល់ ៤៣ ៩៤២ គ.ម. នៅឆ្នាំ២០២១។ ការអភិវឌ្ឍខ្សែបណ្តាញបញ្ជូនរង និងខ្សែបណ្តាញចែកចាយអគ្គិសនីលឿននេះ បានធ្វើឱ្យការគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនីរបស់បណ្តាញជាតិ បានកើនឡើងពី ១១ ៥៥៨ ភូមិ ត្រូវជា ៨១,៥៨% នៃចំនួនភូមិទូទាំងប្រទេស នៅឆ្នាំ២០១៧ ឡើងដល់ ១៣ ៨១៨ ភូមិ ត្រូវជា ៩៧,៥៣% នៃចំនួនភូមិទូទាំងប្រទេសនៅឆ្នាំ២០២១នេះ។ ការអភិវឌ្ឍខ្សែបណ្តាញបញ្ជូនរង និងខ្សែបណ្តាញចែកចាយអគ្គិសនីដ៏លឿននេះក៏បានធ្វើឱ្យការភ្ជាប់ចរន្តឱ្យអ្នកប្រើប្រាស់អគ្គិសនីគ្រប់ប្រភេទកើនឡើងពី ២ ៤០៩ ៩០៧ ទីតាំង នៅឆ្នាំ២០១៧ រហូតដល់ ៣ ៣១៣ ៦០៧ ទីតាំង នៅឆ្នាំ២០២១ ដែលនៅក្នុងនោះការភ្ជាប់ចរន្តឱ្យលំនៅឋានរបស់ប្រជាពលរដ្ឋបានកើនឡើងពី ២ ៣១៥ ៩៣០ ខ្នងផ្ទះ នៅឆ្នាំ២០១៧ រហូតដល់ ៣ ១២៣ ០៩៦ ខ្នងផ្ទះ នៅឆ្នាំ

២០២១។ តាមស្ថិតិចំនួនខ្នងផ្ទះសរុបទូទាំងប្រទេស ៣,១៦ លានខ្នងផ្ទះ ក្នុងនោះ ខ្នងផ្ទះដែលទទួលបានការផ្គត់ផ្គង់អគ្គិសនីនៅឆ្នាំ២០២១ មានចំនួន ៨៦,៤៣% រួចហើយ។ ដោយឡែកភូមិពុំទាន់មានការផ្គត់ផ្គង់អគ្គិសនីទៅដល់ មានចំនួន ៣៥០ ភូមិ ស្មើនឹង ២,៤៧% ជាភូមិដែលដាច់ស្រយាល គ្មានផ្លូវធ្វើដំណើរ ជាតំបន់កោះ ជាភូមិបណ្តែតទឹក និងជាតំបន់លិចទឹកនៅរដូវវស្សា ដែលពិបាកក្នុងការរៀបចំខ្សែបណ្តាញអគ្គិសនី ហើយបើទោះបីជាប្រភពបណ្តាញជាតិពុំទាន់ទៅដល់ ប៉ុន្តែភូមិដែលនៅសល់ទាំងនេះ លំនៅឋានប្រជាពលរដ្ឋមួយចំនួនមានអគ្គិសនីប្រើប្រាស់ជាបណ្តោះអាសន្នរួចហើយ តាមរយៈការផ្តល់ប្រព័ន្ធពន្លឺព្រះអាទិត្យតាមផ្ទះ ក្នុងក្របខណ្ឌជំនួយឧបត្ថម្ភនៃកម្មវិធី គាំពារសង្គមរបស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ និងការវិនិយោគផ្ទាល់ខ្លួន ហើយលំនៅឋានមួយចំនួនទៀត ក៏បានប្រើប្រាស់អាគុយ ដែលមានកន្លែងសាកអាគុយរួមនៅក្នុងភូមិដែរ។ ក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជានឹងរួមគ្នាបន្តដោះស្រាយតាមករណីនីមួយៗ រហូតដល់បញ្ចប់។

### ១.១.៣. ការអភិវឌ្ឍប្រភពអគ្គិសនី

ទំហំប្រភពអគ្គិសនីសរុបដែលបានអភិវឌ្ឍទាំងក្នុងប្រទេស និងការនាំចូលពីប្រទេសជិតខាងបានកើនឡើងពី ២ ៣២២ មេហ្គាវ៉ាត់ នៅឆ្នាំ២០១៧ រហូតដល់ ៤ ០១៤ មេហ្គាវ៉ាត់ នៅឆ្នាំ២០២១ ដែលស្មើនឹងកំណើន ៧២,៧៤% ធៀបទៅនឹងប្រភពអគ្គិសនីដែលមាននៅឆ្នាំ២០១៧។ ប្រភពអគ្គិសនីសរុបនៅឆ្នាំ២០២១នេះ មាន ៣ ០៣៣ មេហ្គាវ៉ាត់ ក្នុងនោះ ៧៥,៥៧% ជាប្រភពអគ្គិសនីដែលបានអភិវឌ្ឍក្នុងស្រុក និង ២៤,៤៣% ជាប្រភពអគ្គិសនីដែលបាននាំចូលពីប្រទេសជិតខាង។

**<u>បញ្ជាក់៖</u>** នៅឆ្នាំ២០២១នេះ អគ្គិសនីដែលកម្ពុជាមាន គឺ ៤ ០១៣,៧៧ ម៉េហ្គាវ៉ាត់ ដោយក្នុងនោះប្រភពក្នុងស្រុកមាន ៣ ០៣៣,០២ ម៉េហ្គាវ៉ាត់ (ប្រភពបានមកពីថាមពលមិនកកើតឡើងវិញសរុប ១ ២៩៣,៩៥ មេហ្គាវ៉ាត់ និងប្រភពបានមកពីថាមពលកកើតឡើងវិញសរុប ១ ៧៣៩,០៧ មេហ្គាវ៉ាត់) ប្រភពក្រៅស្រុក មានចំនួននាំចូល ៩៨០,៧៥ មេហ្គាវ៉ាត់ (ប្រភពមកពីប្រទេសថៃ ២៧៧,៣០ វៀតណាម ៣៣២,៤៥ និងឡាវ ៣៧១)។ ទាំងនេះជាទិន្នន័យដកស្រង់ចេញ របាយការណ៍សង្ខេបបូកសរុបបញ្ចប់ឆ្នាំ២០២១របស់អាជ្ញាធរអគ្គិសនីកម្ពុជា ត្រង់តារាងទិន្នន័យនៃប្រភពអគ្គិសនីផ្សេងៗដែលផ្តល់ឱ្យកម្ពុជា នៅទំព័រទី១។

### ១.១.៤. ការងារគ្រប់គ្រង បច្ចេកទេសអគ្គិសនី និងបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម

ដើម្បីបង្កើនប្រសិទ្ធិភាពការគ្រប់គ្រងបច្ចេកទេសអគ្គិសនី និងប្រសិទ្ធិភាពថាមពល ក្រសួងបានរៀបចំបទដ្ឋានបច្ចេកទេសអគ្គិសនីរួមមាន៖

- ស្តង់ដារៀបចំខ្សែបណ្តាញ សុវត្ថិភាពអគ្គិសនីក្នុងអាគារ លំនៅឋាន និងបទដ្ឋាននៃការបិទស្លាកសញ្ញាប្រសិទ្ធិភាពថាមពលលើឧបករណ៍អគ្គិសនី

- សេចក្តីណែនាំបច្ចេកទេសផលិតបង្គោលអគ្គិសនីតង់ស្យុងមធ្យម និងតង់ស្យុងទាប
- សេចក្តីណែនាំបច្ចេកទេសនៃការប្រើប្រាស់ប្រភេទបង្គោលតាមទីតាំង និង
- សេចក្តីណែនាំបច្ចេកទេសប្រើប្រាស់ខ្សែកាបកប់ក្រោមទឹក។ ក្រសួងរ៉ែ និងថាមពល សហការជាមួយ ADB ពិនិត្យ និងរៀបចំគោលនយោបាយជាតិស្តីពីប្រសិទ្ធិភាពថាមពល និងរៀបចំការអនុវត្តគម្រោង ពាក់ព័ន្ធ និងប្រសិទ្ធិភាព និងសន្សំសំចៃថាមពល។ ដោយឡែកការអភិវឌ្ឍ និងគ្រប់គ្រងការងារ បរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម ក្រសួងរ៉ែ និងថាមពលបានរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នៃថាមពលបរមាណូស៊ីវិល រួមមាន (១) ប្រកាសលេខ០១២៦ រថ.វបប.រថ ចុះថ្ងៃទី១ ខែមេសា ឆ្នាំ ២០២១ ស្តីពីការគ្រប់គ្រងការនាំចូល និងការប្រើប្រាស់សារធាតុវិទ្យុសកម្ម និងប្រភពវិទ្យុសកម្ម (២) សេចក្តីព្រាងច្បាប់បរមាណូនៃព្រះរាជាណាចក្រកម្ពុជា សម្រេចបាន៥០% និង (៣) សេចក្តីព្រាង បទដ្ឋានបច្ចេកទេសស្តីពីសុវត្ថិភាព វិទ្យុសកម្ម និងសន្តិសុខវិទ្យុសកម្ម សម្រេចបាន៣០%។ ក្នុងការ គ្រប់គ្រងលើការងារបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម ក្រសួងបានចុះធ្វើការត្រួតពិនិត្យក៏ដូចជាស្រង់ ទិន្នន័យលើការប្រើប្រាស់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាថាមពលបរមាណូ រួមទាំងវិទ្យុសកម្មនៅតាមទីតាំង នានា ដូចជា ការដ្ឋានរ៉ែ រោងចក្រស៊ីម៉ងត៍ មន្ទីរពេទ្យ មន្ទីរពិសោធន៍ ជាដើម សរុបបានចំនួន ៤៣ ទីតាំង ហើយបានធ្វើការវាយតម្លៃថាការប្រើប្រាស់ទាំងនោះ គឺមានសុវត្ថិភាព សន្តិសុខ និងក្នុងគោលបំណង សន្តិភាពពិតប្រាកដ។ ទន្ទឹមនេះ ក្រសួងបានដឹកនាំ និងសម្របសម្រួលអនុវត្តគម្រោងបច្ចេកទេស ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការអន្តរជាតិជាដៃគូរួមមានទីភ្នាក់ងារថាមពលបរមាណូអន្តរ-ជាតិ (IAEA) សហគមន៍អឺរ៉ុប សហរដ្ឋអាមេរិកជាដើម ដោយទទួលបានជំនួយជាការបណ្តុះបណ្តាល និងឧបករណ៍ សម្ភារៈបច្ចេកទេស ថវិកាសរុបប្រមាណជា ៨០០ ០០០ ទៅ ១ ០០០ ០០០ អឺរ៉ូក្នុង មួយឆ្នាំ។ ក្នុងបរិបទនៃជំងឺកូវីដ១៩ ក្រសួងបានស្នើសុំអង្គការជាដៃគូផ្តល់ជំនួយឧបករណ៍ និងបរិក្ខា តេស្តមេរោគកូវីដ១៩ ប្រភេទ PCR ចំនួន៥ឈុត ថវិកាសរុប ប្រមាណជាង ៤០០ ០០០ អឺរ៉ូ ជូនវិទ្យា-ស្ថានសុខភាពសាធារណៈនៃក្រសួងសុខាភិបាល (២ឈុត) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (១ឈុត) មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តសៀមរាប (១ឈុត) និងមន្ទីរសុខាភិបាលនៃរដ្ឋបាល ខេត្តពោធិ៍សាត់ (១ឈុត)។

## ១.២. ទិសដៅ

ក្រសួងរ៉ែ និងថាមពលបានយកចិត្តទុកដាក់ខ្ពស់ក្នុងការរៀបចំផែនការ និងអនុវត្តសកម្មភាពការងារ ដោយធានាឱ្យបាននូវចីរភាព កាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ដល់បរិស្ថាន និងសង្គម បង្កើនសុខដុមនីយ-កម្មរវាងសហគមន៍ និងការដ្ឋានរ៉ែ និងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាពិសេសសម្រេចបាន

តាមគោលបំណង និងគោលដៅដែលបានកំណត់នៅក្នុងគោលនយោបាយជាតិស្តីពីធនធានរ៉ែ ឆ្នាំ២០១៨-២០២៨ ព្រមទាំងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះវិស័យរ៉ែ គឺអភិវឌ្ឍធនធានរ៉ែដើម្បីជាប្រយោជន៍សេដ្ឋកិច្ច និងសង្គមប្រកបដោយអភិបាលកិច្ចល្អ និងការទទួលខុសត្រូវខ្ពស់ផ្នែកបរិស្ថាន។

### ១.២.១. ការខារពង្រឹងអភិបាលកិច្ចធនធានរ៉ែ

#### ក ការកសាងលិខិតបទដ្ឋានគតិយុត្ត

ដើម្បីពង្រឹងអភិបាលកិច្ចលើការគ្រប់គ្រង និងអភិវឌ្ឍធនធានរ៉ែ នៅក្នុងរយៈពេល៥ឆ្នាំ(២០១៧-២០២១) នេះ ក្រសួងរ៉ែ និងថាមពលបានកសាងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួនរួមមាន ៖

- គោលនយោបាយជាតិស្តីពីធនធានរ៉ែឆ្នាំ២០១៨-២០២៣
- ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- ប្រកាសរួមស្តីពី ការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ១៤៥១សហវ.ប្រក ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈ និងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងរ៉ែ និងថាមពល
- ប្រកាសអន្តរក្រសួងស្តីពី នីតិវិធី និងបែបបទសម្រាប់ការនាំចេញផលិតផលរ៉ែ
- ប្រកាសអន្តរក្រសួងស្តីពី ការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌
- ប្រកាសអន្តរក្រសួងស្តីពី ការគ្រប់គ្រង និងការប្រមូលចំណូលសួយសារធនធានរ៉ែពីការប្រើប្រាស់ធនធានរ៉ែសំណង់ក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋ
- ប្រកាសអន្តរក្រសួងស្តីពី អត្រាសួយសារលើតម្លៃផលិតផលរ៉ែ និងនីតិវិធីនៃការបង់ថ្លៃសួយសារ
- ប្រកាសអន្តរក្រសួងស្តីពី ការបង្កើតមូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍសហគមន៍មូលដ្ឋាន
- ប្រកាសស្តីពី ការធ្វើប្រតិភូកម្មមុខងារក្នុងការផ្តល់សេវារដ្ឋបាលពាក់ព័ន្ធ នឹងការផ្តល់អាជ្ញាបណ្ណសម្រាប់ប្រតិបត្តិការរ៉ែ មានលក្ខណៈជាសិប្បកម្ម និងខ្នាតតូចទៅឱ្យរដ្ឋបាលរាជធានី ខេត្ត
- ប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យចំណុះឱ្យនាយកដ្ឋាននានានៃអគ្គនាយកដ្ឋានធនធានរ៉ែ
- ប្រកាសស្តីពី ការចាត់តាំងក្រុមការងារត្រួតពិនិត្យ និងធ្វើអធិការកិច្ចលើរាល់ប្រតិបត្តិការធនធានរ៉ែ និងសកម្មភាពពាក់ព័ន្ធ
- ប្រកាសស្តីពី វិធាននៃអធិការកិច្ចធនធានរ៉ែសម្រាប់ប្រតិបត្តិការធនធានរ៉ែ ក្រោមអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម អាជ្ញាបណ្ណស្វែងរុករករ៉ែ និងអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ

- ប្រកាសស្តីពី នីតិវិធីនៃការផាកពិន័យបទល្មើសក្នុងប្រតិបត្តិការធនធានរ៉ែ ក្រោមអាជ្ញាបណ្ណអណ្តូងរ៉ែបើកនិងការដ្ឋានវាយថ្មសម្រាប់អាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី
- ប្រកាសស្តីពី បែបបទ និងនីតិវិធី នៃការធ្វើអធិការកិច្ចធនធានរ៉ែសម្រាប់អាជីវកម្មខ្សាច់ ក្រួស ឡាតេរីត ខ្សាច់បក និងអាចម៍ដី
- ប្រកាសស្តីពី ការកំណត់យថាប្រភេទផលិតផលរ៉ែថ្មអារ
- សារាចរស្តីពី ការគ្រប់គ្រងផលិតកម្មអាជីវកម្មថ្មអារ សេចក្តីណែនាំស្តីពីការអនុវត្តមុខងារក្នុងការផ្តល់សេវារដ្ឋបាលក្នុងវិស័យរ៉ែ និងប្រេងកាតរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- គោលការណ៍ណែនាំស្តីពី គោលការណ៍ និងនីតិវិធីនៃការប្រើប្រាស់មូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍសហគមន៍មូលដ្ឋាន។

**ខ. ការរៀបចំមន្ត្រីនគរបាលយុត្តិធម៌**

ដើម្បីជំរុញឱ្យការត្រួតពិនិត្យពង្រឹងភាពអនុលោម និងបង្ក្រាបសកម្មភាពអាជីវកម្មរ៉ែអនាធិបតេយ្យកាន់តែទទួលបានប្រសិទ្ធិភាពខ្ពស់ថែមទៀត ក្រសួងរ៉ែ និងថាមពល បានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីរាជការ និងរៀបចំនីតិវិធីផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដល់មន្ត្រីអធិការកិច្ចធនធានរ៉ែទាំងថ្នាក់កណ្តាល និងមន្ទីររ៉ែ និងថាមពលរាជធានី ខេត្តចំនួន ២៤៥ នាក់ តាមរយៈប្រកាសអន្តរក្រសួងលេខ ០៤៧ កយ.រថ.ប្រក/២០ ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០២០ ស្តីពីការផ្តល់នីតិសម្បទាជានគរបានយុត្តិធម៌។

### ១.២.២ ការគ្រប់គ្រងធនធាន និងអាជីវកម្មរ៉ែ

**ក. ការគ្រប់គ្រងធនធានរ៉ែ**

ក្រសួងរ៉ែ និងថាមពល បានខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការទប់ស្កាត់ និងបង្ក្រាបសកម្មភាពអាជីវកម្មរ៉ែអនាធិបតេយ្យ ព្រមទាំងធ្វើការត្រួតពិនិត្យ និងអធិការកិច្ចជាប្រចាំលើការធ្វើប្រតិបត្តិការធនធានរ៉ែគ្រប់ប្រភេទ ដើម្បីឱ្យការធ្វើប្រតិបត្តិការធនធានរ៉ែមានអនុលោមភាពតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ក្នុងគោលដៅកាត់បន្ថយផលប៉ះពាល់បរិស្ថាន និងសង្គមឱ្យបានជាអតិបរមា ព្រមទាំងផ្តល់ជាប្រយោជន៍ដល់សេដ្ឋកិច្ច និងការអភិវឌ្ឍប្រទេស។ ដើម្បីសម្រេចតាមគោលបំណងខាងលើ ក្រសួងរ៉ែ និងថាមពលបានដាក់ចេញនូវយន្តការក្នុងការពង្រឹងភាពអនុលោមក្នុងវិស័យរ៉ែដូចខាងក្រោះ

- ការពិនិត្យវាយតម្លៃមុននឹងផ្តល់អាជ្ញាបណ្ណធនធានរ៉ែ ដោយធ្វើការពិចារណា ថ្លឹងថ្លែង និងវាយតម្លៃលើកត្តាសំខាន់ចម្បងចំនួន៣ គឺ (១) សេដ្ឋកិច្ច គឺជាការវាយតម្លៃសក្តានុពលធនធានរ៉ែ ដែលអាចធ្វើអាជីវកម្ម និងផលសេដ្ឋកិច្ចពីការធ្វើប្រតិបត្តិការធនធានរ៉ែ (២) បរិស្ថាន សំដៅដល់ការកាត់បន្ថយផលប៉ះពាល់ បរិស្ថានឱ្យនៅជាអប្បបរមា និងយន្តការការពារទប់ស្កាត់ផលប៉ះពាល់បរិស្ថានឱ្យបាន

ជាអតិបរមា ចាប់ពីដំណាក់កាលការទាញយករ៉ែ រហូតដល់ដំណាក់កាលការបិទការដ្ឋានរ៉ែ និង (៣) សង្គម សំដៅដល់ការគិតគូរពីការទប់ស្កាត់ផលប៉ះពាល់សង្គម និងធ្វើយ៉ាងណាឱ្យការធ្វើប្រតិបត្តិការធនធានរ៉ែ បានផ្តល់ប្រយោជន៍ដល់ប្រជាពលរដ្ឋនៅនឹងមូលដ្ឋាន។

- រៀបចំក្រុមការងារត្រួតពិនិត្យ និងអធិការកិច្ចប្រតិបត្តិការធនធានរ៉ែ ចំនួន ០៤ ក្រុម ទៅតាមប្រភេទនៃការធ្វើអាជីវកម្មរ៉ែដូចជា ការធ្វើអាជីវកម្មធនធានរ៉ែឧស្សាហកម្ម ការធ្វើអាជីវកម្មរ៉ែខ្សាច់តាមដងទន្លេ ស្ទឹង និងសមុទ្រការធ្វើអាជីវកម្មរ៉ែអាចម៍ដី និងខ្សាច់បក និងការធ្វើអាជីវកម្មរ៉ែថ្មសំណង់គ្រប់ប្រភេទ។ ក្រុមការងារនីមួយៗ ត្រូវបានដឹកនាំដោយរដ្ឋលេខាធិការ និងមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញពាក់ព័ន្ធ ដើម្បីធ្វើការទប់ស្កាត់ និងបង្ក្រាបសកម្មភាពអាជីវកម្មរ៉ែអនាធិបតេយ្យ។ ជាលទ្ធផលក្រុមការងារបានធ្វើការចុះបង្ក្រាបសកម្មភាពអាជីវកម្មរ៉ែមាសអនាធិបតេយ្យ នៅតំបន់ចុងផ្លាស់ ខេត្តមណ្ឌលគិរី ភ្នំជី ខេត្តកំពង់ធំ និងភ្នំលុង ខេត្តព្រះវិហារ។ល។ ជាពិសេសទៅទៀតនោះ សកម្មភាពអាជីវកម្មរ៉ែខ្សាច់តាមដងទន្លេ ដែលកាលពីមុនឆ្នាំ២០១៥ មានស្ទើរតែពេញផ្ទៃទន្លេមេគ្គងប៉ុន្តែនាពេលបច្ចុប្បន្ននេះ សកម្មភាពអាជីវកម្មរ៉ែអនាធិបតេយ្យខ្សាច់តាមដងទន្លេត្រូវបានបង្ក្រាបទាំងស្រុង។
- មន្ត្រីជំនាញ ក្រសួងរ៉ែ និងថាមពល បានចុះត្រួតពិនិត្យការធ្វើប្រតិបត្តិការធនធានរ៉ែជាប្រចាំ ដើម្បីធានាថា ការធ្វើអាជីវកម្មមានភាពអនុលោមតាមបទដ្ឋានបច្ចេកទេស និងលិខិតបទដ្ឋានគតិយុត្តនានា ក្នុងគោលដៅទប់ស្កាត់ផលប៉ះពាល់បរិស្ថាន សង្គម និងប្រសិទ្ធិភាពនៃការកៀរគរការប្រមូលចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែ។ ជាក់ស្តែងនៅក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១កន្លងទៅ ការចុះត្រួតពិនិត្យភាពអនុលោមបានប្រមូលចំណូលបន្ថែមចំនួនប្រមាណជិត៥លានដុល្លារ និងបានពិន័យជាប្រាក់ចំនួន ២០០ លានរៀល។

### ខ. អាជីវកម្មធនធានរ៉ែ

ដើម្បីគាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសំណង់តូចធំនានា និងចូលរួមចំណែកដល់សេដ្ឋកិច្ចជាតិនៅក្នុងរយៈពេល៥ឆ្នាំ (២០១៧-២០២១) នេះ ការធ្វើអាជីវកម្មរ៉ែសំណង់ និងរ៉ែឧស្សាហកម្មបានផលិតបរិមាណផលិតផលរ៉ែដូចខាងក្រោម៖

| **បរិមាណអាជីវកម្មរ៉ែសំណង់ និងរ៉ែឧស្សាហកម្មបានផលិតពីឆ្នាំ២០១៧-២០១៩** | | | | | |
|---|---|---|---|---|---|
| **ល.រ** | **ផលិតផលរ៉ែ** | **ឯកតា** | **២០១៧** | **២០១៨** | **២០១៩** |
| ១ | ខ្សាច់សំណង់ | លានម.³ | ០,៩៨ | ១,៨២ | ២,០១ |
| ២ | ដីល្បាយខ្សាច់ | លានម.³ | ២,៧៦ | ៦,៣ | ៧,៧១ |
| ៣ | ខ្សាច់បក | លានម.³ | ១,៨៩ | ១,៤១ | ១,៧៨ |

| | | | | | |
|---|---|---|---|---|---|
| ៤ | ក្រួស | ពាន់ម.$^{៣}$ | ១៦,៧២ | ៣៨ | ៣៨,៤០ |
| ៥ | ថ្មបំបែក | លានម.$^{៣}$ | ១,៤៨ | ២,៣៧ | ៤,៧៥ |
| ៦ | អាចម៍ដី | ពាន់ម.$^{៣}$ | ១ ៤៥៤,៧០ | ៦ ៥៧២,៩៤ | ៨ ១៥២,៥៧ |
| ៧ | ដីក្រហម | ពាន់ម.$^{៣}$ | ១ ៤៥៤,៧០ | ១ ៣០០,៩៤ | ២ ២០១,៩០ |
| ៨ | ថ្មអារ | ម.$^{៣}$ | ១៣៧ ៤០០ | ៦៩ ៥៣២ | ១៣៥ ២៣៧ |
| ៩ | ថ្មភក់ | ម.$^{៣}$ | ៧៦៦ | ១ ១៥០ | ២ ២១១ |
| ១០ | ថ្មកែវ | ម.$^{៣}$ | ៣៧៥ | ៦០០ | ៥៤២ |
| ១១ | មាស | គ.ក. | - | - | - |
| ១២ | ម្សៅមាស | គ.ក. | - | ៦៣៨,២៤ | ១ ៧៨២ |
| ១៣ | ធ្យូងថ្ម | តោន | ៥៥ ៩៩១,៤៥ | ៣ ៤១៧២,០៦ | ១៣ ៥៩៨ |
| ១៤ | ថ្មកំបោរ | ពាន់តោន | - | ៥ ៤៦២,៥៦ | ៩ ៥៧៥,៤២ |
| ១៥ | ស៊ីម៉ងត៍ | ពាន់តោន | ៣ ៣៩៩,៧០ | ៥ ៩៦៦,៥១ | ៧ ៩០០,៥៣ |
| ១៦ | ថ្មសន្លឹកនាំចេញ | ម.$^{២}$ | ៤៦ ៩០០ | ១២៦ ៨៤៤,៩៦ | ៥១ ៩១៦,៤៤ |
| ១៧ | ថ្មប្លុកនាំចេញ | ម.$^{៣}$ | ១ ០១២ | ២៨៣,៦៧ | ៤ ១៦៣,២២ |
| **បរិមាណអាជីវកម្មរ៉ែសំណង់ និងរ៉ែឧស្សាហកម្មបានផលិតពីឆ្នាំ២០២០-២០២១ (៩ខែ)** | | | | | |
| **ល.រ** | **ផលិតផលរ៉ែ** | **ឯកតា** | **២០២០** | **២០២១ (៩ខែ)** | **សរុប** |
| ១ | ខ្សាច់សំណង់ | លានម.$^{៣}$ | ៣,០១ | ២,៨៤ | ១០,៦៧ |
| ២ | ដីល្បាយខ្សាច់ | លានម.$^{៣}$ | ៩,៣១ | ១២,១៨ | ៣៨,២៨ |
| ៣ | ខ្សាច់បក | លានម.$^{៣}$ | ១,៩៥ | ២,៤១ | ៩,៤៥ |
| ៤ | ក្រួស | ពាន់ម.$^{៣}$ | ៣៦,៥០ | ៣៦,៥០ | ១៦៦,១២ |
| ៥ | ថ្មបំបែក | លានម.$^{៣}$ | ៣,៦៧ | ៥,២៣ | ១៧,៥២ |
| ៦ | អាចម៍ដី | ពាន់ម.$^{៣}$ | ៨ ១៨៦ | ១០ ៣៨៦ | ៣៤ ៧៥២,២២ |
| ៧ | ដីក្រហម | ពាន់ម.$^{៣}$ | ១ ១៧៥,២៤ | ១ ៣១១ | ៧៤៤១,៧៩ |
| ៨ | ថ្មអារ | ម.$^{៣}$ | ៤០៨ ៦៤០ | ៤៧៨ ៧២០ | ១២២ ៩៥២៩,០០ |
| ៩ | ថ្មភក់ | ម.$^{៣}$ | ៣ ៦៥៩ | ៥ ៦០០ | ១៣ ៣៧៧,០០ |
| ១០ | ថ្មកែវ | ម.$^{៣}$ | ២០០ | ២២០ | ១ ៩៣៧,០០ |
| ១១ | មាស | គ.ក. | - | ៧៤៧,២៦ | ៧៤៧,២៦ |
| ១២ | ម្សៅមាស | គ.ក. | ១៦២ | - | ២ ៥៨២,២៤ |

| | | | | | |
|---|---|---|---|---|---|
| ១៣ | ធ្យូងថ្ម | តោន | ១៩ ០៧៨,២៦ | ១៧ ៥២៨,៧០ | ១៤០ ៣៦៨,៤៧ |
| ១៤ | ថ្មកំបោរ | ពាន់តោន | ១០,៤៧ | ៨ ២៤២,៦៣ | ៣៣ ៧៥៥,៤៥ |
| ១៥ | ស៊ីម៉ងត៍ | ពាន់តោន | ៨ ៥០៦,១០ | ៦ ៨៥៥,១៩ | ៣២ ៦២៨,០៥ |
| ១៦ | ថ្មសន្លឹកនាំចេញ | ម.$^{២}$ | ៣៣៦ ០២០,៣៤ | ១៦៨ ២០២,០៨ | ៧២៩ ៨៨៣,៨២ |
| ១៧ | ថ្មប្លុកនាំចេញ | ម.$^{៣}$ | ៥១ ៣៥០,៥៤ | ៣៧៣ ៤៥៩,៨៧ | ៤៣០ ២៦៩,៣០ |

* ផលិតផលថ្មកំបោរក្នុងឆ្នាំ២០១៧ ពុំបានកត់ត្រាទុក ដោយសារក្រុមហ៊ុនបង់លើបរិមាណផលិតផលសម្រេចស៊ីម៉ងត៍តែម្តង។

### ១.២.៣. ការការពារបរិស្ថាន និងសង្គម

ការទប់ស្កាត់ ការពារផលប៉ះពាល់បរិស្ថាន និងសង្គម ត្រូវបានពិនិត្យវាយតម្លៃចាប់តាំងពីមុនផ្តល់អាជ្ញាបណ្ណរហូតដល់បិទបញ្ចប់ការដ្ឋាន។ ដើម្បីធានាថាការធ្វើប្រតិបត្តិការធនធានរ៉ែមានផលប៉ះពាល់ដល់បរិស្ថាន និងសង្គមតិចតួចបំផុតនោះ ក្រសួងរ៉ែ និងថាមពល បានតម្រូវឱ្យសម្បទានិកត្រូវធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) និងរៀបចំវេទិកាពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋមូលដ្ឋាន មុននឹងផ្តល់អាជ្ញាបណ្ណអនុញ្ញាតឱ្យធ្វើប្រតិបត្តិការធនធានរ៉ែ។ បន្ថែមលើនេះ ការត្រួតពិនិត្យវាយតម្លៃភាពអនុលោមជាប្រចាំលើការធ្វើប្រតិបត្តិការធនធានរ៉ែ និងការកំណត់អំពីគោលការណ៍នៃការស្តារការដ្ឋានរ៉ែ ក្រោយបញ្ចប់ការធ្វើប្រតិបត្តិការធនធានរ៉ែក៏ជាការងារអាទិភាព ដែលក្រសួងរ៉ែ និងថាមពល បានយកចិត្តទុកដាក់ និងអនុវត្តយ៉ាងសកម្មផងដែរ ដើម្បីធានាអំពីប្រសិទ្ធិភាពនៃការទប់ស្កាត់ផលប៉ះពាល់បរិស្ថាន និងសង្គម។ ទន្ទឹមនឹងយន្តការទាំងអស់ខាងលើនេះ ដើម្បីលើកកម្ពស់ការអភិវឌ្ឍសហគមន៍មូលដ្ឋាន **ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល** បានផ្តួចផ្តើមបង្កើតមូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍសហគមន៍មូលដ្ឋាន (មូលនិធិរ៉ែ) នៅក្នុងឆ្នាំ២០១៥ ក្នុងគោលដៅប្រើប្រាស់ជាប្រយោជន៍ដល់ការអភិវឌ្ឍសហគមន៍មូលដ្ឋាន ដែលបានទទួលរងផលប៉ះពាល់ដោយផ្ទាល់ និងប្រយោលពីការធ្វើប្រតិបត្តិការធនធានរ៉ែ។ គិតត្រឹមឆមាសទី១ ឆ្នាំ២០២១នេះ ចំនួន ៧ ០៦៣ ១០៥,៤៧ (ប្រាំពីរលានហុកសិបបីពាន់មួយរយប្រាំក្បៀសសែសិបប្រាំពីរ) ដុល្លារអាមេរិក ហើយបានបញ្ចប់ការអភិវឌ្ឍសហគមន៍មូលដ្ឋានចំនួន ២៧ គម្រោង និងអនុម័តគម្រោងស្នើសុំអភិវឌ្ឍសហគមន៍ចំនួន ២៤ គម្រោងបន្ថែម សរុបចំនួន ៥១ គម្រោងត្រូវបាន និងកំពុងបន្តអនុវត្ត ដែលមានថវិកាចំណាយ និងគ្រោងសរុបចំនួន ២ ៦៨១ ០៩៩,៣១ (ពីរលានប្រាំមួយរយប៉ែតសិបមួយពាន់កៅសិបប្រាំបួនក្បៀសសាមសិបមួយ) ដុល្លារអាមេរិក។

### ១.២.៤. ការគៀរគរចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែ

រយៈពេល៥ឆ្នាំមកនេះ ក្រសួងរ៉ែ និងថាមពល បានគៀរគរចំណូលមិនមែនសាពើពន្ធពីវិស័យរ៉ែ ចាប់ពីឆ្នាំ២០១៧ ដល់ ឆ្នាំ២០២១ (៩ខែ) បានចំនួនដូចខាងក្រោម៖

- នៅឆ្នាំ២០១៧ ចំណូលមិនមែនសាពើពន្ធពីវិស័យរ៉ែ មានចំនួន ៥៨ ២៥០.៩៨ លានរៀល។
- នៅឆ្នាំ២០១៨ ចំណូលមិនមែនសាពើពន្ធពីវិស័យរ៉ែ មានចំនួន ៧២ ៨៦៨.៤៩ លានរៀល។
- នៅឆ្នាំ២០១៩ ចំណូលមិនមែនសាពើពន្ធពីវិស័យរ៉ែ មានចំនួន ៧៥ ៩៨៣.៩០ លានរៀល។
- នៅឆ្នាំ២០២០ ចំណូលមិនមែនសាពើពន្ធពីវិស័យរ៉ែ មានចំនួន ១១០ ១៨៨.៨៣ លានរៀល។
- នៅរយៈពេល៩ខែដើមឆ្នាំ២០២១ ចំណូលមិនមែនសាពើពន្ធពីវិស័យរ៉ែ មានចំនួន ៩៨ ៤៦០ លានរៀល។

**តារាងប្រៀបធៀបចំណូលរវាងឆ្នាំ២០១៣-២០១៧ និង២០១៧-២០២១(៩ខែ)**

| ល.រ | បរិយាយ | អនុវត្តជាក់ស្តែង ២០១៣-២០១៧ | អនុវត្តជាក់ស្តែង ២០១៧-២០២១(៩ខែ) | ធៀប |
|---|---|---|---|---|
| | | ១ | ២ | ៣=២/១ |
| ១ | សួយសារធនធានរ៉ែ | ១០៤ ៩០៩,៦៣ | ៣៥០ ១៥៧,៨១ | ៣៣៤% |
| ២ | កម្រៃអាជ្ញាបណ្ណ | ៨ ១០១,១៨ | ១៤ ១៣៤,៥៥ | ១៧៤% |
| ៣ | កម្រៃចុះបញ្ជី | ១៥៩,១៩ | ៨៩ | ៥៦% |
| ៤ | ថ្លៃផ្ទេរសិទ្ធិអាជ្ញាបណ្ណធនធានរ៉ែ | ១ ៥០៣ | ២ ៤៤០ | ១៦២% |
| ៥ | ចំណូលពីការទទួលស្គាល់សមាសភាពភាគហ៊ុន | ៧៩០ | ១ ១២៥ | ១៤២% |
| ៦ | ចំណូលពីសេវាពិនិត្យ  រៀបចំនឹងដំណើរការឯកសារ | ១៨៥,១០ | ៤៦៣,១៥ | ២៥០% |
| ៧ | ចំណូលពីការចេញលិខិតបញ្ជាក់ | ៧៩ | ៦៤៩ | ៨២២% |
| ៨ | លិខិតអនុញ្ញាតបុរេសនា | ១២ | ៨៨ | ៧៣៣% |
| ៩ | ឈ្នួលផ្ទៃក្រឡា | ២០ ៤៤៥,៤៧ | ១៨ ០៥៣,៥៥ | ៨៨% |
| ១០ | ចំណូលបំណុល (ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ) | ២៦ ១៣៨,១០ | ១៦ ៩៥៥,៥៤ | ៦៥% |
| ១១ | ចំណូលពីការពិន័យ | ៧ ៣៦៨,៧៨ | ២១ ៥៩៦,៦០ | ២៩៣% |
| សរុប | | ១៦៩ ៦៩១,៤៥ | ៤២៥ ៧៥២,២០ | ២៥១% |

### ១.៣. វិស័យប្រេងកាត

ក្រសួងរ៉ែ និងថាមពលបានអនុវត្តការងារដោយឈរលើសសរស្តម្ភចំនួន៣គឺ ទី១ បង្កើតបន្ថែមឿនឧស្សាហកម្មនិស្សារណកម្មពីវិស័យប្រេងកាត ដោយផ្តោតសំខាន់លើការងារសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រ វាយ-

តម្លៃសេដ្ឋកិច្ច និងការរកឃើញធនធានប្រេងកាត ការផ្សព្វផ្សាយព័ត៌មាន និងការទាក់ទាញការវិនិយោគក្នុងវិស័យប្រេងកាតការជំរុញប្រសិទ្ធិភាពប្រតិបត្តិការប្រេងកាត ការលើកកម្ពស់ជីវភាពប្រជាជនមូលដ្ឋាន និងការលើកស្ទួយការប្រើប្រាស់ទំនិញសេវាកម្ម និងពលកម្មក្នុងស្រុក និងការងារដោះស្រាយតំបន់ទាមទារដែនសមុទ្រត្រួតគ្នា ទី២- បង្កើនប្រសិទ្ធិភាពក្នុងការគ្រប់គ្រងលំហូរចំណូលជាតិពីវិស័យប្រេងកាត ដោយផ្តោតសំខាន់លើការពង្រឹងប្រសិទ្ធិភាពនៃប្រព័ន្ធប្រមូលចំណូល និងការកសាងសមត្ថភាពជាតិ ក្នុងការគ្រប់គ្រងចំណូលប្រកបដោយប្រសិទ្ធិភាព និងទី៣ ការការពារបរិស្ថាន និងសង្គមក្នុងប្រតិបត្តិការប្រេងកាត ដោយផ្តោតសំខាន់លើការរៀបចំលិខិតបទដ្ឋានគតិយុត្តការគ្រប់គ្រង និងត្រួតពិនិត្យសកម្មភាពផ្នែកដោនស្រ្ទីម (Downstream) ការពង្រឹងប្រសិទ្ធិភាពការគ្រប់គ្រងសម្បទានប្រេងកាត និងការងារអធិការកិច្ចក្នុងវិស័យប្រេងកាត។

### ១.៣.១ ការងារគ្រប់គ្រង និងអភិវឌ្ឍវិស័យប្រេងកាត

ក្រសួងបានយកចិត្តទុកដាក់ខ្ពស់ជំរុញការអភិវឌ្ឍវិស័យប្រេងកាត ឱ្យមានការរីកចម្រើនដូចបណ្តាប្រទេសនានាក្នុងតំបន់ និងសកលលោក ដោយបានខិតខំផ្សព្វផ្សាយ និងទាក់ទាញអ្នកវិនិយោគឱ្យមកបណ្តាក់ទុនរកស៊ីក្នុងវិស័យប្រេងកាតនៅកម្ពុជា។ ជាក់ស្តែង បន្ទាប់ពីការចរចាដ៏ស្វិតស្វាញ ក្រសួងបានចុះកិច្ចព្រមព្រៀងប្រេងកាតជាមួយក្រុមហ៊ុន KrisEnergy និងបានសហការសម្របសម្រួលឱ្យក្រុមហ៊ុននេះធ្វើការអភិវឌ្ឍគម្រោងប្រេងកាតប្លុក A (ប្លុកអប្សរា) រហូតទទួលបានការដាក់ឱ្យដំណើរការផលិតកម្មប្រេងលើកដំបូងរបស់កម្ពុជា នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ និងផលិតប្រេងបានចំនួន ២៩០ ២៥៤ បារ៉ែល គិតត្រឹមខែឧសភា ឆ្នាំ២០២១។ ទន្ទឹមនេះសម្រាប់សកម្មភាពផ្នែកដោនស្រ្ទីម (Downstream) ក្រសួងបានផ្តល់អាជ្ញាបណ្ណចំនួន ៦៣ លិខិតអនុញ្ញាតដំណើរការចំនួន ១៧ វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្ថានីយចំនួន ៣៨៤ និងលិខិតអនុញ្ញាតដំណើការស្ថានីយចំនួន ១ ៩៣១ ដែលធ្វើឱ្យចំនួនស្ថានីយដែលបានដាក់ពាក្យនឹងមានច្បាប់កើនឡើងពី ១១% ទៅ ៦៧%។

**តារាងសង្ខេបការផ្តល់អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតដំណើរការពាក់ព័ន្ធនឹងសកម្មភាពពាណិជ្ជកម្ម**

| ល.រ | ប្រភេទ | អាជ្ញាបណ្ណ | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | |
| ១ | មណ្ឌលសន្និធិប្រេងឥន្ធនៈ | ១ | ៣ | ២ | ៣ | ១ | ១០ |
| ២ | មណ្ឌលសន្និធិឧស្ម័នឥន្ធនៈ | ១ | - | ២ | ៣ | ១ | ៧ |
| ៣ | មណ្ឌលសន្និធិរួមប្រេង និងឧស្ម័នឥន្ធនៈ | - | - | - | ១ | - | ១ |
| ៤ | ការនាំចូលប្រេង និងឧស្ម័នឥន្ធនៈ | ១ | - | - | ១ | ៣ | ៥ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | ការដឹកជញ្ជូនឧស្ម័នឥន្ធនៈ | ២ | - | - | ១ | - | ៣ |
| ៦ | ការផ្គត់ផ្គង់ និងការចែកចាយឧស្ម័នឥន្ធនៈ (ឧស្ម័នធម្មជាតិ) | ២៥ | - | - | - | - | ២៥ |
| ៧ | ការវេចខ្ចប់ឧស្ម័នអិលភីជី | - | - | - | ៧ | ៥ | ១២ |
| សរុប | | ៣០ | ៣ | ៤ | ១៦ | ១០ | ៦៣ |
| ល.រ | ប្រភេទ | អាជ្ញាបណ្ណ | | | | | សរុប |
| | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | |
| ១ | មណ្ឌលសន្និធិប្រេងឥន្ធនៈ | ១ | ២ | ១ | ៥ | - | ៩ |
| ២ | មណ្ឌលសន្និធិឧស្ម័នឥន្ធនៈ | - | - | ១ | ៣ | - | ៤ |
| ៣ | មណ្ឌលសន្និធិរួមប្រេង និងឧស្ម័នឥន្ធនៈ | - | - | - | ១ | - | ១ |
| ៤ | ការនាំចូលប្រេង និងឧស្ម័នឥន្ធនៈ | - | - | - | - | - | - |
| ៥ | ការដឹកជញ្ជូនឧស្ម័នឥន្ធនៈ | - | - | - | - | - | - |
| ៦ | ការផ្គត់ផ្គង់ និងការចែកចាយឧស្ម័នឥន្ធនៈ (ឧស្ម័នធម្មជាតិ) | - | - | - | - | - | - |
| ៧ | ការវេចខ្ចប់ឧស្ម័នអិលភីជី | - | - | - | ២ | ១ | ៣ |
| សរុប | | ១ | ២ | ២ | ១១ | ១ | ១៧ |
| ល.រ | ប្រភេទ | អាជ្ញាបណ្ណ | | | | | សរុប |
| | | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | |
| ១ | វិញ្ញាបនបត្របញ្ជាក់បច្ចេកទេស | ៣៥ | ១០០ | ៨៧ | ៤២ | ៨០ | ៣៤៤ |
| ២ | លិខិតអនុញ្ញាតដំណើរការ | ១៣ | ៩២ | ១១៥ | ៧៥៨ | ៩៥៣ | ១៩៣១ |
| សរុប | | ៤៨ | ១៩២ | ២០២ | ៨០០ | ១០៣៣ | ២២៧៥ |

## តារាងសង្ខេបចំនួនស្ថានីយដែលបានដាក់ពាក្យ និងមានច្បាប់៖

| ឆ្នាំ | ចំនួនស្ថានីយសរុប | បានដាក់ពាក្យស្នើសុំច្បាប់ | មិនទាន់មានច្បាប់ | ភាគរយបានដាក់ពាក្យ និងមានច្បាប់ |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| ២០១៧ | ៣ ៥១៩ | ៣៧២ | ៣ ១៤៧ | ១១% |
| ២០១៨ | ៣ ៧៧៨ | ៥៦៩ | ៣ ២០៩ | ១៥% |
| ២០១៩ | ៤ ២០០ | ៨៥៧ | ៣ ៣៤៣ | ២០% |
| ២០២០ | ៤ ៧៥២ | ២ ៦៥៧ | ២ ០៩៥ | ៥៦% |
| ២០២១ | ៥ ០៣៤ | ៣ ៣៩៦ | ១ ៦៣៨ | ៦៧% |

**តារាងសង្ខេបពីការបណ្តាក់ទុនវិនិយោគសម្រាប់ផ្នែកអាប់ស្ទ្រីមៈ**

| ក្រុមហ៊ុន | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ (គិតត្រឹម ត្រីមាសទី៣) | សរុប |
|---|---|---|---|---|---|---|
| ក្រុមហ៊ុន គ្រីសអេនើជី (អប្សរា) ឯ.ក (KrisEnergy Apsara Company Limited) ប្លុក A | ២,៥៦ | ៥,១៨ | ១៩,១៧ | ៥៩,២៧ | ២៩,៦៧ | ១១៥,៨៥ |
| ក្រុមហ៊ុន ខេមបូឌាន រីសស ស៍ អេនើជី ឌីវឡុបមិន ឯ.ក (Cambodian Resource Energy Development Co.,Ltd) ប្លុក D | ០ | ០ | ០ | ១,០៣ | ០,៣៥ | ១,៣៨ |
| **សរុប** | ២,៥៦ | ៥,១៨ | ១៩,១៧ | ៦០,៣០ | ៣០,០២ | ១១៧,២៣ |

### ១.៣.២ ចំណូលមិនមែនសារពើពន្ធពីវិស័យប្រេងកាត

ចំណូលពីវិស័យប្រេងកាតក៏ត្រូវបានពង្រឹងតាមរយៈការផ្តល់សេវាសាធារណៈ និងការជំរុញឱ្យអ្នកចុះកិច្ចព្រមព្រៀងប្រេងកាតអនុវត្តកាតព្វកិច្ចហិរញ្ញវត្ថុ តាមការតម្រូវដោយច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។ ក្នុងរយៈពេល៥ឆ្នាំមកនេះ ក្រសួងរ៉ែ និងថាមពល បានកៀរគរចំណូលមិនមែនសាពើពន្ធពីវិស័យប្រេងកាត ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ បានចំនួនដូចខាងក្រោមៈ

- នៅឆ្នាំ២០១៧ ចំណូលមិនមែនសាពើពន្ធពីវិស័យប្រេងកាត មានចំនួន ៨ ២១៥.៨៨ លានរៀល
- នៅឆ្នាំ២០១៨ ចំណូលមិនមែនសាពើពន្ធពីវិស័យប្រេងកាត មានចំនួន ២៤ ១៦៧.៤៩ លានរៀល
- នៅឆ្នាំ២០១៩ ចំណូលមិនមែនសាពើពន្ធពីវិស័យប្រេងកាត មានចំនួន ១១ ៧៣៣.០២ លានរៀល
- នៅឆ្នាំ២០២០ ចំណូលមិនមែនសាពើពន្ធពីវិស័យប្រេងកាត មានចំនួន ២១ ០៤៣.៣៦ លានរៀល
- នៅឆ្នាំ២០២១ ចំណូលមិនមែនសាពើពន្ធពីវិស័យប្រេងកាត មានចំនួន ២ ១៨៥.៣៥ លានរៀល។

**<u>សម្គាល់៖</u>** ចំពោះការលើកឡើងពីសមិទ្ធផលនានា ដែលក្រសួងរ៉ែ និងថាមពលសម្រេចបានក្នុងរយៈពេល៥ឆ្នាំខាងលើនេះ ពោលគិតចាប់ពីឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០២១ គឺក្រុមយើងខ្ញុំបានធ្វើការដកស្រង់នូវខ្លឹមសារទាំងស្រុងចេញពីរបាយការណ៍ការសង្ខេប ស្តីពីសមិទ្ធផលសំខាន់ៗរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៧-២០២១ ត្រង់ទំព័រទី១៨៧ រហូតដល់ទំព័រ១៩៦។

## ២. បញ្ហាប្រឈម និងដំណោះស្រាយ

វិស័យរ៉ែ និងថាមពល ជាវិស័យដែលមានសក្តានុពលមួយនាពេលអនាគត និងអាចជាប្រភពចំណូលបន្ថែមដ៏សំខាន់របស់ជាតិ។ កន្លងមកនេះ ការប្រមូលចំណូលពីវិស័យរ៉ែ និងថាមពល មានកំណើនជាមធ្យម ៤១,១% ក្នុងមួយឆ្នាំ ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៨។ ទោះបីជា រាជរដ្ឋាភិបាលដាក់អនុវត្តបទប្បញ្ញត្តិមួយចំនួនដើម្បីបង្កើនប្រសិទ្ធិភាពគ្រប់គ្រងលើវិស័យនេះ ការប្រមូលចំណូលនៅប្រឈមបញ្ហាមួយចំនួនដូចជា៖

- កាតព្វកិច្ចហិរញ្ញវត្ថុដែលមាននៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមានមួយចំនួន នៅមិនទាន់សមស្របនឹងការវិវឌ្ឍសេដ្ឋកិច្ច
- ប្រសិទ្ធិភាពនៃការកៀគរការប្រមូលចំណូលពីសួយសារ សម្រាប់រដ្ឋនៅមានកម្រិត
- កង្វះប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគ្រប់គ្រងកិច្ចសន្យា/កិច្ចព្រមព្រៀង និងអាជ្ញាបណ្ណរ៉ែ និងថាមពល និង
- កង្វះមន្ត្រីក្នុងការកៀរគរចំណូលឱ្យមានប្រសិទ្ធិភាព។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចជា៖

- សិក្សា និងធ្វើបច្ចុប្បន្នភាព កាតព្វកិច្ចហិរញ្ញវត្ថុនៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន ឱ្យស្របតាមការវិវឌ្ឍសេដ្ឋកិច្ចកម្ពុជា និងផ្តល់ផលប្រយោជន៍ជូនភាគីរដ្ឋាភិបាល
- ពង្រឹងប្រសិទ្ធិភាពនៃការកៀរគរការប្រមូលចំណូលពីសួយសារ
- បន្តអនុវត្តន៍លើការបង់ចំណូលពីវិស័យធនធានរ៉ែ ដោយតម្រូវឱ្យសម្បទានិកធ្វើការបង់ចំណូលដែលគ្រោងជាមុន ដោយផ្អែកលើផែនការផលិតកម្ម និងមធ្យោបាយផលិតកម្ម
- រៀបចំប្រព័ន្ធព័ត៌មានសម្រាប់គ្រប់គ្រងកិច្ចសន្យា/កិច្ចព្រមព្រៀង និងអាជ្ញាបណ្ណរ៉ែ និងថាមពល ដើម្បីពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល
- រៀបចំលិខិតបទដ្ឋាន ដើម្បីកំណត់ឱ្យក្រុមហ៊ុនអាជីវកម្មរ៉ែ មានប្រធានការដ្ឋានដែលមានជំនាញច្បាស់លាស់នៅគ្រប់ការដ្ឋានរ៉ែ[50]។

[50] ដកស្រង់ចេញពីយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ត្រង់ចំណុច៨៥ និងចំណុច៨៦

ដោយឡែកចំពោះវិស័យទាំងបីរបស់ក្រសួងរ៉ែ និងថាមពល វិស័យប្រេងកាតហាក់បីជួបបញ្ហាប្រឈមជាងគេក្នុងការដឹកនាំ និងធ្វើការអភិវឌ្ឍទៅលើវិស័យមួយនេះ។ ប្រជាពលរដ្ឋគ្រប់រូបបានដឹងរួចមកហើយថា នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ ព្រះរាជាណាចក្រកម្ពុជា បានចាប់ផ្តើមផលិតកម្មប្រេងដំបូង នៅតំបន់ប្លុក A (ប្លុកអប្សរា) ឈូងសមុទ្រកម្ពុជា ដែលនេះជាការលើកឡើងរបស់ សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈបណ្តាញសង្គម (Facebook) ផ្លូវការរបស់សម្តេចនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០។ ក្រោយពីការចាប់ផ្តើមផលិតកម្មបូមប្រេងកាត មិនទាន់បានរយៈពេល១ឆ្នាំផង អាជីវកម្មមួយនេះត្រូវបានផ្អាកលែងដំណើការ ដោយសារតែក្រុមហ៊ុន គ្រីសអេនើជី (KrisEnergy) ដែលជាក្រុមហ៊ុនមេ មានមូលដ្ឋាននៅប្រទេសសិង្ហបុរី បានចេញសេចក្តីប្រកាសរបស់ខ្លួន ពីការប្រកាសក្ស័យធុន ដោយក្នុងនោះក្រុមហ៊ុនបានបញ្ជាក់ថា ខ្លួនមិនមានលទ្ធភាពសងបំណុលខ្លួន ដោយផ្អែកលើបំណុលដែលអាចកើនឡើង និងកំពុងមានជាក់ស្តែង ហើយនឹងបន្តទៅរកការទូទាត់បំណុល នេះជាការចុះផ្សាយរបស់ក្រុមហ៊ុន គ្រីសអេនើជី (KrisEnergy) នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១។ កត្តានេះហើយជាហេតុនាំឱ្យក្រុមហ៊ុន គ្រីសអេនើជី ខេមបូឌា (KrisEnergy Cambodia) ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធនៃ ក្រុមហ៊ុន គ្រីសអេនើជី (KrisEnergy) និងជាក្រុមហ៊ុនទទួលបានសិទ្ធិសម្រាប់ការស្វែងរុករក និងអភិវឌ្ឍក្នុងតំបន់អប្សរា ប្លុក A កម្ពុជា មិនអាចបន្តការអភិវឌ្ឍ និងធ្វើអាជីវកម្មបូមប្រេងឆៅនៅប្រទេសកម្ពុជាបន្តទៀតបាន។ ហើយអ្វីដែលជាបញ្ហាប្រឈមខ្លាំង និងគួរឱ្យកត់សម្គាល់នោះគឺ ប្រេងដែលក្រុមហ៊ុន គ្រីសអេនើជី ខេមបូឌា (KrisEnergy Cambodia) បានបូមចេញ ត្រូវបាននាវា MT Strovolos លួចដឹកយកប្រេងទាំងអស់នោះចាកចេញពីប្រទេសកម្ពុជា។ សូមបញ្ជាក់ថា នៅល្ងាចថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ នាវា MT Strovolos ត្រូវបានបញ្ជាដោយក្រុមហ៊ុន Wrold Tankers Management Pte Ltd បានធ្វើការចាកចេញពីកម្ពុជានៅម៉ោង ៨:០០ ល្ងាច ចូលដែនទឹកប្រទេសថៃរួចមក នាវា MT Strovolos នេះបានបន្តធ្វើដំណើរទៅកាន់ដែនទឹកប្រទេសឥណ្ឌូណេស៊ី។ បន្ទាប់មកក្រុមនាវិកនៃនាវា MT Strovolos ត្រូវបានចាប់ខ្លួនដោយអាជ្ញាធរនៃប្រទេសឥណ្ឌូណេស៊ី ពាក់ព័ន្ធនឹងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌអំពីការលួចប្រេងឆៅនៅលើនាវាចំនួន ២៩៥ ០០០ (ពីររយកៅសិបប្រាំពាន់) បារ៉ែល របស់ព្រះរាជាណាចក្រកម្ពុជា។ ក្រោយពីទទួលបានដំណឹងខាងលើ រាជរដ្ឋាភិបាលប្រទេសកម្ពុជា បានប្រើប្រាស់សិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនស្របតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដើម្បីស្នើសុំ និងបានទំនាក់ទំនងដោយផ្ទាល់ជាមួយអាជ្ញាធរឥណ្ឌូណេស៊ី និងតាមរយៈប៉ូលិសអាំងទែប៉ូល ឱ្យចាប់ខ្លួន និងធ្វើបត្យាប័នក្រុមនាវិកទាំងនោះមកព្រះរាជាណាចក្រកម្ពុជា ស្របតាមនីតិវិធីដែលមានកំណត់ក្នុងសន្ធិសញ្ញាអាស៊ាន ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យ

ព្រហ្មទណ្ឌ និងច្បាប់កម្ពុជាដែលពាក់ព័ន្ធ[51]។

**<u>សម្គាល់៖</u>** នាវា MT Strovolos ជានាវាដែលត្រូវបានជួលដោយក្រុមហ៊ុនមួយ នៃគ្រីសអេនើជីគ្រុប (KrisEnergy Group) ដើម្បីធ្វើជានាវាស្តុកទុក និងផ្ទេរប្រេងឆៅពីតំបន់អប្សរាប្លុក A ក្នុងដែនសមុទ្រកម្ពុជា។

ចំពោះពេលបច្ចុប្បន្ននេះ ឯកឧត្តម ជៀប សួរ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាត បានបង្ហាញថា កម្ពុជានៅមិនទាន់ទទួលតម្រុយថា អាចទទួលបានប្រេងដែលជារបស់កម្ពុជាវិញនៅពេលណានោះទេ ខណៈកម្ពុជាផ្ទាល់កំពុងបន្តធ្វើការលើរឿងនេះជាប់ជាប្រចាំ ដើម្បីនាំយកប្រេងដែលកម្ពុជាបាត់មកវិញគ្រប់ចំនួន។ បន្ថែមពីនេះ ឯកឧត្តម ជៀប សួរ បានអះអាងថា បច្ចុប្បន្នមានក្រុមហ៊ុនមកពីបណ្តាប្រទេសចំនួន៥ រួមមានប្រទេសថៃ កាណាដា ចិន ម៉ាឡេស៊ី និងកាហ្សាក់ស្តង់ ដែលកំពុងចាប់អារម្មណ៍ និងសម្លឹងមើលឃើញអំពីលទ្ធភាពជីករុករកប្រេង និងឧស្ម័ននៅកម្ពុជា ដែលវត្តមាននៃក្រុមហ៊ុនទាំងអស់នេះ ជាសញ្ញាបង្ហាញឱ្យឃើញពីក្តីសង្ឃឹមថ្មីមួយទៀតមកលើដំណើរការបូមប្រេងនៅកម្ពុជា បន្ទាប់ពីប្រតិបត្តិការបូមប្រេងនេះត្រូវបានស្ងាត់សូន្យឈឹងអស់រយៈពេលជាងមួយឆ្នាំមកនេះ[52]។

## ៣. គោលដៅការងារ និងផែនការសកម្មភាពរបស់ក្រសួងរ៉ែ និងថាមពល

ក្រសួងរ៉ែ និងថាមពល ជាស្ថាប័នដែលទទួលខុសត្រូវទៅលើវិស័យបីសំខាន់ៗ ដែលក្នុងនោះរួមមាន វិស័យរ៉ែ វិស័យថាមពល និងវិស័យប្រេងកាត។ ដើម្បីឱ្យការគ្រប់គ្រងទៅលើវិស័យទាំងបី មានភាពរីកចម្រើន និងផ្តល់ផលប្រយោជន៍ដល់ការអភិវឌ្ឍសង្គមជាតិ រាជរដ្ឋាភិបាល បានដាក់ចេញនូវផែនការសកម្មភាពទៅតាមវិស័យទាំងបីរបស់ក្រសួងរ៉ែ និងថាមពល ដូចខាងក្រោម៖

### ៣.១.វិស័យរ៉ែ

ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦ នៃរដ្ឋសភាក្រសួងរ៉ែ និងថាមពល និងបន្តអនុវត្ត គោលនយោបាយជាតិស្តីពីធនធានរ៉ែឆ្នាំ២០១៨-២០២៨ ដោយពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងធនធាន និងអាជីវកម្មរ៉ែ ទន្ទឹមនឹងការជំរុញការចូលរួមពីសហគមន៍ ដើម្បីកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន សង្គម និងពង្រីកការប្រមូលចំណូលថវិកាជាតិ ពង្រឹងយន្តការគ្រប់គ្រងធនធាន និងអាជីវកម្មរ៉ែដោយកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថាន[53]។

គោលនយោបាយជាតិស្តីពីធនធានរ៉ែ ឆ្នាំ២០១៨-២០២៨ បង្កើតឡើងក្នុងគោលបំណង (១) គ្រប់គ្រង

---

[51] ដកស្រង់ខ្លឹមសារចេញពីលិខិតលេខ០០៣៦ ស្តីពីសេចក្តីប្រកាសព័ត៌មានស្តីពីបច្ចុប្បន្នភាពនៃនាវា MT Strovolos និងក្រុមនាវិកដែលត្រូវបានចាប់ខ្លួនពាក់ព័ន្ធនឹងបទល្មើសលួចប្រេងឆៅរបស់កម្ពុជា

[52] ដកស្រង់ចេញពីខ្លឹមសាររបស់វិទ្យុបារាំងចុះផ្សាយថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២២

[53] ដកស្រង់ចេញពីចំណុច ៤.១៧៩ ចេញពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៩-២០២៣ ទំព័រទី៣៤៤

និងអភិវឌ្ឍធនធានរ៉ែប្រកបដោយចីរភាព (២) ផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋ និងសហគមន៍រ៉ែ (៣) ផ្គត់ផ្គង់វត្ថុធាតុដើមដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសំណង់ (៤) បង្កើតប្រភពចំណូលថ្មីសម្រាប់ជាតិ។ ដើម្បីអនុវត្តឱ្យបានសម្រេចនូវគោលបំណងខាងលើ ក្រសួងបានកំនត់គោលដៅចំនួន៥ត្រូវបានដាក់ចេញរួមមាន៖

**គោលដៅទី១-ពង្រឹងតួនាទីស្ថាប័នរដ្ឋក្នុងការគ្រប់គ្រង និងការអភិវឌ្ឍធនធានរ៉ែ**

**១.ការរៀបចំច្បាប់ និងបទប្បញ្ញត្តិនានា** ដែលមានផែនការសកម្មភាពដូចជា (១) ជំរុញការរៀបចំក្រមស្តីពីធនធានរ៉ែ ដែលរួមមានបញ្ញត្តិស្តីពីការគ្រប់គ្រងប្រតិបត្តិការធនធានរ៉ែ (២) ពិនិត្យឡើងវិញនូវបទប្បញ្ញត្តិនានាដែលទាក់ទងជាមួយនឹងវិស័យរ៉ែ និងរៀបចំបំពេញបន្ថែមចំណុចខ្វះខាត សំដៅធានាប្រសិទ្ធិភាពក្នុងការគ្រប់គ្រងវិស័យរ៉ែ និងធានាដល់ការប្រតិបត្តិនូវអភិបាលកិច្ចល្អដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល (៣) រៀបចំបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងទិន្នន័យភូគព្ភសាស្ត្រ និងសំណាកភូគព្ភសាស្ត្រ (៤) រៀបចំបទប្បញ្ញត្តិដើម្បីធានានូវការប្រមូលចំណូលពីវិស័យរ៉ែប្រកបដោយតម្លាភាព និងប្រសិទ្ធិភាព។

**២.ការពង្រឹងសមត្ថភាពមន្ត្រី និងការកសាងធនធានមនុស្ស** ដែលមានផែនការសកម្មភាពដូចជា (១) ពង្រឹងសមត្ថភាពមន្ត្រីក្នុងការត្រួតពិនិត្យក្រុមហ៊ុនរ៉ែទាំងផ្នែកបច្ចេកទេស និងទាំងផ្នែកហិរញ្ញវត្ថុ (២) ពង្រឹងសមត្ថភាពមន្ត្រីក្នុងការធ្វើអធិការកិច្ចការដ្ឋានអាជីវកម្មធនធានរ៉ែលើសុវត្ថិភាពការងារ និងសុខភាព (៣) ពង្រឹងយន្តការ និងសមត្ថភាពមន្ត្រីក្នុងការកៀរគរប្រមូលចំណូលពីវិស័យរ៉ែ (៤) កសាងសមត្ថភាពមន្ត្រីលើផ្នែកផែនទីភូគព្ភសាស្ត្រ បរិស្ថាន និងការគ្រប់គ្រង និងដំណើរការមន្ទីរពិសោធន៍ (៥) ពិនិត្យរៀបចំបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យរ៉ែរយៈពេលខ្លី និងមធ្យមសម្រាប់បណ្តុះបណ្តាលកម្មករជំនាញ និងអ្នកបច្ចេកទេស (៦) លើកផែនការតម្រូវធនធានមនុស្សរយៈពេល៥ឆ្នាំម្តង ដោយសហការជាមួយស្ថាប័នអប់រំដើម្បីបញ្ចូលក្នុងកម្មវិធីបណ្តុះបណ្តាលចំពោះអ្នកបច្ចេកទេសជាន់ខ្ពស់ និងវិស្វករជំនាញ (៧) សហការជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍនានាដើម្បីស្នើសុំការបណ្តុះបណ្តាលរយៈពេលវែង និងលើជំនាញបច្ចេកទេសបន្ថែម ក្នុងគោលដៅបន្ថយឱ្យបានជាអតិបរមានូវការប្រើបុគ្គលិក និងអ្នកជំនាញការបរទេស។

**៣.ការធ្វើសារពើភណ្ឌធនធានរ៉ែ** ដែលមានផែនការសកម្មភាពដូចជា៖ (១) ជំរុញរៀបចំសារពើភណ្ឌជាតិធនធានរ៉ែដោយបង្កើតឱ្យមានឃ្លាំងទិន្នន័យ និងផែនទីភូគព្ភសាស្ត្រ និងធនធានរ៉ែផ្សេងៗ តាមរយៈការកំណត់អត្តសញ្ញាណធនធានរ៉ែ តំបន់ធនធានរ៉ែ និងទិន្នន័យជម្រករ៉ែ (២) ដំណើរការ វិភាគបកស្រាយទិន្នន័យភូគព្ភសាស្ត្រ និងធ្វើការវាយតម្លៃធនធានរ៉ែ (៣) ធ្វើបច្ចុប្បន្នកម្មទិន្នន័យ ផែនទីភូគព្ភសាស្ត្រ និងផែនទីធនធានរ៉ែជាប្រចាំ (៤) កំណត់បង្កើតតំបន់ធនធានរ៉ែដែលក្នុងនោះបែងចែកជាតំបន់ការពារធនធានរ៉ែ និងតំបន់បម្រុងទុកធនធានរ៉ែ។ តំបន់ការពារធនធានរ៉ែ គឺជាតំបន់ដែលសន្ទស្សន៍រ៉ែត្រូវបានស្រាវជ្រាវរកឃើញ ឬជាតំបន់រចនា-

សម្ព័ន្ធភូគព្ភសាស្ត្របានបង្ហាញអំពីលទ្ធភាពនៃវត្តមានធនធានរ៉ែ រីឯតំបន់បម្រុងទុកធនធានរ៉ែ គឺជាតំបន់ដែលជម្រករ៉ែត្រូវបានស្រាវជ្រាវរកឃើញ ហើយព័ត៌មាន និងទិន្នន័យភូគព្ភសាស្ត្រអំពីសក្តានុពលធនធានរ៉ែត្រូវបានកំណត់ (៥) រៀបចំបង្កើតមន្ទីរពិសោធន៍រ៉ែ ឃ្លាំងតម្កល់សំណាកគំរូរ៉ែ និងសារមន្ទីរភូគព្ភសាស្ត្រជាតិ (៦) បង្កើតបណ្ណសារដ្ឋានភូគព្ភសាស្ត្រ ដើម្បីរក្សាទុកឯកសារ និងសម្រាប់ការសិក្សាស្រាវជ្រាវ (៧) ប្រមូលចងក្រងព័ត៌មានភូគព្ភសាស្ត្រដែលមានស្រាប់ និងធ្វើការចងក្រងផែនទីតិចតួនិចភូគព្ភសាស្ត្រ ១/៥០០ ០០០ ក្នុងតំបន់នៃប្រទេសទាំងមូល (៨) រៀបចំគោលការណ៍ណែនាំក្រុមហ៊ុនរ៉ែ ក្នុងការផ្តល់របាយការណ៍បច្ចេកទេសដើម្បីងាយស្រួលក្នុងការចងក្រងវិភាគទិន្នន័យនៃការស្វែងរុករកធនធានរ៉ែថ្មីៗ (៩) លើកទឹកចិត្តការសិក្សាស្រាវជ្រាវរ៉ែវិទ្យុសកម្ម ដើម្បីឱ្យដឹងអំពីសក្តានុពលដោយសហការជាមួយនឹងដៃគូអភិវឌ្ឍ ឬស្ថាប័នជំនាញអន្តរជាតិ។

**៤.អភិបាលកិច្ចល្អ និងការគ្រប់គ្រងប្រកបដោយគណនេយ្យភាព និងតម្លាភាព** មានផែនការសកម្មភាពដូចជា (១) អនុវត្តនូវអភិបាលកិច្ចល្អចាប់តាំងពីការចាប់ផ្តើមជំហានដំបូងនៃការសិក្សាអង្កេតភូគព្ភសាស្ត្ររហូតដល់ដំណាក់កាលអាជីវកម្ម (២) កំណត់រៀបចំជាគោលការណ៍សំខាន់ៗនៃអភិបាលកិច្ចល្អ មានជាអាទិ៍ ការធ្វើរបាយការណ៍ ការធ្វើអធិការកិច្ច ការបញ្ជ្រាបព័ត៌មានទៅប្រជាពលរដ្ឋ ការធ្វើទំនាក់ទំនង និងនីតិវិធីនៃការពិគ្រោះយោបល់រវាងភាគីពាក់ព័ន្ធ (៣) គ្រប់គ្រង ប្រមូល និងប្រើប្រាស់ចំណូលធនធានរ៉ែប្រកបដោយតម្លាភាពស្របតាមគោលការណ៍នៃច្បាប់ (៤) បង្កើតយន្តការកៀរគរប្រមូលចំណូលធនធានរ៉ែដែលជាយន្តការចម្បងក្នុងការអនុវត្តគោលនយោបាយប្រកបដោយតម្លាភាព និងគណនេយ្យភាព។ យន្តការនេះតម្រូវឱ្យមានមន្ត្រីដែលមាននីតិសម្បទានជានគរបាលយុត្តិធម៌ដែលអាចធ្វើការផាកពិន័យ កៀរគរចំណូលចូលរដ្ឋ និង/ឬកសាងសំណុំរឿងទៅតុលាការលើបទល្មើសធនធានរ៉ែ ដែលប៉ះពាល់ដល់បរិស្ថាន សង្គម និងចំណូលជាតិ (៥) បង្កើតយន្តការពិគ្រោះយោបល់ក្នុងន័យផ្តល់នូវតម្លាភាព និងឱកាសចូលរួមពីប្រជាពលរដ្ឋក្នុងសហគមន៍ដែលរងផលប៉ះពាល់ យន្តការនេះនឹងត្រូវអនុវត្តន៍មុនពេលផ្តល់អាជ្ញាបណ្ណធនធានរ៉ែ សំដៅទទួលយកមតិយោបល់ស្ថាបនា ចូលរួមពិភាក្សាដោះស្រាយបញ្ហាប្រឈមដែលអាចនឹងកើតមាន និងប្រមូលធាតុចូលក្នុងការសម្រេចផ្តល់អាជ្ញា-បណ្ណ (៦) បង្កើតយន្តការផ្សព្វផ្សាយព័ត៌មានរ៉ែដល់សាធារណជនតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងតាមរយៈព្រឹត្តិបត្រព័ត៌មានវិស័យរ៉ែឱ្យបានទៀតទាត់។

**៥.ការជំរុញវិនិយោគ** មានផែនការសកម្មភាពដូចជា (១) ផ្តល់នូវទិន្នន័យបឋមតាមរយៈការផ្សព្វផ្សាយ និងដាក់ក្នុងគេហទំព័រដើម្បីធ្វើការទាក់ទាញ ការវិនិយោគក្នុងវិស័យរ៉ែ និងជួយសម្រួលដល់វិនិយោគិនក្នុងដំណាក់កាលសិក្សាដំបូង ឬបុរេសនា (២) ផ្តល់ទិន្នន័យ និងព័ត៌មានលម្អិតដល់វិនិយោគិនដែលមានសក្តានុ-ពល ដោយឈរលើមូលដ្ឋានបង់ថ្លៃ (៣) អនុវត្តនូវគោលការណ៍ អ្នកមកមុនទទួលបានសេវាមុន (៤) ផ្តល់នូវ

ការធានាដល់វិនិយោគិនដែលទទួលបានសិទ្ធិស្វែងរុករកធនធានរ៉ែ ក្នុងតំបន់សម្បទានធនធានរ៉ែនូវសិទ្ធិទទួលបានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែស្របតាមគោលការណ៍នៃច្បាប់ និងបទប្បញ្ញត្តិដែលទាក់ទងនិងវិស័យរ៉ែ (៥) រៀបចំរបបពន្ធអាករពិសេសសម្រាប់វិស័យរ៉ែដោយឈរលើគោលការណ៍យុត្តិធម៌ តម្លាភាពដើម្បីរក្សាស្ថិរភាពនៃចំណូល និងភាពប្រកួតប្រជែងដោយយកចិត្តទុកដាក់ជាពិសេសចំពោះការប្រើប្រាស់ធនធានរ៉ែធ្វើជាវត្ថុធាតុដើម សម្រាប់បម្រើឱ្យឧស្សាហកម្មក្នុងស្រុក និងការកែច្នៃផលិតផលរ៉ែសំដៅបង្កើតនូវតម្លៃបន្ថែម។ រៀបចំនីតិវិធីប្រមូលចំណូលសួយសារ និងកំណត់នូវអត្រាសួយសារសមស្របតាមប្រភេទរ៉ែនីមួយៗ។

**គោលដៅទី២ ជំរុញការធ្វើប្រតិបត្តិការធនធានរ៉ែប្រកបដោយចីរភាព និងការទទួលខុសត្រូវ**

**១.ការអនុវត្តអភិក្រមអភិវឌ្ឍប្រកបដោយចីរភាព** មានផែនការសកម្មភាពដូចជា (១) រៀបចំសេចក្តីសម្រេចដោយសមាហរណកម្មបញ្ហាបរិស្ថាន សេដ្ឋកិច្ច និងសង្គម ដើម្បីធានាឱ្យការអភិវឌ្ឍធនធានរ៉ែដំណើរការប្រកបដោយចីរភាព (២) រៀបចំអភិក្រមឆ្លើយតបដោយការទទួលខុសត្រូវ ដែលក្នុងនោះត្រូវមានយន្តការដោះ-ស្រាយឱ្យបានទាន់ពេលវេលាចំពោះសំណូមពររបស់អ្នកពាក់ព័ន្ធទាំងអស់ (ក្រុមហ៊ុន ប្រជាជនក្នុងតំបន់រ៉ែ និងជិតខាងតំបន់រ៉ែ និងរដ្ឋបាលថ្នាក់ក្រោមជាតិ) និងបញ្ហាដែលកើតមានឡើងនៅក្នុងប្រតិបត្តិការធនធានរ៉ែ (៣) រៀបចំក្រុម-ប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធក្នុងទិសដៅធ្វើឱ្យមានសង្គតិភាពរវាងផែនការអភិវឌ្ឍវិស័យរ៉ែ និងផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានាមានផ្លូវថ្នល់ ផ្លូវដែក អគ្គិសនី ទឹកស្អាត (៤) រៀបចំអភិក្រមតួនាទីដែលមិនមែនជាបញ្ញត្តិកម្ម ដើម្បីឱ្យក្លាយជាមធ្យោបាយដ៏មានប្រសិទ្ធិភាពមួយទៀត ក្នុងការជួយធ្វើឱ្យសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងការទទួលខុសត្រូវ។ តួនាទីនេះមានសារៈសំខាន់ក្នុងការបំពេញបន្ថែម ទៅលើបញ្ញត្តិកម្មដែលមិនទាន់ពេញលេញ ឬចន្លោះប្រហោង ដូចជាក្រមប្រតិបត្តិ គោលការណ៍ណែនាំ និងគំនិតផ្តួចផ្តើមស្ម័គ្រចិត្ត ដទៃទៀតដែលមិនមានចែងក្នុងបញ្ញត្តិកម្ម (៥) ផ្តោតការយកចិត្តទុកដាក់លើសារៈសំខាន់នៃវិទ្យា-សាស្ត្ររ៉ែ ដោយជំរុញឬតម្រូវឱ្យប្រើប្រាស់បច្ចេកវិទ្យាជឿនលឿនក្នុងការធ្វើអាជីវកម្មធនធានរ៉ែ។ ការវាយតម្លៃកំណត់បានយ៉ាងសុក្រឹត អំពីជម្រករ៉ែ អាស្រ័យដោយការប្រើប្រាស់វិធីសាស្ត្រស្វែងរុករកទំនើប និងមានលក្ខណៈវិទ្យាសាស្ត្រ ហើយដើម្បីឱ្យការទាញយករ៉ែរក្សាបាននូវការប្រើប្រាស់វិស្វកម្មជឿនលឿន រួមនឹងឧបករណ៍សម្ភារៈព្រមទាំងបច្ចេកវិទ្យាទំនើបៗផងដែរ (៦) ផ្តល់ការគាំទ្រលើទស្សនទាននៃការការពារបរិស្ថាន ដោយឈរលើគោលការណ៍ការពារបរិស្ថានក្នុងប្រតិបត្តិការធនធានរ៉ែ ដែលគិតគូរចាប់តាំងពីដំណាក់កាលសិក្សាស្រាវជ្រាវការទាញយករ៉ែ ប្រព្រឹត្តិកម្មរ៉ែ ការប្រើប្រាស់ឧបករណ៍ គ្រឿងចក្រ ថាមពល ប្រព័ន្ធគ្រប់គ្រងសំណល់រ៉ែ ការទុកដាក់សំណល់ និងការបិទការដ្ឋានរ៉ែ។

**២. ការគ្រប់គ្រងបរិស្ថាន** មានផែនការសកម្មភាពដូចជា (១) កំណត់ស្តង់ដាគោលការណ៍ការពារបរិស្ថានសម្រាប់ក្រុមហ៊ុនរ៉ែអនុវត្តទៅតាមដំណាក់កាលនៃផែនការអភិវឌ្ឍ (២) កំណត់ស្តង់ដារនៃការគ្រប់គ្រង និងប្រើ-ប្រាស់ទឹក ទឹកលើដី និងក្រោមដី (៣) កំណត់ស្តង់ដានៃការគ្រប់គ្រង និងការបញ្ចេញចោលសំណល់រាវ ក្នុងនោះត្រូវយកចិត្តទុកដាក់ចំពោះការប្រើប្រាស់ទឹកសំណល់ឡើងវិញ (៤) កំណត់ស្តង់ដានៃការគ្រប់គ្រងសំណល់រ៉ែដើម្បីធានាថារចនាសម្ព័ន្ធទាំងអស់មានដូចជាកន្លែងទុកដាក់សំណល់ និងប្រព័ន្ធគ្រប់គ្រងសំណល់រ៉ែ ត្រូវបានរៀបចំ និងដំណើរការត្រឹមត្រូវតាមបច្ចេកទេសក្នុងប្រតិបត្តិការធនធានរ៉ែ និងបន្ទាប់ពីពេលអណ្តូងរ៉ែត្រូវបានបិទ (៥) អនុវត្តផែនការនីតិសម្បទាអណ្តូងរ៉ែដែលបានបិទ ដោយធានាថាផែនការដែលបានរៀបចំជាមុននោះ ធ្វើបានត្រឹមត្រូវតាមកម្រិតស្តង់ដារ និងត្រូវបានធ្វើបច្ចុប្បន្នកម្ម កែតម្រូវជាទៀងទាត់។ ចំពោះអណ្តូងរ៉ែដែលការទាញយករ៉ែមានរយៈពេលខ្លី ការវាយតម្លៃឡើងវិញ ផែនការនីតិសម្បទាអណ្តូងរ៉ែត្រូវធ្វើឱ្យបានញឹកញាប់ជាងអណ្តូងរ៉ែដែលការទាញយករ៉ែមានរយៈពេលវែង។ ទន្ទឹមនោះត្រូវបង្កើតយន្តការធានាហិរញ្ញវត្ថុសម្រាប់ការបិទការដ្ឋានអណ្តូងរ៉ែ ដែលត្រូវតែមានគ្រប់គ្រាន់ក្នុងការចំណាយសម្រាប់ដំណើរការបិទអណ្តូងរ៉ែ និងក្នុងការធ្វើនីតិ-សម្បទានអណ្តូងរ៉ែដែលបញ្ហានេះត្រូវរៀបចំតាំងពីដំណាក់កាលដំបូងនៃអាជីវកម្មធនធានរ៉ែ។

**៣.ការធានានូវសុវត្ថិភាពអណ្តូងរ៉ែ** មានផែនការសកម្មភាពដូចជា (១) ពង្រឹងសមត្ថភាពរបស់មន្ត្រីអធិការកិច្ចធនធានរ៉ែក្នុងការអនុវត្តបទប្បញ្ញត្តិស្តីពីសុវត្ថិភាព និងសុខភាពអណ្តូងរ៉ែ ដែលទាមទារនូវការបណ្តុះបណ្តាលរយៈពេលខ្លី និងមធ្យម។ ជាពិសេសត្រូវយកចិត្តទុកដាក់បំពាក់បំប៉នជំនាញជាមូលដ្ឋាន ទន្ទឹមនឹងការបណ្តុះបណ្តាលផ្ទាល់នៅនឹងកន្លែងចំពោះមន្ត្រីថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ដើម្បីឱ្យការត្រួតពិនិត្យមានភាពងាយស្រួល និងឆ្លើយតបទៅនឹងសភាពការណ៍ដែលកើតឡើងជាយថាហេតុបានទាន់ពេលវេលា (២) រៀបចំគោលការណ៍សុវត្ថិភាព និងសុខភាពអណ្តូងរ៉ែទៅតាមប្រភេទនៃអាជីវកម្មធនធានរ៉ែដូចជាប្រភេទអណ្តូងរ៉ែបើកមានការដ្ឋានវាយថ្ម ការដ្ឋានថ្មអារ ការដ្ឋានត្បូងថ្ម ប្រភេទអណ្តូងរ៉ែក្រោមដី មានអណ្តូងរ៉ែលោហៈ អណ្តូងរ៉ែអលោហៈ (៣) តម្រូវឱ្យក្រុមហ៊ុនរ៉ែបង្កើតគោលការណ៍សុវត្ថិភាព និងសុខភាពអណ្តូងរ៉ែជាក់ស្តែងតាមប្រភេទនៃប្រតិបត្តិការធនធានរ៉ែ និងស្ថានភាពនៃទីតាំងការដ្ឋានរបស់ខ្លួន (៤) តម្រូវឱ្យក្រុមហ៊ុនរ៉ែបង្កើតប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពអណ្តូងរ៉ែ ដែលរួមបញ្ចូលនូវការគ្រប់គ្រងហានិភ័យ និងការប្រតិបត្តិ ដែលធានានូវសុវត្ថិ-ភាព និងសុខភាពអណ្តូងរ៉ែរបស់មនុស្សដែលអាចរងផលប៉ះពាល់ពីប្រតិបត្តិការធនធានរ៉ែ។ ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងសុខភាពអណ្តូងរ៉ែត្រូវរៀបចំជាប្រព័ន្ធឯកសារដែលអាចធ្វើសវនកម្មបាន និងជាផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រងដោយរួមមានរចនាសម្ព័ន្ធចាត់តាំង ផែនការសកម្មភាព ការទទួលខុសត្រូវ ការប្រតិបត្តិ នីតិវិធីដំណើរការ និងធនធានសម្រាប់ការអភិវឌ្ឍសមត្ថភាព ការអនុវត្ត និងការត្រួតពិនិត្យឡើងវិញ។

**៤.ការទាញយកធនធានរ៉ែឱ្យអស់ពីលទ្ធភាព** មានផែនការសកម្មភាពដូចជា (១) កំណត់ស្តង់ដារអត្រារ៉ែបន្ទាប់បន្សំអប្បបរមាដែលត្រូវធ្វើប្រព្រឹត្តិកម្មចម្រាញ់យក និងតម្រូវឱ្យមានការវាយតម្លៃសន្ទស្សន៍ធនធានរ៉ែបន្ទាប់បន្សំដែលមាននៅក្នុងរ៉ែចម្បងក្នុងការធ្វើអាជីវកម្មធនធានរ៉ែ (២) កំណត់កម្រិតកាត់ចេញដោយផ្អែកលើការវាយតម្លៃសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ (៣) ជំរុញការប្រើប្រាស់បច្ចេកវិទ្យាទំនើប និងលើកទឹកចិត្តចំពោះការប្រើប្រាស់វិធីសាស្ត្រនៃការធ្វើអាជីវកម្មធនធានរ៉ែមានលក្ខណៈវិទ្យាសាស្ត្រ។

**៥.ការអភិវឌ្ឍធនធានរ៉ែ និងតំបន់ការពារធម្មជាតិ** មានផែនការសកម្មភាពដូចជា (១) បង្កើតនីតិវិធីដោយឡែកសម្រាប់ការធ្វើបុរេសនា និងការស្វែងរុករកធនធានរ៉ែនៅក្នុងតំបន់ការពារធម្មជាតិ ដោយយកចិត្តទុកដាក់អំពីផលប៉ះពាល់បរិស្ថាន ព្រៃឈើ ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ សត្វ និងរុក្ខជាតិ (២) បង្កើតនីតិវិធីដោយឡែកក្នុងការអនុញ្ញាតឱ្យធ្វើអាជីវកម្មធនធានរ៉ែ នៅក្នុងតំបន់ការពារធម្មជាតិ និងសិក្សាកំណត់លក្ខខណ្ឌចាំបាច់នានាក្នុងការការពារបរិស្ថាន ព្រៃឈើ ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ សត្វ និងរុក្ខជាតិ។ ការប្រើប្រាស់ឧបករណ៍ដែលមានបច្ចេកវិទ្យាខ្ពស់ ដែលកាត់បន្ថយផលប៉ះពាល់បរិស្ថានជាអតិបរមាក្នុងការទាញយករ៉ែ គឺជាប្រការតម្រូវចាំបាច់ក្នុងការធ្វើអាជីវកម្ម (៣) បង្កើតលក្ខខណ្ឌដោយឡែកសម្រាប់ការបង្កើតរោងចក្រប្រព្រឹត្តិកម្មរ៉ែ នៅក្នុងតំបន់ការពារធម្មជាតិ (៤) បង្កើតយន្តការត្រួតពិនិត្យតាមកាលកំណត់ និងដោយមិនចាំបាច់ជូនដំណឹងមុន ដោយអនុវត្តនូវវិធានការដែលមានប្រសិទ្ធិភាព ដើម្បីពិនិត្យវាយតម្លៃការប្រតិបត្តិរបស់ក្រុមហ៊ុនរ៉ែ និងចាត់វិធានការឆ្លើយតបឱ្យបានទាន់ពេលវេលា។

**គោលដៅទី៣ - អភិវឌ្ឍធនធានរ៉ែ និងសហគមន៍**

**១.ការអភិវឌ្ឍសហគមន៍** មានផែនការសកម្មភាពដូចជា (១) កំណត់ការរៀបចំផែនការទទួលខុសត្រូវសង្គមរួម (Corporate Social Responsibility) ជាផ្នែកមួយនៃការសិក្សាសមិទ្ធិលទ្ធភាព ដែលក្រុមហ៊ុនឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ត្រូវដាក់ជូនរាជរដ្ឋាភិបាលក្នុងពេលស្នើសុំអាជ្ញាបណ្ណ ឧស្សាហកម្មអាជីវកម្មធនធានរ៉ែ។ ផែនការនេះត្រូវរួមបញ្ចូលនូវការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ធនធានរ៉ែ និងដោយឡែកចំពោះតំបន់ដាច់ស្រយាលត្រូវបញ្ចូលនូវផែនការផ្តល់សេវាអប់រំ ផ្តល់ទឹកស្អាត និងការការពារសុខភាពបឋមដល់ប្រជាពលរដ្ឋក្នុងសហគមន៍ធនធានរ៉ែ។ (២) ជំរុញឱ្យក្រុមហ៊ុនឧស្សាហកម្មអាជីវកម្មធនធានរ៉ែបង្កើតមូលនិធិអភិវឌ្ឍសង្គមនៅក្នុងតំបន់អាជីវកម្មធនធានរ៉ែ។ ការគ្រប់គ្រង និងការប្រើប្រាស់មូលនិធិនេះ ត្រូវកំណត់ក្នុងលក្ខន្តិកៈដែលមានការឯកភាពរវាងក្រុមហ៊ុន និងសហគមន៍។ ប្រភពហិរញ្ញវត្ថុរបស់មូលនិធិ បានមកពីចំណែកនៃប្រាក់ចំណេញរបស់ក្រុមហ៊ុន និងពីការបែងចែកកម្រៃសួយសារពីរាជរដ្ឋាភិបាលក្នុងអត្រាកំណត់មួយ។ គួរកំណត់ផងដែរអំពីគោលការណ៍ និងមធ្យោបាយដោះស្រាយទំនាស់ក្នុងករណីដែលកើតមាន។ (៣) បង្កើតមូលនិធិរ៉ែ

ទ្រទ្រង់កិច្ចអភិវឌ្ឍសហគមន៍មូលដ្ឋាន ដែលក្រុមហ៊ុនរ៉ែត្រូវរួមចំណែកបង់ចូលមូលនិធិនេះ តាមអត្រាកំណត់មួយសមាមាត្រទៅនឹងបរិមាណនៃផលិតកម្មរ៉ែ។ មូលនិធិនេះ នឹងត្រូវប្រើប្រាស់ជាប្រយោជន៍ដល់សហគមន៍មូលដ្ឋានដែលការដ្ឋានរ៉ែស្ថិតនៅ ឬ រងផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោល។ (៤) បញ្ជ្រាបការយល់ដឹងជាសាធារណៈដល់ប្រជាពលរដ្ឋក្នុងតំបន់ ដែលមានគម្រោងអភិវឌ្ឍធនធានរ៉ែ តាមរយៈការអប់រំពន្យល់អំពីគម្រោងអភិវឌ្ឍនោះ។ ផែនការបញ្ជ្រាបការយល់ដឹងនេះត្រូវធ្វើដោយមានការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងតំណាងប្រជាពលរដ្ឋក្នុងសហគមន៍។ (៥) បង្កើតយន្តការអភិវឌ្ឍសហគមន៍ ដែលជាយន្តការគន្លឹះសម្រាប់សមធម៌សង្គមក្នុងការបែងចែកភាគផលដែលបានមកពីចំណូលពីវិស័យរ៉ែ ដល់សហគមន៍ និងផ្តល់ឱកាសដល់ប្រជាពលរដ្ឋក្នុងតំបន់សហគមន៍រ៉ែ ចូលរួមធ្វើការសម្រេចចិត្តក្នុងការអភិវឌ្ឍសហគមន៍មូលដ្ឋានរបស់ខ្លួនដោយផ្ទាល់។ នេះជាយន្តការចំហរដែលអាចឱ្យមានការចូលរួមពីសមាគម ឬអង្គការសង្គមស៊ីវិលផ្សេងៗ ដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការសម្របសម្រួល និងគាំទ្រដើម្បីឱ្យគម្រោងអភិវឌ្ឍសហគមន៍ទទួលបានជោគជ័យ។

**២. ការប្រើពលកម្មក្នុងតំបន់ និងការងារយេនឌ័រ** មានផែនការសកម្មភាពដូចជា (១) កំណត់គោលការណ៍ជំរុញឱ្យក្រុមហ៊ុនរ៉ែ ប្រើពលកម្ម និងសេវាកម្មដែលមានក្នុងតំបន់ដែលក្រុមហ៊ុនរ៉ែធ្វើអាជីវកម្ម។ (២) ជំរុញឱ្យក្រុមហ៊ុនរ៉ែបង្កើតវគ្គបំពាក់បំប៉នជំនាញនៅក្នុងសហគមន៍។ (៣) យកចិត្តទុកដាក់ដល់ការប្រើពលកម្មជាស្ត្រីនៅក្នុងអាជីវកម្មធនធានរ៉ែ នៅទីកន្លែងដែលមិនប្រឈមគ្រោះថ្នាក់ខ្លាំង។ ទន្ទឹមនឹងនោះយកចិត្តទុកដាក់ផ្តល់នូវសេវាថែទាំសុខភាពជាពិសេសដល់ស្ត្រី។

**៣.ជនជាតិដើមភាគតិច និងអាជីវកម្មធនធានរ៉ែ** មានផែនការសកម្មភាពក្នុងការ ផ្តល់ការការពារដល់ជនជាតិដើមភាគតិចក្នុងតំបន់អភិវឌ្ឍធនធានរ៉ែ ដោយរក្សាឱ្យបាននូវសិទ្ធិសេរីភាពទំនៀមទំលាប់ ប្រពៃណី វប្បធម៌ និងជំនឿសាសនារបស់ជនជាតិដើមភាគតិចស្របតាមគោលនយោបាយ និងច្បាប់របស់រដ្ឋ។

**គោលដៅទី៤ - អភិវឌ្ឍសិប្បកម្មរ៉ែ និងអាជីវកម្មខ្នាតតូច**

**១.សិប្បកម្មរ៉ែ និងអាជីវកម្មរ៉ែខ្នាតតូច** មានផែនការសកម្មភាពដូចជា (១) សិក្សាកំណត់អត្តសញ្ញាណជម្រករ៉ែខ្នាតតូចដែលរួមមានប្រភេទនៃរ៉ែ បរិមាណរ៉ែដែលមាន (Reserve) និងទីតាំងនៃជម្រករ៉ែនោះ។ (២) ផ្តល់ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់សិប្បករនិងអាជីវកម្មរ៉ែខ្នាតតូច ឱ្យយល់ដឹងពីច្បាប់ហានិភ័យដែលបណ្តាល មកពីការប្រើប្រាស់សាធាតុគ្រោះថ្នាក់ ពីការបញ្ចៀស និងការគ្រប់គ្រងហានិភ័យ។ ការអប់រំ និងបណ្តុះបណ្តាលក៏ត្រូវផ្តោតទៅលើបញ្ហាសុខភាព សុវត្ថិភាព បរិស្ថាន និងទៅលើលក្ខណៈសេដ្ឋកិច្ចក្នុងអាជីវកម្មផងដែរ។ (៣) ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់អាជីវកម្មរ៉ែខ្នាតតូច ឱ្យមានភាពទូលំទូលាយតាមរយៈការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍ ផ្តល់នូវបច្ចេកវិទ្យាជឿនលឿនសមស្របដល់អាជីវកររ៉ែខ្នាតតូច។ (៤) សម្រួលនីតិវិធីក្នុងការស្នើសុំ

ច្បាប់អនុញ្ញាត ដោយសម្រួលបែបបទរដ្ឋបាលក្នុងការស្នើសុំ។ ទន្ទឹមនោះនឹងត្រូវពិនិត្យកំណត់ការធ្វើប្រតិភូកម្មទៅថ្នាក់ក្រោមជាតិ ចំពោះការទាញយករ៉ែដែលគ្មានគ្រោះថ្នាក់នឹងមានរយៈពេលខ្លី ដូចជាការជីកយកខ្សាច់ យកអាចម៍ដី និងវាយថ្មជាដើម។ (៥) លើកទឹកចិត្តក្នុងការចងក្រងសិប្បកម្មរ៉ែ និងអាជីវកម្មរ៉ែខ្នាតតូចជាចង្កោម ឬជាសហគមន៍ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង ការបណ្តុះបណ្តាល ការពិគ្រោះយោបល់ ការខ្ចីឥណទានពីធនាគារ និងការធ្វើពាណិជ្ជកម្មរ៉ែក្នុងគោលការណ៍ធុរកិច្ចដ៏ល្អ។ (៦) សម្រួលក្នុងទំនាក់ទំនងពាណិជ្ជកម្មជាមួយនឹងក្រុមហ៊ុនរ៉ែធំៗ ឬឧស្សាហកម្មក្នុងស្រុកលើគោលការណ៍ស្មើភាព និងសមធម៌។

**២. វិធានការ និងដំណោះស្រាយចំពោះអាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាត មានផែនការសកម្មភាពដូចជា** (១) ទប់ស្កាត់អាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាត គឺជាវិធានការដំបូង និងចាំបាច់បំផុតដែលត្រូវប្រកាន់យក។ ការចូលរួមយ៉ាងសកម្មប្រកបដោយស្មារតីទទួលខុសត្រូវ របស់រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ជាន់ថ្នាក់ ក្នុងការទប់ស្កាត់អាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាត គឺជាប្រការដ៏មានប្រសិទ្ធិភាពបំផុត ក្នុងការរួមចំណែកថែរក្សាធនធានរ៉ែឱ្យស្ថិតនៅគង់វង្សជាប្រយោជន៍របស់រដ្ឋ និងរួមចំណែករក្សាបាននូវ បរិស្ថាននិងសង្គម។ គណៈកម្មាធិការទប់ស្កាត់អាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាតពីរាជធានី ខេត្តនឹងត្រូវបង្កើតឡើងដោយមានការចូលរួមពីស្ថាប័នមន្ទីរពាក់ព័ន្ធ ព្រមទាំងត្រូវដាក់ចេញនូវយន្តការអនុវត្តជាប្រចាំ ដើម្បីកុំឱ្យអាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាតទាំងនេះកើតមានឡើងក្នុងដែនដីសមត្ថកិច្ចរបស់ខ្លួន។ (២) សិក្សាអំពីទំហំនៃអាជីវកម្មធនធានរ៉ែ ដែលគ្មានការអនុញ្ញាតដែលកំពុងកើតមានទូទាំងប្រទេស ជាពិសេសរ៉ែមាស ដោយកំណត់ឱ្យបានអំពីទីតាំង ចំនួនអ្នកជីករ៉ែដែលគ្មានការអនុញ្ញាត បែបផែននៃការធ្វើអាជីវកម្ម (ផ្ទាល់ខ្លួនឬបម្រើឱ្យឈ្មួញកណ្តាល) និងផលប៉ះពាល់។ (៣) អប់រំអំពីគ្រោះថ្នាក់នៃការប្រើប្រាស់វំសេវជាតិផ្ទុះ និងសារធាតុគីមីមានបារតស្យានីត ឬសារធាតុគីមីផ្សេងទៀតដែលបង្កគ្រោះថ្នាក់ ឬផលប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាព និង បរិស្ថានជុំវិញ។ (៤) ពិពិធកម្មមុខរបរចំពោះអ្នកជីករ៉ែដែលគ្មានការអនុញ្ញាត ក្នុងទិសដៅឱ្យពួកគេមានមុខរបរចិញ្ចឹមជីវិតផ្សេងក្រៅពីការងារយករ៉ែ ដោយសហការជាមួយនឹងក្រុមហ៊ុនសម្បទានរ៉ែក្នុងការផ្តល់នូវការងារ ការបង្កើតមុខរបរថ្មីដូចជាការធ្វើកសិកម្ម ចិញ្ចឹមសត្វ កាត់ដេរជាដើម។ សម្រាប់បម្រើផ្គត់ផ្គង់ ឬផ្តល់សេវាដល់ ក្រុមហ៊ុនសម្បទានរ៉ែវិញ។ (៥) ចងក្រងជាសហគមន៍ និងធ្វើសមាហរណកម្មស្របទៅតាមក្របខណ្ឌច្បាប់ ចំពោះអាជីវ-កម្មធនធានរ៉ែដែលគ្មានការអនុញ្ញាតនៅតំបន់ដីសាធារណៈរបស់រដ្ឋ និងដីកម្មសិទ្ធិឯកជន នៅពេលសិក្សាឃើញថាតំបន់ទាំងនោះ មិនមានសក្តានុពលធនធានរ៉ែសម្រាប់ឧស្សាហកម្មរ៉ែធំៗ។ (៦) សិក្សាកំណត់តំបន់រ៉ែមាស និងត្បូង ដែលមិនមានសក្តានុពលសេដ្ឋកិច្ចសម្រាប់បម្រើឱ្យឧស្សាហកម្មរ៉ែ ដែលស្ថិតក្នុងដីសាធារណៈរបស់រដ្ឋ ឬដីកម្មសិទ្ធិឯកជន ហើយបង្វែរទិសដៅ និងជំរុញឱ្យអ្នកធ្វើអាជីវកម្មរ៉ែដែលគ្មានការអនុញ្ញាត មកធ្វើ

អាជីវកម្មស្របច្បាប់តាមបែបសិប្បកម្ម ឬអាជីវកម្មរ៉ែខ្នាតតូចវិញ។ (៧) ជំរុញការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការទប់ស្កាត់អាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាត។ (៨) រៀបចំអភិក្រមតួនាទីរបស់សង្គមស៊ីវិលក្នុងកិច្ចសហការជាមួយនឹងរាជរដ្ឋាភិបាល ដើម្បីទប់ស្កាត់អាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាតដោយផ្តល់លទ្ធភាពឱ្យសង្គមស៊ីវិល អាចផ្តល់ព័ត៌មានជាក់ស្តែងដល់ស្ថាប័នមានសមត្ថកិច្ច និងផ្តល់យោបល់ក្នុងន័យស្ថាបនាដោយសហការជាមួយនឹងរាជរដ្ឋាភិបាលក្នុងការធ្វើការអប់រំបណ្តុះបណ្តាល និងជំរុញការធ្វើពិពិធកម្មមុខរបរដល់អ្នកធ្វើអាជីវកម្មធនធានរ៉ែដែលគ្មានការអនុញ្ញាត។

**គោលដៅទី៥ ធនធានរ៉ែ និងការនាំចេញ**

**១.នយោបាយនាំចេញ មានផែនការសកម្មភាពដូចជា** (១) រៀបចំលិខិតបទដ្ឋានគតិយុត្ត អំពីការគ្រប់គ្រងការនាំចេញផលិតផលរ៉ែដោយពិនិត្យពិចារណាអំពីផលិតផលរ៉ែ ដែលអាចយកមកធ្វើប្រព្រឹត្តិកម្មបន្ត ឬកែច្នៃ ឬធ្វើជាវត្ថុធាតុដើមបម្រើឱ្យឧស្សាហកម្មក្នុងស្រុក ដូចជាផលិតផលរ៉ែដែលបានមកពីរ៉ែឧស្សាហកម្ម រ៉ែលោហៈ ឬរ៉ែអលោហៈផ្សេងៗព្រមទាំងផលិតផលរ៉ែសំណង់ (២) រៀបចំបញ្ជីយថាប្រភេទផលិតផលរ៉ែដែលអាចនាំចេញបានដោយផ្អែកលើការវាយតម្លៃឧត្តមភាពប្រៀបធៀបសេដ្ឋកិច្ច និងផលប្រយោជន៍សង្គម និង បរិស្ថាន។ បញ្ជីនេះត្រូវធ្វើបច្ចុប្បន្នភាពយ៉ាងយូរបីឆ្នាំម្តង។

**២.ការនាំចេញផលិផលរ៉ែក្នុងលទ្ធភាពផ្តល់នូវតម្លៃបន្ថែមខ្ពស់** មានផែនការសកម្មភាពដូចជា (១) លើក-ទឹកចិត្តក្នុងការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍ ដើម្បីធ្វើឱ្យកាន់តែល្អប្រសើរឡើងនូវផលិតភាព (២) លើកទឹកចិត្តក្នុងការកែច្នៃធនធានរ៉ែ និងផលិតផលរ៉ែ មុននឹងធ្វើការនាំចេញ (៣) ពិនិត្យសិក្សាតម្លៃផលិតផលរ៉ែលើទីផ្សារអន្តរ-ជាតិជាប្រចាំ ដើម្បីបម្រើឱ្យការធ្វើសេចក្តីសម្រេចដ៏ត្រឹមត្រូវក្នុងយុទ្ធសាស្ត្រនាំចេញផលិតផលរ៉ែ (៤) ពិនិត្យសិក្សាអំពីបម្រែបម្រួលតម្រូវការផលិតផលរ៉ែទាំងក្នុងពេលបច្ចុប្បន្ន ក៏ដូចជាការនិទស្សន៍ពីបម្រែបម្រួលនាពេលអនាគត។

**៣.ការសម្រួលពាណិជ្ជកម្ម** មានផែនការសកម្មភាពដូចជា (១) សិក្សាកំណត់នីតិវិធីសម្រួលពាណិជ្ជកម្ម និងបែបបទនាំចេញផលិតផលរ៉ែ (២) រៀបចំប្រកាសអន្តរក្រសួងរវាងក្រសួងរ៉ែ និងថាមពល ជាមួយនឹងស្ថាប័នដែលពាក់ព័ន្ធនឹងនីតិវិធីសម្រួលពាណិជ្ជកម្ម និងបែបបទនាំចេញនោះ ក្នុងករណីចាំបាច់។

## ៣.២. វិស័យថាមពល

ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា ក្រសួងរ៉ែ និងថាមពល នឹងបន្តការងារអាទិភាពរបស់ខ្លួន ក្នុងការគ្រប់គ្រង និងជំរុញការអភិវឌ្ឍវិស័យអគ្គិសនី ដើម្បីឈានទៅសម្រេចឱ្យបានការផ្គត់ផ្គង់ថាមពលអគ្គិសនីមួយគ្រប់គ្រាន់មានចីរភាព អាចទុកចិត្តបាន មានគុណភាព និងមានថ្លៃសមរម្យសម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ និងគ្រប់គ្រង និងជំរុញការអភិវឌ្ឍប្រសិទ្ធិភាព

ថាមពល និងសន្សំសំចៃថាមពល។ ក្រសួងក៏មានគោលដៅគ្រប់គ្រង និងជំរុញការស្រាវជ្រាវ ការអភិវឌ្ឍ និងការប្រើប្រាស់ថាមពលបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម និងបច្ចេកទេសថាមពលបរមាណូ ក្នុងគោលបំណងសន្តិភាព សុវត្ថិភាព និងមានសន្តិសុខ។ ដើម្បីសម្រេចបាននូវការប្តេជ្ញាខាងលើ រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងរ៉ែ និងថាមពល បានដាក់ចេញនូវសកម្មភាពយុទ្ធសាស្ត្រមួយចំនួនដូចខាងក្រោម៖

- ជំរុញការអភិវឌ្ឍវិស័យថាមពល និងថាមពលអគ្គិសនី ដោយបង្កើនការតភ្ជាប់អគ្គិសនីជូនប្រជាពលរដ្ឋប្រកបដោយគុណភាព ស្ថិរភាព និងថ្លៃសមរម្យដែលផលិតពីប្រទេសផ្សេងៗ រួមទាំងវារីអគ្គិសនី ចំហេះ និងពន្លឺព្រះអាទិត្យ។
- ពង្រឹងការងារបច្ចេកទេសថាមពល និងស្តង់ដារអគ្គិសនីក្នុងអគារ និងលំនៅដ្ឋាន។
- ពង្រឹងការងារវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាថាមពលបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម និងបច្ចេកទេសថាមពលបរមាណូ[54]។

## ៣.៣.វិស័យប្រេងកាត

ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦ នៃរដ្ឋសភា ក្រសួងរ៉ែ និងថាមពល មានបេសកកម្មយ៉ាងធំធេងក្នុងការអភិវឌ្ឍវិស័យប្រេងកាតឱ្យអស់លទ្ធភាព តាមរយៈការស្វែងរុករក អភិវឌ្ឍផលិតកម្ម ប្រព្រឹត្តិកម្ម ដឹកជញ្ជូន សន្និធិ និងការធ្វើពាណិជ្ជកម្មប្រេង និងឧស្ម័ន ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងផលប្រយោជន៍យូរអង្វែងនៃប្រទេសជាតិ និងភាពល្អប្រសើរនៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា[55]។

ដើម្បីសម្រេចបាននូវបេសកកម្មខាងលើ ក្រសួងរ៉ែ និងថាមពល នឹងរៀបចំគោលនយោបាយជាតិប្រេងកាតឆ្នាំ២០២០ - ២០៣០ និងដាក់ចេញផែនការសកម្មភាព សម្រាប់អនុវត្តឱ្យបានចប់សព្វគ្រប់នៅឆ្នាំ២០២០។ សកម្មភាពជាអាទិភាព រួមមានដូចខាងក្រោម៖

- កសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- កសាងសមត្ថភាព និងពង្រឹងស្ថាប័ន ទាំងផ្នែកអាប់ស្រ្ទីម និងដោនស្ទ្រីម
- បង្កើនចំណូលពីវិស័យប្រេងកាត
- ជំរុញភាពទទួលខុសត្រូវសង្គម និងបរិស្ថានក្នុងប្រតិបត្តិការប្រេងកាត និងសន្តិសុខថាមពល[56]។

[54] ដកស្រង់ចេញពីចំណុច ៤.១០០ ចេញពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៩-២០២៣ ទំព័រទី២៨៣

[55] ដកស្រង់ចេញពីចំណុច ៤.១១២ ចេញពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៩-២០២៣ ទំព័រទី២៩៤

[56] ដកស្រង់ចេញពីចំណុច ៤.១១៣ ចេញពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៩-២០២៣ ទំព័រទី២៩៤

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវកន្លងមក ក្រសួងរ៉ែ និងថាមពល ជាស្ថាប័នថ្មីមួយដែលបានបង្កើតនៅក្នុងនីតិកាលទី៥ នៃរដ្ឋសភា តាមរយៈព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ ២០១៣។ ដោយក្នុងនោះការបង្កើតក្រសួងរ៉ែ និងថាមពលនេះឡើង គឺបានមកពីការរួមបញ្ចូលគ្នារវាងពីរស្ថាប័នគឺ ស្ថាប័នទី១ សំដៅដល់អតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលបានផ្តាច់ខ្លួនជាពីរ ដែលមួយបង្កើតបានជាក្រសួងឧស្សាហកម្ម និងសិប្បកម្ម (បច្ចុប្បន្នបានប្តូរឈ្មោះមកជា ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តាមរយៈព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ស្តីពីច្បាប់បង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍) និងមួយទៀតបង្កើតជាក្រសួងរ៉ែ និងថាមពល និងស្ថាប័នទី២ គឺជាអតីតអាជ្ញាធរប្រេងកាតជាតិកម្ពុជា ដែលបានការផ្ទេរ និងធ្វើសមាហរណកម្មអាជ្ញាធរប្រេង-កាតជាតិកម្ពុជាទៅក្រោមក្រសួងរ៉ែ និងថាមពល ដោយឡែកអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវស្ថិតនៅក្រោមការដឹកនាំ និងគ្រប់គ្រងផ្នែកគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការរបស់ក្រសួងរ៉ែ និងថាមពល។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល នៅពេលបច្ចុប្បន្ននេះ ត្រូវបានបែងចែកជាពីរអង្គភាពគឺ អង្គភាពថ្នាក់ជាតិ និងអង្គភាពថ្នាក់ក្រោមជាតិ។ អង្គភាពថ្នាក់ជាតិត្រូវបានបែងចែកជាអង្គភាពក្រោមឱវាទរបស់ក្រសួងដូចជា (១) ខុទ្ទកាល័យ គឺជាទីកន្លែងដែលបំពេញបេសកកម្មជាជំនួយការដល់ថ្នាក់ដឹកនាំសាមីដែលជាអ្នកដឹកនាំនយោបាយលើការងារក្នុងរង្វង់រាជរដ្ឋាភិបាល និង/ឬរដ្ឋសភា ក៏ដូចជាអ្នកដឹកនាំរដ្ឋបាលក្នុងរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន (២) អគ្គាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែ និងថាមពលលើការងារអធិការកិច្ច ដែលមានភារកិច្ចក្នុងការធ្វើអធិការកិច្ចជាប្រចាំ ទៅលើការគ្រប់គ្រងអង្គភាពក្រោមឱវាទក្រសួងរ៉ែ និងថាមពល និងធ្វើរបាយការណ៍ជូនឯកឧត្តមរដ្ឋមន្ត្រី អំពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចហើយ និងអំពីមធ្យោបាយកែលម្អការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ (៣) នាយកដ្ឋានសវនកម្មផ្ទៃក្នុង បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែ និងថាមពលលើការងារសវនកម្មផ្ទៃក្នុងដោយមានភារកិច្ចក្នុងការអនុវត្តមុខងារសវនកម្មផ្ទៃក្នុងលើការពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ក្រសួង ព្រមទាំងវាយតម្លៃអំពីប្រសិទ្ធិភាពនៃការអនុវត្តប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់អង្គភាពក្រោមឱវាទក្រសួង សំដៅពង្រឹងអភិបាលកិច្ចល្អ និងធ្វើរបាយការណ៍ត្រង់ទៅប្រធានស្ថាប័ន ដោយធ្វើច្បាប់ចម្លងទៅអាជ្ញាធរសវនកម្មជាតិ និងសម្របសម្រួលការងារជាមួយសមត្ថកិច្ចត្រួតពិនិត្យនានា (៤) អគ្គនាយកដ្ឋានកិច្ចការទូទៅ បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែ និងថាមពល ព្រមទាំងមានភារកិច្ចក្នុងការគ្រប់គ្រងសម្របសម្រួលកិច្ចការរដ្ឋបាលរបស់ក្រសួងទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គ្រប់គ្រងបណ្តាញព័ត៌មានវិទ្យា និងគេហទំព័រ គ្រប់គ្រងការងារថវិកា គណនេយ្យ ហិរញ្ញវត្ថុ មន្ត្រីរាជការចំណុះក្រសួង និងទ្រព្យសម្បត្តិរបស់ក្រសួង កត់ត្រាចំណូលមិនមែនសារពើពន្ធ រៀបចំ

ផែនការ និងបូកសរុបលទ្ធផលការងាររបស់ក្រសួង ព្រមទាំងបំពេញភារកិច្ចមួយចំនួនតាមការកំណត់របស់ថ្នាក់ដឹកនាំក្រសួងរ៉ែ និងថាមពល (៥) អគ្គនាយកដ្ឋានធនធានរ៉ែ បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែ និងថាមពល លើបេសកកម្មគ្រប់គ្រងការអភិវឌ្ឍ និងការធ្វើអាជីវកម្មធនធានរ៉ែ និងជំរុញការប្រើប្រាស់ ធនធានរ៉ែ ព័ត៌មានភូគព្ភសាស្ត្រ និងធនធានរ៉ែ ដើម្បីចូលរួមចំណែកក្នុងកិច្ចអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ (៦) អគ្គនាយកដ្ឋានថាមពល បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែ និងថាមពល លើបេសកកម្មគ្រប់គ្រងវិស័យថាមពល ផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី និង (៧) អគ្គនាយកដ្ឋានប្រេងកាត បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែ និងថាមពល ដោយមានភារកិច្ចអនុវត្តគោលនយោបាយបម្រើឱ្យវិស័យប្រេងកាត និងការគ្រប់គ្រងការងារប្រេងកាតផ្នែកអាប់ស្ទ្រីម និងផ្នែកដោនស្ទ្រីម ដែលរួមមានបុរេសនាការស្វែងរុករក ការអភិវឌ្ឍ និងផលិតកម្មប្រេងកាត ការធ្វើប្រព្រឹត្តិកម្មប្រេងកាត និងគីមីប្រេងកាត ការដឹកជញ្ជូន និងចែកចាយ សន្និធិ ការនាំចេញ-ការនាំចូល និងការធ្វើពាណិជ្ជកម្មប្រេងកាតនិងផលិតផលប្រេងកាត។ ចំពោះអង្គភាពថ្នាក់ក្រោមជាតិវិញ គឺសំដៅដល់មន្ទីររ៉ែ និងថាមពលនៅតាមបណ្តា រាជធានី-ខេត្ត ដើម្បីបំពេញមុខងារពាក់ព័ន្ធនឹងវិស័យរបស់ក្រសួងរ៉ែ និងថាមពលនៅថ្នាក់ក្រោមជាតិ។

ចាប់ពីឆ្នាំ២០១៧ រហូតដល់ដើមឆ្នាំ២០២២ ក្រសួងរ៉ែ និងថាមពល បានខិតខំបំពេញបេសកកម្ម និងមុខងារភារកិច្ចយ៉ាងសស្រាក់សស្រាំ ដោយមិនខ្លាចពីភាពនឿយហត់ ដែលជាលទ្ធផលក្រសួងបានសម្រេចនៅសមិទ្ធិផលជាច្រើន សម្រាប់ចូលរួមដល់ការអភិវឌ្ឍសង្គមជាតិឱ្យមានភាពរីកចម្រើន។ ក្នុងនោះយើងឃើញថា វិស័យថាមពលបានសម្រេចនូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដូចជា ការកាត់បន្ថយថ្លៃអគ្គិសនី ដោយរាជរដ្ឋាភិបាលបាន អនុវត្តឧបត្ថម្ភធនដល់គ្រួសារក្រីក្រនៅតំបន់ជនបទចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២០ ក្រៅពីនេះ រាជរដ្ឋាភិបាល បានបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ (ម.អ.ជ.) ចំណុះក្របខណ្ឌអគ្គិសនីកម្ពុជា ដើម្បីជួយផ្តល់នូវកម្មវិធីគាំពារសង្គមក្នុងវិស័យថាមពល ដោយឡែកនៅពេលបច្ចុប្បន្ននេះ មានភូមិចំនួន ១៣,៨១៨ ដែលស្មើនឹង ៩៧.៥៣% បានសាងសង់ខ្សែបណ្តាញរួចរាល់ ហើយភូមិនៅសល់មានចំនួន ៣៥០ ស្មើនឹង ២.៤៧% នៃភូមិសរុបទូទាំងប្រទេសពុំមានខ្សែបណ្តាញទៅដល់ ដោយសារតំបន់ទាំងនោះភាគច្រើនជាតំបន់កោះ តំបន់លិចទឹកនៅរដូវវស្សា តំបន់គ្មានផ្លូវធ្វើដំណើរ តំបន់បណ្តែតទឹក តំបន់ឆ្ងាយដាច់ស្រយាលដែលមានប្រជាជនរស់នៅរាយប៉ាយ។ ចំពោះការងារគ្រប់គ្រង បច្ចេកទេសអគ្គិសនី និងបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម ក្រសួងបានចុះធ្វើការត្រួតពិនិត្យក៏ដូចជាស្រង់ទិន្នន័យលើការប្រើប្រាស់វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាថាមពលបរមាណូ រួមទាំងវិទ្យុសកម្មនៅតាមទីតាំងនានា ដូចជា ការដ្ឋានរ៉ែ រោងចក្រស៊ីម៉ងត៍ មន្ទីរពេទ្យ មន្ទីរពិសោធន៍ ជាដើម ជាពិសេសនៅក្នុងបរិបទនៃជំងឺកូវីដ១៩ ក្រសួងបានស្នើសុំអង្គការជាដៃគូផ្តល់ជំនួយ

ឧបករណ៍និងបរិក្ខាតេស្តមេរោគកូវីដ១៩ ប្រភេទ PCR ចំនួន៥ឈុត ថវិកាសរុប ប្រមាណជា៤០០ ០០០ អឺរ៉ូ។ រីឯវិស័យរ៉ែវិញ ក្រសួងបានយកចិត្តទុកដាក់ខ្ពស់ក្នុងការរៀបចំផែនការ និងអនុវត្តសកម្មភាពការងារដោយធានាឱ្យបាននូវចីរភាព កាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ដល់បរិស្ថាន និងសង្គម បង្កើនសុខដុមនីយកម្មរវាងសហគមន៍និងការដ្ឋានរ៉ែ និងចូលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាពិសេសសម្រេចបានតាមគោល-បំណង និងគោលដៅដែលបានកំណត់នៅក្នុងគោលនយោបាយជាតិស្តីពីធនធានរ៉ែ ឆ្នាំ២០១៨-២០២៨។ ដោយឡែកវិស័យប្រេងកាត ក្រសួងបានឈរលើ សសរស្តម្ភចំនួនបីគឺ ១- បង្កើតបន្ថែមខឿនឧស្សាហកម្ម និស្សារណកម្មពីវិស័យប្រេងកាត ដោយផ្តោតសំខាន់លើការងារសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រ វាយតម្លៃសេដ្ឋកិច្ច និងការរកឃើញធនធានប្រេងកាត ការផ្សព្វផ្សាយព័ត៌មាន និងការទាក់ទាញការវិនិយោគក្នុងវិស័យប្រេងកាត ការជំរុញប្រសិទ្ធិភាពប្រតិបត្តិការប្រេងកាត ការលើកកម្ពស់ជីវភាពប្រជាជនមូលដ្ឋាន និងការលើកស្ទួយការប្រើប្រាស់ទំនិញសេវាកម្មនិងពលកម្មក្នុងស្រុក និងការងារដោះស្រាយតំបន់ទាមទារដែនសមុទ្រត្រួតគ្នា ទី២- បង្កើនប្រសិទ្ធិភាពក្នុងការគ្រប់គ្រងលំហូរចំណូលជាតិ ពីវិស័យប្រេងកាត ដោយផ្តោតសំខាន់លើការពង្រឹងប្រសិទ្ធិភាពនៃប្រព័ន្ធប្រមូលចំណូល និងការកសាងសមត្ថភាជាតិក្នុងការគ្រប់គ្រងចំណូលប្រកបដោយប្រសិទ្ធិភាព និងទី៣ ការការពារបរិស្ថាន និងសង្គមក្នុងប្រតិបត្តិការប្រេងកាត ដោយផ្តោតសំខាន់លើការរៀបចំលិខិតបទដ្ឋានគតិយុត្ត ការគ្រប់គ្រងនិងត្រួតពិនិត្យសកម្មភាពផ្នែកដោនស្ទ្រីម ការពង្រឹងប្រសិទ្ធិភាពការគ្រប់គ្រងសម្បទានប្រេងកាត និងការងារអធិការកិច្ចក្នុងវិស័យប្រេងកាត។ ទន្ទឹមនឹងការសម្រេចបាននូវសមិទ្ធផលខាងលើ ក្រសួងរ៉ែ និងថាមពល បានជួបនៅប្រទះបញ្ហាប្រឈមមួយចំនួនដូចជា កាតព្វកិច្ចហិរញ្ញវត្ថុដែលមាននៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមានមួយចំនួន នៅមិនទាន់សមស្របនឹងការ វិវឌ្ឍសេដ្ឋកិច្ច ប្រសិទ្ធិភាពនៃការកៀគរការប្រមូលចំណូលពីសួយសារ សម្រាប់រដ្ឋនៅមានកម្រិត កង្វះប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគ្រប់គ្រងកិច្ចសន្យា/កិច្ចព្រមព្រៀង និងអាជ្ញាបណ្ណរ៉ែ និងថាមពល ជាពិសេសបញ្ហាប្រឈមមួយដែលគួរឱ្យកត់សម្គាល់នោះគឺ ការជាប់គាំង លែង-ដំណើរការអាជីវកម្មបូមប្រេងនៅប្រទេសកម្ពុជាបន្តទៀត ដោយសារតែក្រុមហ៊ុនទទួលសិទ្ធិធ្វើអាជីវកម្មបានប្រកាសក្ស័យធន់ ហើយប្រេងដែលបានបូមបាននោះ គឺត្រូវបាននាវា MT Strovolos បានលួចដឹកចាកចេញពីប្រទេសកម្ពុជា និងត្រូវបានចាប់ឃាត់ខ្លួននៅឯប្រទេសឥណ្ឌូ-ណេស៊ី។ បច្ចុប្បន្ននេះ កម្ពុជានៅមិនទាន់ទទួលតម្រុយថា អាចទទួលបានប្រេងដែលជារបស់កម្ពុជាវិញនៅពេលណានោះទេ ខណៈកម្ពុជាផ្ទាល់កំពុងបន្តធ្វើការលើរឿងនេះជាប់ជាប្រចាំ ដើម្បីនាំយកប្រេងដែលកម្ពុជាបាត់មកវិញគ្រប់ចំនួន។ សព្វថ្ងៃនេះមានក្រុមហ៊ុនមកពីបណ្តាប្រទេសចំនួន៥ រួមមានប្រទេសថៃ កាណាដា ចិន ម៉ាឡេស៊ី និងកាហ្សាក់ស្តង់ ដែលកំពុងចាប់អារម្មណ៍ និងសម្លឹងមើលឃើញអំពីលទ្ធភាពជីករុករកប្រេង និងឧស្ម័ននៅកម្ពុជា ដែលវត្តមាននៃក្រុមហ៊ុនទាំង

អស់នេះ ជាសញ្ញាបង្ហាញឱ្យឃើញពីក្តីសង្ឃឹមថ្មីមួយទៀតមកលើដំណើរការបូមប្រេងនៅកម្ពុជា បន្ទាប់ពីប្រតិបត្តិ-ការបូមប្រេងនេះត្រូវបានស្ងាត់សូន្យឈឹងអស់រយៈពេលជាងមួយឆ្នាំមកនេះ។ រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ក៏ដូចជាក្រសួងរ៉ែ និងថាមពល បានដាក់ចេញនៅផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៩ ២០២៣ សម្រាប់អនុវត្តនូវសកម្មភាពការងារ នៅពេលខាងមុខបន្តទៀត ដើម្បីបង្កើនប្រសិទ្ធិភាពការងារ និងបន្តការអភិវឌ្ឍវិស័យរ៉ែ វិស័យថាមពល និងវិស័យប្រេងកាត ក្នុងគោលដៅជាផលប្រយោជន៍សេដ្ឋកិច្ច និងសង្គមប្រកបដោយអភិបាលកិច្ចល្អ និងការទទួលខុសត្រូវខ្ពស់ផ្នែកបរិស្ថាន ស្របតាមការអភិវឌ្ឍប្រកបដោយចីរភាព។

ជាចុងក្រោយយើងខ្ញុំទាំងពីរអ្នក សូមធ្វើការកោតសសើរចំពោះក្រសួងរ៉ែ និងថាមពល ដែលបានខិតខំប្រឹងប្រែង អនុវត្តតួនាទីភារកិច្ច ក្នុងនាមជាស្ថាប័នមួយដែលមានទំនួលខុសត្រូវក្នុងការដឹកនាំ និងអភិវឌ្ឍទៅលើវិស័យរ៉ែ វិស័យប្រេងកាត និងវិស័យថាមពលនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យមានភាពរីកចម្រើន ហើយយើងខ្ញុំក៏សូមធ្វើការលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួងទាំងអស់ បន្តនៅការខិតខំបំពេញការងារទៅលើវិស័យទាំងបីនេះជាបន្តទៅទៀត ដើម្បីឱ្យសង្គមជាតិកាន់តែមានភាពរីកចម្រើន និងស៊ីវិល័យ។

# ឯកសារយោង

## I. លិខិតបទដ្ឋានគតិយុត្ត

### ❖ ព្រះរាជក្រម

១. ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

២. ព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ

៣. ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងរ៉ែ និងថាមពល

៤. ព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត

៥. ព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ស្តីពីច្បាប់បង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

❖ **ព្រះរាជក្រឹត្យ** លេខ នស/រកត/១២១៣/១៤០១ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្ទេរ និងធ្វើសមា-ហរណកម្មអាជ្ញាធរប្រេងកាតជាតិកម្ពុជាទៅក្រោមក្រសួងរ៉ែ និងថាមពល

### ❖ អនុក្រឹត្យ

១. អនុក្រឹត្យលេខ ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល

២. អនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន

៣. អនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល

### ❖ ប្រកាស

១. ប្រកាសលេខ ០០៨៤ រថ.បល.ប្រក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គាធិការដ្ឋានចំណុះក្រសួងរ៉ែ និងថាមពល

២. ប្រកាសលេខ០០៤៧ រថ.បល.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង

៣. ប្រកាសលេខ ០៩២ រថ.បល.ប្រក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមន្ទីររ៉ែ និងថាមពល រាជធានី-ខេត្ត

៤. ប្រកាសលេខ៣១៩ រថ.បល.ប្រក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤ ស្តីពី ការកែសម្រួលប្រការ៥ ប្រការ៦ និងតារាងឧបសម្ព័ន្ធ នៃប្រកាសលេខ០៩២ រថ.បល.ប្រក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការព្រឹត្តទៅនៃមន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត

៥. ប្រកាសលេខ០៣១៨ រថ.អកទទ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យចំណុះឱ្យនាយកដ្ឋាននានានៃអគ្គនាយកដ្ឋានកិច្ចការទូទៅ

៦. ប្រកាសលេខ០៣១៩ រថ.អកទទ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យចំណុះឱ្យនាយកដ្ឋាននានានៃអគ្គនាយកដ្ឋានប្រេងកាត

៧. ប្រកាសលេខ០៣២០ រថ.អធរ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យចំណុះឱ្យនាយកដ្ឋាននានានៃអគ្គនាយកដ្ឋានធនធានរ៉ែ

៨. ប្រកាសលេខ០៣២១ រថ.អថ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យចំណុះឱ្យនាយកដ្ឋាននានានៃអគ្គនាយកដ្ឋានថាមពល

II. **ផែនការយុទ្ធសាស្ត្រ**

១. យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣

២. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៩-២០២៣

III. **គោលនយោបាយជាតិស្តីពីធនធានរ៉ែឆ្នាំ២០១៨-២០២៨**

IV. **របាយការណ៍**

១. របាយការណ៍ការសង្ខេប ស្តីពីសមិទ្ធផលសំខាន់ៗរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៧-២០២១

២. របាយការណ៍សង្ខេបបូកសរុបបញ្ចប់ឆ្នា២០២១របស់អាជ្ញាធរអគ្គិសនីកម្ពុជា

V. **សេចក្តីប្រកាសព័ត៌មាន** លេខ ០០៣៦ រថ.អប្រក ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ស្តីពី បច្ចុប្បន្នភាពនៃនាវា MT Strovolos និងក្រុមនាវិកដែលត្រូវបានចាប់ខ្លួនពាក់ព័ន្ធនឹង បទល្មើសលួចប្រេងឆៅរបស់កម្ពុជា

## VI. គេហទំព័រ

១. រាជរដ្ឋាភិបាលកម្ពុជា https://www.ocm.gov.kh

២. ក្រសួងរ៉ែ និងថាមពល http://www.mme.gov.kh/

៣. វិទ្យុបារាំងផ្សាយជាភាសាខ្មែរ https://www.rfi.fr/km/

# សន្ទានុក្រម

- **ការស្វែងរុករក** គឺជាការសិក្សាស្រាវជ្រាវក្នុងបំណងរកឱ្យឃើញ ធ្វើតេស្តសន្ទស្សន៍រ៉ែ ដើម្បីកំណត់សក្តា-នុពល ទំហំ គុណភាព បរិមាណ ព្រមទាំងលទ្ធភាពសេដ្ឋកិច្ច អាជីវកម្មតាមរយៈការធ្វើបុរេសនា ការស្រាវជ្រាវភូគព្ភសាស្ត្រ រូបភូគព្ភសាស្ត្រ និងគីមីភូគព្ភសាស្ត្រ ការជីកកកាយ ការខួង ការដឹកជញ្ជូន និងការធ្វើវិភាគដី ដីល្បាប់ ទឹក ថ្ម និងគំរូរ៉ែផ្សេងៗទៀត។ (យោងមាត្រា៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៣ មាត្រា២៣ មាត្រា៣០ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៦ មាត្រា៣៧ មាត្រា៣៨ មាត្រា៣៩ និងមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ)
- **ថបនភណ្ឌ** សំដៅដល់គ្រឿងបរិក្ខារ រោងចក្រ បំពង់បង្ហូរ និងទព្វសម្ភារៈផ្សេងៗសម្រាប់ប្រតិបត្តិការប្រេង-កាត លើកលែងលេងតែកប៉ាល់ដឹកជញ្ជូនប្រេងកាត ឬកប៉ាល់ដឹកសម្ភារៈផ្គត់ផ្គង់ និងគាំទ្រផ្សេងៗ។ (យោងសន្ទានុក្រម នៃច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត)
- **បុរេសនា** គឺជាការស្វែងរុករកជំហានដំបូងនៅស្រទាប់ដីលើ ដោយប្រើប្រាស់ឧបករណ៍សាមញ្ញ ហើយមានការប៉ះពាល់បន្តិចបន្តួចដល់ផ្ទៃដី ដើម្បីកំណត់វត្តមានធនធានរ៉ែ ដែលមានតម្លៃពាណិជ្ជកម្ម និងអាចជាទិសដៅសម្រាប់ការស្នើសុំអាជ្ញាបណ្ណស្វែងរុករក និងអាជីវកម្មធនធានរ៉ែ។ (យោងមាត្រា៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ)
- **ផលិតផលរ៉ែ** សំដៅដល់ផលិតផលរ៉ែដែលបានមកពី ការធ្វើប្រតិបត្តិការធនធានរ៉ែរបស់សម្បទានិកដែលមានអាជ្ញាបណ្ណធនធានរ៉ែពីក្រសួងទទួលបន្ទុកវិស័យរ៉ែ។ (យោងមាត្រា៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ)
- **ផ្នែកដោនស្ទ្រីម** (Downstream) គឺសំដៅដល់សកម្មភាព **ការធ្វើប្រព្រឹត្តិកម្ម** (សំដៅដល់ការបញ្ចុះសីតុ-ណ្ហភាព ដើម្បីពង្រាវឧស្ម័ន ការចម្រាញ់ ការបន្សុទ្ធ ការញែក និងការរលាយបង្កើនគុណភាពនៃប្រេងកាត ផលិតផលប្រេងកាត និងគីមីប្រេងកាត លើកលែងការធ្វើប្រព្រឹត្តិកម្មនៅការដ្ឋានផលិតកម្មប្រេងកាត) **ការដឹកជញ្ជូន** (សំដៅដល់ការដឹកជញ្ជូនប្រេងកាត និងផលិតផលប្រេងកាត តាមមធ្យោបាយដឹកជញ្ជូនផ្លូវគោក ផ្លូវដែក និងផ្លូវទឹក រួមបញ្ចូលបំពង់បង្ហូរមេ និងប្រព័ន្ធបំពង់បង្ហូររង) **សន្និធិ** (សំដៅដល់ការស្តុកទុកប្រេងកាត ផលិតផលប្រេងកាត និងគីមីប្រេងកាត នៅទីតាំងលើដី ក្នុងដី និងកប់ក្នុងដី បណ្តែតទឹក និងក្នុងល្អាង ដោយមានថបនភណ្ឌសម្រាប់ការទទួល ការស្តុក និងការបញ្ចេញ) និង **ពាណិជ្ជកម្ម** (សំដៅដល់ការរកឃើញធនធានប្រេងកាតដែលពុំអាចធ្វើការអភិវឌ្ឍ និងផលិតកម្មបានភ្លាមៗ ប៉ុន្តែអាចនឹងមានលក្ខណៈពាណិជ្ជកម្មនៅពេលមានលក្ខខណ្ឌសមស្រប ប្រេងកាត និងផលិតផលប្រេងកាត លើកលែងតែការលក់

និងការនាំចេញប្រេងកាតដែលអនុវត្តស្របតាមកិច្ចព្រមព្រៀងប្រេងកាត)។ (យោងមាត្រា៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត)

- **ផ្នែកអាប់ស្ទ្រីម** (Upstream) គឺសំដៅដល់សកម្មភាព **បុរេសនា** (សំដៅដល់ការស្វែងរុកដើម្បីកំណត់សក្តានុពលភូគព្ភសាស្ត្រប្រេងកាតជំហានដំបូង ដោយមិនមានសិទ្ធិធ្វើការអភិវឌ្ឍនិងផលិតកម្ម) **ការស្វែងរុករក** (សំដៅដល់ការសិក្សាភូគព្ភសាស្ត្រ សិលាវិទ្យា រូបភូគព្ភសាស្ត្រ គីមីភូគព្ភសាស្ត្រ ឋានលេខា និងវិស្វកម្មភូគព្ភសាស្ត្រ ការខួងអណ្តូងស្វែងរុករក ការខួងអណ្តូងវាយតម្លៃ និងប្រតិបត្តិការផ្សេងទៀតក្នុងការប្រើប្រាស់ឋបនភណ្ឌនានាសម្រាប់គោលបំណងស្វែងរុករកធនធានប្រេងកាត) **ការអភិវឌ្ឍ** (សំដៅដល់ការគូសប្លង់ ការសាងសង់ ការតម្លើងឋបនភណ្ឌសម្រាប់ផលិតកម្ម ការខួងអណ្តូងផលិតកម្ម និងព្រមទាំងសកម្មភាពទាំងឡាយណាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍរបស់អ្នកចុះកិច្ចព្រមព្រៀងប្រេងកាត ស្របតាមលក្ខខណ្ឌដែលមានចែងនៅក្នុងលិខិតអនុញ្ញាតផលិតកម្ម) និង **ផលិតកម្ម** (សំដៅដល់ការផលិតប្រេងកាត រួមទាំងការខួងនិងថែទាំអណ្តូងផលិតកម្ម ការបាញ់បញ្ចូល ការបង្កើនប្រសិទ្ធិភាពទាញយក ប្រព្រឹត្តិកម្ម ការស្តុកទុកប្រេងកាតសម្រាប់ការដឹកជញ្ជូន ព្រមទាំងសកម្មភាពទាំងឡាយណាដែលពាក់ព័ន្ធនឹងផលិតកម្មប្រេងកាត នៅក្នុងការដ្ឋានប្រេងកាត)។ (យោងមាត្រា៨ នៃច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត)
- **អាជីវកម្មធនធានរ៉ែ** គឺជាប្រតិបត្តិការជីកយកធនធានរ៉ែ ដែលក្នុងនោះធនធានរ៉ែត្រូវបានយកចេញពីជម្រករ៉ែ ធ្វើប្រព្រឹត្តិកម្ម ដឹកជញ្ជូន លក់ដូរ ឬការនាំចេញក្នុងគោលបំណងពាណិជ្ជកម្ម។ ដោយឡែកការលក់ដូរ ការនាំចេញ ការនាំចូលលោហធាតុមានតម្លៃត្បូងថ្មមានតម្លៃដែលមិនទាន់ច្នៃ និងកែច្នៃរួចហើយ ត្រូវស្ថិតនៅក្រោមបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជាដែលមានជាធរមាន។ (យោងមាត្រា៣ នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ)
- **អាជ្ញាប័ណ្ណធនធានរ៉ែ** គឺជាលិខិតអនុញ្ញាតដែលផ្តល់នូវសិទ្ធិឱ្យទៅសម្បទាននិកដោយស្ថាប័នមានសមត្ថកិច្ចដើម្បីអនុវត្តសកម្មភាពប្រតិបត្តិការធនធានរ៉ែ។ អាជ្ញាបណ្ណធនធានរ៉ែត្រូវបានបែងចែកចេញជា ០៦ ប្រភេទរួមមាន **អាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ** (អាចផ្តល់ឱ្យចំពោះតែប្រជាពលរដ្ឋខ្មែរប៉ុណ្ណោះ ក្នុងគោល-បំណងអនុវត្តការងារស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែ ដោយប្រើប្រាស់ឧបករណ៍សម្ភារៈសាមញ្ញ ដែលមាននៅក្នុងមូលដ្ឋាន ហើយប្រើប្រាស់កម្លាំងផ្ទាល់ខ្លួន ឬជាលក្ខណៈគ្រួសារដែលមានចំនួនមិនលើសពី ៧ (ប្រាំពីរ) នាក់។ សិប្បកម្មធនធានរ៉ែ អាចធ្វើការស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែ បានចំពោះតែធនធានរ៉ែដែលរកឃើញក្នុងសភាពជាធនធានរ៉ែ រាយបាយនៅក្នុងដីល្បាប់ ខ្សាច់ ក្រួស សិលា ក្នុងផ្ទៃដីកំណត់មួយមានទំហំមិនលើសពី ១(មួយ) ហិកតា និងជម្រៅមិនហួសពី៥ (ប្រាំ) ម៉ែត្រ។) **អាជ្ញាបណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្ម** (អាចផ្តល់ឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានលក្ខណៈសម្បត្តិ និងសមត្ថភាពគ្រប់គ្រាន់ក្នុងបំណងអនុវត្តការងារជាក់ស្វែងរុករក ធ្វើអាជីវកម្មធនធានរ៉ែសំណង់ និងធនធានរ៉ែឧស្សាហកម្មណាមួយ

បម្រើឱ្យការសាងសង់ ឧស្សាហកម្មគីមី ឧស្សាហកម្មកែច្នៃ ហើយជីកយកពីអណ្តូងរ៉ែបើក ឬការដ្ឋានវាយថ្ម។ ធនធានរ៉ែសំណង់ និងធនធានរ៉ែឧស្សាហកម្មមានជាអាទិ៍ ខ្សាច់ ក្រួស ថ្មសំណង់ ឡាតេរីត ដីឥដ្ឋ ដីឥដ្ឋធ្វើស៊ីម៉ង់ត៍ ផូស៊ីលផ្កាថ្ម ហ្វូស្វរីត ថ្មកំបោរ ដូឡូមីត ថ្មម៉ាប កៅឡាំង ប៉ាហ្គោឌីត អំបិល ប៉ូតាស ម្នាងសិលា ធ្យូងថ្ម ខ្សាច់ទីតាន ខ្សាច់ស៊ីលីស ឬសមាសធាតុធនធានរ៉ែផ្សេងទៀតដែលប្រើប្រាស់ក្នុងគោលដៅដូចគ្នា។) **អាជ្ញាបណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ** (អាចផ្តល់ឱ្យដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានលក្ខណៈសម្បត្តិ និងសមត្ថភាពគ្រប់គ្រាន់ ក្នុងបំណងស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែ ត្បូងថ្មមានតម្លៃ ពាក់កណ្តាលមានតម្លៃ និងថ្មសំអាង។ ត្បូងថ្មមានតម្លៃមានជាអាទិ៍ ពេជ្រ ត្បូងទទឹម កណ្តៀង មរកត និងរ៉ែត្បូងថ្មទាំងឡាយដែលមានគុណភាពប្រហាក់ប្រហែល។ ត្បូងថ្មពាក់កណ្តាលមានតម្លៃមានជាអាទិ៍ សៀកកុន អាមេទីស តូប៉ាស និងរ៉ែត្បូងថ្មទាំងឡាយដែលមានគុណភាពប្រហាក់ប្រហែល។ ថ្មសំអាង គឺជាថ្មដែលមានកំរិតថ្លាឆ្លុះទាប ឬមិនថ្លាឆ្លុះ ត្រូវបានគេយកទៅប្រើប្រាស់ជាគ្រឿងលំអផ្សេងៗ មានជាអាទិ៍ កាល់សេដូន អាសូរីត អូប៉ាល់ធម្មតា អាហ្គាក ហ្សេតម៉ាឡាស៊ីក ឈើថ្ម ថ្មថ្លើមអណ្តើក និងថ្មទាំងឡាយដែលមានគុណភាពប្រហាក់ប្រហែល។) **អាជ្ញាបណ្ណកែច្នៃធនធានរ៉ែ** (អាចផ្តល់ឱ្យចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងគោលបំណងកែច្នៃត្បូងថ្មមានតម្លៃ ពាក់កណ្តាលមានតម្លៃ ឬថ្មសំអាង) **អាជ្ញាបណ្ណស្វែងរុករក** (អាចផ្តល់ឱ្យចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីធ្វើការស្វែងរុករក និងសិក្សាអំពីសក្តានុពលធនធានរ៉ែ) និង **អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ** (ត្រូវបានផ្តល់ឱ្យចំពោះតែសម្បទានិកដែលមានអាជ្ញាបណ្ណស្វែងរុករកតែប៉ុណ្ណោះ ក្នុងគោលបំណងស្វែងរុករក និងជីកយករ៉ែណាដែលមានជម្រករ៉ែមានប្រសិទ្ធិភាពសេដ្ឋកិច្ច ហើយឋិតនៅតែក្នុងរង្វង់ព្រំដែននៃអាជ្ញាបណ្ណស្វែងរុករក។ សម្បទានិកស្វែងរុករក ត្រូវតែដាក់ឱ្យពិនិត្យនូវការវិភាគបច្ចេកទេសហិរញ្ញវត្ថុ បរិស្ថាន សេដ្ឋកិច្ច និងសង្គម ក្នុងគោលបំណងកំណត់លទ្ធភាពសេដ្ឋកិច្ចសង្គម នៃទម្រង់ប្រតិបត្តិការជីកយករ៉ែ ដើម្បីសុំការយល់ព្រមពីរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែ។ បែបបទនិងមាតិកានៃរបាយការណ៍ ការសិក្សាសមិទ្ធិលទ្ធភាពចុងក្រោយ និងឯកសារយោងព្រមទាំងល័ក្ខខណ្ឌទាំងឡាយ នៃការចេញអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែនឹងមានចែងក្នុងអនុក្រឹត្យ។ (មាត្រា១១ នៃច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ)

# បញ្ជីឧបសម្ព័ន្ធ

| លំដាប់ឧបសម្ព័ន្ធ | បរិយាយ |
|---|---|
| ឧបសម្ព័ន្ធទី១ | ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| ឧបសម្ព័ន្ធទី២ | ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងរ៉ែ និងថាមពល |
| ឧបសម្ព័ន្ធទី៣ | ព្រះរាជក្រឹត្យក្រឹត្យលេខ នស/រកត/១២១៣/១៤០១ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្ទេរ និងធ្វើសមាហរណកម្មអាជ្ញាធរប្រេងកាតជាតិកម្ពុជាទៅក្រោមក្រសួងរ៉ែ និងថាមពល |
| ឧបសម្ព័ន្ធទី៤ | អនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល |
| ឧបសម្ព័ន្ធទី៥ | យុទ្ធសាស្ត្រចតុកោណ ២០១៩-២០២៣ |
| ឧបសម្ព័ន្ធទី៦ | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ |
| ឧបសម្ព័ន្ធទី៧ | លិខិតលេខ ៥២៦ ស.ភ.ន.វ.ស ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ ស្តីពីសំណើសុំអនុញ្ញាតឱ្យនិស្សិតចំនួន ០២ រូបចុះសិក្សាស្រាវជ្រាវឯកសារនៅក្រសួងរ៉ែ និងថាមពល |
| ឧបសម្ព័ន្ធទី៨ | លិខិតបង្គាប់ការលេខ ០០២៩ រថ.បល.លបក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣ ស្តីពីការអនុញ្ញាតឱ្យចុះសិក្សាស្រាវជ្រាវឯកសារ និងស្វែងយល់ពីការងារដែលពាក់ព័ន្ធនឹងប្រធានបទ "ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល" |
| ឧបសម្ព័ន្ធទី៩ | រូបភាពចុះសិក្សាស្រាវជ្រាវឯកសារ និងស្វែងយល់ពីការងារដែលពាក់ព័ន្ធនឹងប្រធានបទ "ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល" នៅនាយកដ្ឋាននីតិកម្ម នៃអគ្គនាយកដ្ឋានកិច្ចការទូទៅ នៃក្រសួងរ៉ែ និងថាមពល |

I. ឧបសម្ព័ន្ធទី១៖ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

# ព្រះរាជក្រម

នស/រកដ/០១៩៦/០៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

******

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រមលេខ ០២ នស ៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើក ទី ៥ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

## ស្តីពី

# ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល

មាត្រា ១.-

ត្រូវបានបង្កើតក្រសួងឧស្សាហកម្ម រ៉ែនិងថាមពលចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

មាត្រា ២.-

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលមានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រង លើ វិស័យឧស្សាហកម្ម សិប្បកម្ម រ៉ែនិងថាមពលនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣.-

ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពលត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូបដែល អាចអមដោយរដ្ឋលេខាធិការនិង ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

មាត្រា ៤.-

ការរៀបចំរចនាសម្ព័ន្ធនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៥.-

បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៦.-

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២**

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

II. ឧបសម្ព័ន្ធទី២៖ ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល

## ព្រះរាជក្រម

នស/រកម/១២១៣/០១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

### ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ១៤៦/០២១/២០១៣ កបធ.ច ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

# ច្បាប់

# ស្តីពី

# ការបង្កើតក្រសួងរ៉ែ និងថាមពល

**មាត្រា ១.–**

ត្រូវបានបង្កើតក្រសួងរ៉ែ និងថាមពល ចំណុះរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.–**

ក្រសួងរ៉ែ និងថាមពល មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងវិស័យរ៉ែនិងថាមពល ដោយរួមទាំងប្រេងកាត ឧស្ម័ន និងអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.–**

ក្រសួងរ៉ែ និងថាមពល ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអមដោយរដ្ឋលេខាធិការ និង/ឬ អនុរដ្ឋលេខាធិការ តាមការចាំបាច់ ។

**មាត្រា ៤.–**

ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥.–**

អាជ្ញាធរអគ្គិសនីកម្ពុជា ដែលត្រូវបានកំណត់ដោយច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស.រកម.០២០១.០៣ ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០០១ ត្រូវស្ថិតនៅក្រោមការដឹកនាំនិងគ្រប់គ្រងផ្នែកគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការរបស់ក្រសួងរ៉ែ និងថាមពល និងត្រូវមានគណនេយ្យភាពហិរញ្ញវត្ថុ ចំពោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ។

**មាត្រា ៦.–**

វិស័យរ៉ែ និងថាមពល ដែលជាសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ពីមុនត្រូវស្ថិតនៅក្រោមក្រសួងរ៉ែ និងថាមពល ។

ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម រ៉ែ និងថាមពល ដែលនៅជាធរមានត្រូវមានអានុភាពអនុវត្តបន្ត រហូតដល់មានការកំណត់ជាថ្មី ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

រដ្ឋមន្ត្រីនិងរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ត្រូវបន្តដឹកនាំ និងគ្រប់គ្រងក្រសួងរ៉ែ និងថាមពលរហូតដល់មានការតែងតាំងរដ្ឋមន្ត្រី និងរដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល ។

**មាត្រា ៧.–**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨.–**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៣

[illegible] **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ:១៣១៧ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

III. ឧបសម្ព័ន្ធទី៣៖ ព្រះរាជក្រឹត្យ លេខ នស/រកត/១២១៣/១៤០១ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្ទេរ និងធ្វើសមាហរណកម្មអាជ្ញាធរប្រេងកាតជាតិកម្ពុជាទៅក្រោមក្រសួងរ៉ែ និងថាមពល

# ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១៤០១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែ និងថាមពល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានផ្ទេរ និងធ្វើសមាហរណកម្មអាជ្ញាធរប្រេងកាតជាតិកម្ពុជាទៅក្រោមក្រសួងរ៉ែ និងថាមពល។

មាត្រា២ : កិច្ចព្រមព្រៀង និងកិច្ចសន្យាទាំងឡាយដែលចុះហត្ថលេខាដោយអាជ្ញាធរប្រេងកាតជាតិកម្ពុជា ត្រូវបន្តសុពលភាព នៅក្រោមសមត្ថកិច្ចក្រសួងរ៉ែ និងថាមពល ដោយអនុលោមតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។

មាត្រា៣ : ព្រះរាជាក្រឹត្យលេខ ជស/រតក/០១៩៨/០២០ ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតអាជ្ញាធរ ប្រេងកាតជាតិកម្ពុជា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

ROYAUME DU CAMBODGE • LE MINISTÈRE DU PALAIS ROYAL

**មាត្រា៤ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស. ១២១៣.១៤១៩

*ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១៣*

លេខៈ ១៣៥៣ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ .ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

## IV. ឧបសម្ព័ន្ធទី៤៖ អនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣៧ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤០១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការផ្ទេរនិងធ្វើសមាហរណកម្មអាជ្ញាធរប្រេងកាតជាតិកម្ពុជាទៅក្រោមក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមេសា ឆ្នាំ២០១៧ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់វិធីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចខាងក្រោម៖

- រៀបចំបេសកកម្មនិងរចនាសម្ព័ន្ធរបស់ក្រសួងរ៉ែនិងថាមពល
- រៀបចំមុខងារនិងភារកិច្ចរបស់អង្គភាពនានារបស់ក្រសួងរ៉ែនិងថាមពល
- ធានាគុណភាពនិងប្រសិទ្ធភាពក្នុងការដឹកនាំ គ្រប់គ្រង អភិវឌ្ឍ និងលទ្ធផលបំពេញការងារលើវិស័យរ៉ែនិងថាមពលរួមទាំងវិស័យប្រេងកាត(ប្រេងនិងឧស្ម័ន) បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រប់អង្គភាពចំណុះក្រសួងរ៉ែនិងថាមពល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយគ្របដណ្តប់លើវិស័យរ៉ែនិងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី។

## ជំពូកទី២

## បេសកកម្មនិងរចនាសម្ព័ន្ធ

**មាត្រា៤.-**

ក្រសួងរ៉ែនិងថាមពលបំពេញមុខងារជាសេនាធិការឱ្យរាជរដ្ឋាភិបាល ដែលមានបេសកកម្មដឹកនាំ គ្រប់គ្រងនិងអភិវឌ្ឍវិស័យរ៉ែនិងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី។

បេសកកម្មនេះត្រូវធ្វើឡើងតាមរយៈការរៀបចំនិងការអនុវត្តឱ្យបានត្រឹមត្រូវនូវគោលនយោបាយ ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិទាំងឡាយទាក់ទងនឹងការដឹកនាំ ការគ្រប់គ្រង និងការអភិវឌ្ឍ វិស័យរ៉ែនិងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី។

**មាត្រា៥.-**

ក្រសួងរ៉ែនិងថាមពលមានមុខងារនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងអនុវត្តគោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្ត្រ លើវិស័យរ៉ែនិងថាមពល រួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី
- រៀបចំតាក់តែងច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងវិស័យរ៉ែនិងថាមពល រួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី

- អនុវត្តផែនការយុទ្ធសាស្ត្រនិងសហប្រតិបត្តិការជាមួយស្ថាប័នជាតិនិងអន្តរជាតិ សំដៅគ្រប់គ្រងនិងអភិវឌ្ឍវិស័យរ៉ែនិងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី
- គ្រប់គ្រង ការងារសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រ ការផ្សព្វផ្សាយទិន្នន័យភូគព្ភសាស្ត្រ និងការសិក្សាស្រាវជ្រាវរុករកធនធានរ៉ែ
- គ្រប់គ្រង ការអភិវឌ្ឍ ការធ្វើអាជីវកម្ម ការប្រើប្រាស់ធនធានរ៉ែ ការប្រើប្រាស់អណ្តូងរ៉ែ ការបន្សុទ្ធ និងការចម្រាញ់រ៉ែ ព្រមទាំងរាល់សកម្មភាពទាំងឡាយដែលទាក់ទងទៅនឹងប្រតិបត្តិការធនធានរ៉ែ
- គ្រប់គ្រង ការសិក្សាស្រាវជ្រាវអំពីប្រភពការផលិត ការចែកចាយ និងការប្រើប្រាស់ថាមពល ព្រមទាំងការការពារសុវត្ថិភាពក្នុងវិស័យថាមពល
- គ្រប់គ្រង ការធ្វើផែនការនិងការអភិវឌ្ឍអគ្គិសនី ស្ថានីយផលិតអគ្គិសនី ប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនី ប្រព័ន្ធចែកចាយអគ្គិសនី និងវាយតម្លៃសក្តានុពលវារីអគ្គិសនីដើម្បីរៀបចំអភិវឌ្ឍទំនប់វារីណាដែលមានការផលិតថាមពលអគ្គិសនីជាគោលបំណងចម្បង
- គ្រប់គ្រងការងារប្រេងកាតផ្នែកអាប់ស្ទ្រីម(Upstream) និងផ្នែកដោនស្ទ្រីម(Downstream)ដែលរួមមានបុរេសនា ការស្វែងរុករក ការអភិវឌ្ឍនិងផលិតកម្មប្រេងកាត ការធ្វើប្រព្រឹត្តិកម្មប្រេងកាតនិងគីមីប្រេងកាត ការដឹកជញ្ជូននិងចែកចាយ សន្និធិ ការនាំចេញ-នាំចូល និងការធ្វើពាណិជ្ជកម្មប្រេង-កាតនិងផលិតផលប្រេងកាត
- លើកកម្ពស់ការការពារសុវត្ថិភាព សុខភាព និងលក្ខខណ្ឌការងារក្នុងវិស័យរ៉ែនិងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី
- លើកកម្ពស់ ការការពារនិងអភិរក្សគុណភាពបរិស្ថាន និងសុខុមាលភាពសង្គម ក្នុងវិស័យរ៉ែនិងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី និង
- គៀរគរចំណូលមិនមែនសារពើពន្ធពាក់ព័ន្ធនឹងវិស័យរ៉ែនិងថាមពលរួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី។

**មាត្រា៦ ..**

ក្រសួងរ៉ែនិងថាមពល មានរចនាសម្ព័ន្ធដូចខាងក្រោម៖

ក- អង្គភាពថ្នាក់ជាតិ

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានកិច្ចការទូទៅ
- អគ្គនាយកដ្ឋានធនធានរ៉ែ
- អគ្គនាយកដ្ឋានថាមពល
- អគ្គនាយកដ្ឋានប្រេងកាត
- អគ្គាធិការដ្ឋាន និង
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង។

ខ- អង្គភាពថ្នាក់ក្រោមជាតិ

ថ្នាក់ក្រោមជាតិ មានមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត។

**មាត្រា៧ -**

អគ្គនាយកដ្ឋាននីមួយៗដឹកនាំដោយអគ្គនាយកមួយរូបនិងអមដោយអគ្គនាយករងមួយចំនួនអនុលោមតាមបទប្បញ្ញត្តិដែលមានជាធរមាន។

អគ្គាធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូប មានឋានៈស្មើអគ្គនាយក និងអមដោយអគ្គាធិការរងមួយចំនួនអនុលោមតាមបទប្បញ្ញត្តិដែលមានជាធរមានឋានៈស្មើអគ្គនាយករង និងអធិការឋានៈស្មើប្រធាននាយកដ្ឋាន។

នាយកដ្ឋាននីមួយៗដឹកនាំដោយប្រធានមួយរូបនិងអមដោយអនុប្រធានមួយចំនួនអនុលោមតាមបទប្បញ្ញត្តិដែលមានជាធរមាន។

មន្ទីររ៉ែនិងថាមពលរាជធានី ខេត្តនៃក្រសួងរ៉ែនិងថាមពល ដឹកនាំដោយប្រធានមួយរូបនិងអមដោយអនុប្រធានមួយចំនួនអនុលោមតាមបទប្បញ្ញត្តិដែលមានជាធរមាន។

អង្គការលេខរបស់ក្រសួងរ៉ែនិងថាមពលមានភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៨ -**

ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពនានាក្រោមឱវាទរបស់អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពថ្នាក់ក្រោមជាតិនៃក្រសួងរ៉ែនិងថាមពលត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

## ជំពូកទី៣
## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា៩ -**

ខុទ្ទកាល័យរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន និងអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន។

## ជំពូកទី៤
## អគ្គនាយកដ្ឋានកិច្ចការទូទៅ

**មាត្រា១០ -**

អគ្គនាយកដ្ឋានកិច្ចការទូទៅ បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែនិងថាមពល ដោយមានភារកិច្ចដូចតទៅ៖

- គ្រប់គ្រងនិងសម្របសម្រួលរាល់សកម្មភាពរដ្ឋបាលរបស់ក្រសួង នៅថ្នាក់ជាតិ និងរវាងថ្នាក់ជាតិ និងអង្គភាពថ្នាក់ក្រោមជាតិ និងអង្គភាពដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងរ៉ែនិងថាមពល
- រៀបចំនិងគ្រប់គ្រងបណ្ដាញព័ត៌មានវិទ្យានិងគេហទំព័ររបស់ក្រសួងរ៉ែនិងថាមពល
- រៀបចំនិងគ្រប់គ្រងរាល់ការងារទាក់ទងថវិកា គណនេយ្យ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ របស់ក្រសួងរ៉ែនិងថាមពល
- គ្រប់គ្រងការកត់ត្រាចំណូលមិនមែនសារពើពន្ធរបស់ក្រសួងរ៉ែនិងថាមពល
- រៀបចំនិងគ្រប់គ្រងរាល់ការងារទាក់ទងនឹងមន្ត្រីរាជការ
- សហការពិនិត្យនិងផ្ដល់យោបល់ និងការពារផលប្រយោជន៍ក្រសួងរ៉ែនិងថាមពលតាមផ្លូវច្បាប់
- សហការសម្របសម្រួលនិងគ្រប់គ្រងការងារទាក់ទងនឹងកិច្ចសហប្រតិបត្តិការនិងកិច្ចការអាស៊ានរបស់ក្រសួងរ៉ែនិងថាមពល
- រៀបចំផែនការនិងបូកសរុបលទ្ធផលការងាររបស់ក្រសួងរ៉ែនិងថាមពល និង
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់ថ្នាក់ដឹកនាំក្រសួងរ៉ែនិងថាមពល។

**មាត្រា១១.-**

អគ្គនាយកដ្ឋានកិច្ចការទូទៅមាននាយកដ្ឋានក្រោមឱវាទចំនួន៦(ប្រាំមួយ)ដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាលនិងព័ត៌មានវិទ្យា
- នាយកដ្ឋានបុគ្គលិក
- នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ
- នាយកដ្ឋានផែនការ
- នាយកដ្ឋាននីតិកម្ម និង
- នាយកដ្ឋានសហប្រតិបត្តិការ និងកិច្ចការអាស៊ាន។

អគ្គនាយកដ្ឋានកិច្ចការទូទៅទទួលបន្ទុកសម្របសម្រួលការងាររបស់មន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ដែលជាតំណាងក្រសួងរ៉ែនិងថាមពលនៅថ្នាក់ក្រោមជាតិ។

**មាត្រា១២.-**

នាយកដ្ឋានរដ្ឋបាលនិងព័ត៌មានវិទ្យា បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅលើការងាររដ្ឋបាលនិងព័ត៌មានវិទ្យា។

នាយកដ្ឋានបុគ្គលិក បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅលើការងារបុគ្គលិក។

នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅលើការងារគណនេយ្យនិងហិរញ្ញវត្ថុ។

នាយកដ្ឋានផែនការ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅលើការងារផែនការ គម្រោងថវិកា និងបូកសរុប។

នាយកដ្ឋាននីតិកម្ម បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅលើការងារនីតិកម្ម។

នាយកដ្ឋានសហប្រតិបត្តិការនិងកិច្ចការអាស៊ាន បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានកិច្ចការទូទៅ លើការងារសហប្រតិបត្តិការនិងកិច្ចការអាស៊ាន។

មន្ទីររ៉ែនិងថាមពលបំពេញមុខងារជាតំណាងរបស់ក្រសួងរ៉ែនិងថាមពល លើការងារសម្របសម្រួលអង្គភាពថ្នាក់ក្រោមជាតិរបស់ក្រសួងរ៉ែនិងថាមពល ព្រមទាំងអនុវត្តភារកិច្ចគ្រប់គ្រងវិស័យរ៉ែនិងថាមពល រួមទាំងវិស័យប្រេងកាត បរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនីនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល។

## ជំពូកទី៥
## អគ្គនាយកដ្ឋានធនធានរ៉ែ

**មាត្រា១៣.-**

អគ្គនាយកដ្ឋានធនធានរ៉ែ បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែនិងថាមពល លើបេសកកម្មគ្រប់គ្រងការអភិវឌ្ឍនិងការធ្វើអាជីវកម្មធនធានរ៉ែនិងជំរុញការប្រើប្រាស់ ធនធានរ៉ែ ព័ត៌មានភូគព្ភសាស្ត្រនិងធនធានរ៉ែ ដើម្បីចូលរួមចំណែកក្នុងកិច្ចអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ អគ្គនាយកដ្ឋានធនធានរ៉ែមានភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងចងក្រងគោលនយោបាយ ច្បាប់ បទប្បញ្ញត្តិ និងផែនការយុទ្ធសាស្ត្រនានាដើម្បីជំរុញអភិវឌ្ឍវិស័យរ៉ែ
- ជំរុញ ការសិក្សាស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាផ្នែកភូគព្ភសាស្ត្រ ការសិក្សាស្វែងរុករកនិងការវាយតម្លៃទំហំសក្តានុពលធនធានរ៉ែ
- ជំរុញការកសាងសមត្ថភាពធនធានមនុស្សនិងការផ្ទេរបច្ចេកវិទ្យាក្នុងវិស័យរ៉ែ
- ជំរុញ ការអភិវឌ្ឍ ការធ្វើអាជីវកម្ម និងការប្រើប្រាស់ធនធានរ៉ែ បម្រើឱ្យវិស័យសេដ្ឋកិច្ចនិងសង្គម
- ជំរុញនិងគ្រប់គ្រងការវិនិយោគឯកជនក្នុងវិស័យធនធានរ៉ែ ចាប់ពីការសិក្សាស្វែងរុករករហូតដល់ការធ្វើអាជីវកម្ម ការបិទការដ្ឋាន និងស្តារបរិស្ថានឡើងវិញ
- លើកកម្ពស់ការការពារគុណភាពបរិស្ថាននិងសុខុមាលភាពសង្គមនៅក្នុងសកម្មភាពអភិវឌ្ឍវិស័យរ៉ែ
- ធានាសុចរិតភាព ប្រសិទ្ធភាព និងគណនេយ្យភាព ក្នុងការធ្វើអាជីវកម្មនិងប្រើប្រាស់ធនធានរ៉ែ
- គៀរគរគ្រប់គ្រងការប្រមូលចំណូលមិនមែនសារពើពន្ធពាក់ព័ន្ធនឹងវិស័យរ៉ែ និង
- គ្រប់គ្រងការនាំចេញ-នាំចូលធនធានរ៉ែនិងផលិតផលរ៉ែ។

**មាត្រា១៤.-**

អគ្គនាយកដ្ឋានធនធានរ៉ែ មានអង្គភាពក្រោមឱវាទចំនួន៦(ប្រាំមួយ)ដូចខាងក្រោម៖

- នាយកដ្ឋានភូគព្ភសាស្រ្ត-រ៉ែ
- នាយកដ្ឋានផែនការសេដ្ឋកិច្ចធនធានរ៉ែ
- នាយកដ្ឋានឧស្សាហកម្មអាជីវកម្មធនធានរ៉ែ
- នាយកដ្ឋានអាជីវកម្មរ៉ែខ្សាច់សំណង់
- នាយកដ្ឋានអាជីវកម្មរ៉ែថ្មសំណង់ និង
- នាយកដ្ឋានត្រួតពិនិត្យប្រតិបត្តិការធនធានរ៉ែ។

**មាត្រា១៥ .-**

នាយកដ្ឋានភូគព្ភសាស្រ្ត-រ៉ែ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានធនធានរ៉ែ លើការងារភូគព្ភសាស្រ្ត សិក្សាស្រាវជ្រាវនិងអភិវឌ្ឍបច្ចេកវិទ្យាផ្នែកភូគព្ភសាស្រ្ត និងគ្រប់គ្រងដំណើរការមន្ទីរពិសោធន៍ភូគព្ភសាស្រ្ត-រ៉ែ។

នាយកដ្ឋានផែនការសេដ្ឋកិច្ចធនធានរ៉ែ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានធនធានរ៉ែលើការងាររៀបចំផែនការយុទ្ធសាស្រ្ត ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែ ការជំរុញលើកកម្ពស់ផលសេដ្ឋកិច្ចសង្គម និងការងារសហប្រតិបត្តិការក្នុងវិស័យរ៉ែ។

នាយកដ្ឋានឧស្សាហកម្មអាជីវកម្មធនធានរ៉ែ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានធនធានរ៉ែលើការងារគ្រប់គ្រងប្រតិបត្តិការស្វែងរុករកនិងអាជីវកម្មធនធានរ៉ែ។

នាយកដ្ឋានអាជីវកម្មរ៉ែខ្សាច់សំណង់ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានធនធានរ៉ែលើការងារគ្រប់គ្រងអាជីវកម្មរ៉ែខ្សាច់ ក្រួស និងល្បាប់ខ្សាច់ ភក់ ពីប្រភពសមុទ្រ ទន្លេ ស្ទឹង ព្រែក បឹង និងអូរសំដៅបម្រើឱ្យវិស័យសំណង់។

នាយកដ្ឋានអាជីវកម្មរ៉ែថ្មសំណង់ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានធនធានរ៉ែលើការងារគ្រប់គ្រងអាជីវកម្មរ៉ែថ្មសំណង់ ថ្មអារ ឡាតេរីត ខ្សាច់បក និងអាចម៍ដី។

នាយកដ្ឋានត្រួតពិនិត្យប្រតិបត្តិការធនធានរ៉ែ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានធនធានរ៉ែលើការងារត្រួតពិនិត្យនិងជំរុញអនុលោមភាពស្របតាមវិធានបច្ចេកទេស សុវត្ថិភាព សុខភាព និងលក្ខខណ្ឌការងារ ព្រមទាំងការការពារបរិស្ថាននិងសុខុមាលភាពសង្គមនៅក្នុងប្រតិបត្តិការធនធានរ៉ែ។

## ជំពូកទី៦
## អគ្គនាយកដ្ឋានថាមពល

**មាត្រា១៦ .-**

អគ្គនាយកដ្ឋានថាមពល បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែនិងថាមពល លើបេសកកម្មគ្រប់គ្រងវិស័យថាមពល ផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី ដោយមានភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងកំណត់គោលនយោបាយ យុទ្ធសាស្រ្ត ច្បាប់ បទប្បញ្ញត្តិ និងស្តង់ដារ ក្នុងវិស័យថាមពលផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី

- ជំរុញការកសាងសមត្ថភាពធនធានមនុស្សនិងការផ្ទេរបច្ចេកវិទ្យាក្នុងវិស័យថាមពល ផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី
- ធ្វើកិច្ចសហប្រតិបត្តិការក្នុងវិស័យថាមពល ផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម ក្នុងតំបន់និងអន្តរជាតិ
- ជំរុញការធ្វើពាណិជ្ជកម្មក្នុងវិស័យថាមពល
- គ្រប់គ្រងការអភិវឌ្ឍវិស័យថាមពល
- គ្រប់គ្រងវិស័យថាមពលវារីអគ្គិសនី
- គ្រប់គ្រងកិច្ចការផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម រួមមានកិច្ចការសុវត្ថិភាព ការការពារសុវត្ថិភាព និងសហការលើការងារសន្តិសុខបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្មជាមួយស្ថាប័នពាក់ព័ន្ធ
- គ្រប់គ្រងវិស័យថាមពលកំដៅនិងចំហេះ
- គ្រប់គ្រងវិស័យថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត និង
- គ្រប់គ្រងបច្ចេកទេសនិងគោលនយោបាយអាជីវកម្មក្នុងវិស័យថាមពល។

**មាត្រា១៧ -**

អគ្គនាយកដ្ឋានថាមពល មាននាយកដ្ឋានក្រោមឱវាទចំនួន៦(ប្រាំមួយ)ដូចខាងក្រោម៖

- នាយកដ្ឋានអភិវឌ្ឍថាមពល
- នាយកដ្ឋានវារីអគ្គិសនី
- នាយកដ្ឋានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាបរមាណូ
- នាយកដ្ឋានថាមពលកំដៅនិងចំហេះ
- នាយកដ្ឋានថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត និង
- នាយកដ្ឋានបច្ចេកទេសនិងគោលនយោបាយអាជីវកម្មថាមពល។

**មាត្រា១៨ -**

នាយកដ្ឋានអភិវឌ្ឍថាមពល បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថាមពល លើការងារតាមដានស្ថានភាពនៃការផ្គត់ផ្គង់ថាមពល ប្រមូលព័ត៌មាននិងទិន្នន័យក្នុងវិស័យថាមពល សិក្សានិងរៀបចំផែនការអភិវឌ្ឍវិស័យថាមពល សិក្សានិងរៀបចំផែនការវិនិយោគ រៀបចំការងារពិនិត្យ ចរចា និងឯកសារសម្រេចអនុញ្ញាតឱ្យវិនិយោគក្នុងវិស័យថាមពល។

នាយកដ្ឋានវារីអគ្គិសនី បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថាមពល លើការងារស្រាវជ្រាវបច្ចេកវិទ្យា ធ្វើសហប្រតិបត្តិការ រៀបចំគោលនយោបាយ ច្បាប់ ស្តង់ដារ ផែនការ ការបណ្តុះបណ្តាល និងតាមដាន ត្រួតពិនិត្យ ការអនុវត្តគម្រោងវិនិយោគក្នុងវិស័យថាមពលវារីអគ្គិសនី។

នាយកដ្ឋានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាបរមាណូ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថាមពល លើការងារស្រាវជ្រាវវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ធ្វើសហប្រតិបត្តិការ រៀបចំគោលនយោបាយ ច្បាប់ ស្តង់ដារ ផែនការ ការបណ្តុះបណ្តាល និងតាមដាន ត្រួតពិនិត្យ ការអនុវត្តគម្រោងវិនិយោគក្នុងផ្នែកថាមពលបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម។

នាយកដ្ឋានថាមពលកំដៅនិងចំហេះ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថាមពល លើការងារស្រាវជ្រាវបច្ចេកវិទ្យា ធ្វើសហប្រតិបត្តិការ រៀបចំគោលនយោបាយ ច្បាប់ ស្តង់ដារ ផែនការ ការបណ្តុះ-បណ្តាល និងតាមដាន ត្រួតពិនិត្យ ការអនុវត្តគម្រោងវិនិយោគក្នុងវិស័យថាមពលកំដៅនិងចំហេះ។

នាយកដ្ឋានថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថាមពល លើការងារស្រាវជ្រាវបច្ចេកវិទ្យា ធ្វើសហប្រតិបត្តិការ រៀបចំគោលនយោបាយ ច្បាប់ ស្តង់ដារ ផែនការ ការបណ្តុះបណ្តាល និងតាមដាន ត្រួតពិនិត្យ ការអនុវត្តគម្រោងវិនិយោគក្នុងវិស័យថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត។

នាយកដ្ឋានបច្ចេកទេសនិងគោលនយោបាយអាជីវកម្មថាមពល បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថាមពលលើការងាររៀបចំនិងត្រួតពិនិត្យការអនុវត្តស្តង់ដារបច្ចេកទេស និងស្តង់ដារសុវត្ថិភាព រៀបចំនិងត្រួតពិនិត្យការអនុវត្តគោលនយោបាយនិងយន្តការសន្សំសំចៃថាមពល និងប្រសិទ្ធភាពថាមពល រៀបចំនិងត្រួតពិនិត្យការអនុវត្តស្តង់ដារបច្ចេកទេសអគ្គិសនីសម្រាប់រៀបចំបណ្តាញនិងសុវត្ថិភាពអគ្គិសនីក្នុងអគារនិងលំនៅដ្ឋាន រៀបចំនិងត្រួតពិនិត្យការអនុវត្តគោលនយោបាយនិងយន្តការធ្វើអាជីវកម្ម និងការផ្តល់សេវាក្នុងវិស័យថាមពល ព្រមទាំងត្រួតពិនិត្យការអនុវត្តគម្រោងវិនិយោគប្រព័ន្ធបណ្តាញផ្គត់ផ្គង់និងការពង្រឹងស្ថិរភាពនៃការផ្គត់ផ្គង់។

## ជំពូកទី៧
## អគ្គនាយកដ្ឋានប្រេងកាត

**មាត្រា១៩ ៖**

អគ្គនាយកដ្ឋានប្រេងកាត បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែនិងថាមពល ដោយមានភារកិច្ចអនុវត្តគោលនយោបាយបម្រើឱ្យវិស័យប្រេងកាត និងគ្រប់គ្រងការងារប្រេងកាតផ្នែកអាប់ស្ទ្រីមនិងផ្នែកដោនស្ទ្រីម ដែលរួមមានបុរេសនា ការស្វែងរុករក ការអភិវឌ្ឍនិងផលិតកម្មប្រេងកាត ការធ្វើប្រព្រឹត្តិកម្មប្រេងកាតនិងគីមីប្រេងកាត ការដឹកជញ្ជូននិងចែកចាយ សន្និធិ ការនាំចេញ-នាំចូល និងការធ្វើពាណិជ្ជកម្មប្រេងកាតនិងផលិតផលប្រេងកាត។

**មាត្រា២០ ៖**

អគ្គនាយកដ្ឋានប្រេងកាត មាននាយកដ្ឋានក្រោមឱវាទចំនួន៥(ប្រាំ)ដូចតទៅ៖

- នាយកដ្ឋានសិក្សាស្រាវជ្រាវប្រេងកាត
- នាយកដ្ឋានជំរុញនិងអភិវឌ្ឍធនធានប្រេងកាត

- នាយកដ្ឋានគ្រប់គ្រងគម្រោងសម្បទានប្រេងកាត
- នាយកដ្ឋានកិច្ចការប្រេងកាតអន្តរជាតិ និង
- នាយកដ្ឋានបច្ចេកវិទ្យាប្រេងកាត គាំទ្រកិច្ចប្រតិបត្តិការ និងសន្តិសុខថាមពល។

មាត្រា២១ _

នាយកដ្ឋានសិក្សាស្រាវជ្រាវប្រេងកាត បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រេងកាត លើការងារបច្ចេកទេសផ្នែកអាប់ស្ទ្រីម។

នាយកដ្ឋានជំរុញនិងអភិវឌ្ឍធនធានប្រេងកាត បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រេងកាត លើការងារទាក់ទាញអ្នកវិនិយោគ និងរៀបចំផ្តល់កិច្ចព្រមព្រៀងប្រេងកាតតាមវិធីសាស្ត្រដេញថ្លៃឬចរចាផ្ទាល់។

នាយកដ្ឋានគ្រប់គ្រងគម្រោងសម្បទានប្រេងកាត បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រេងកាតលើការងារតាមដានត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀងប្រេងកាតរួមទាំងការងារគ្រប់គ្រងការអភិវឌ្ឍ និងផលិតកម្មប្រេងនិងឧស្ម័ន។

នាយកដ្ឋានកិច្ចការប្រេងកាតអន្តរជាតិ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រេងកាត លើការងារស្រាវជ្រាវច្បាប់ គោលនយោបាយ យុទ្ធសាស្ត្រ និងការងារសហប្រតិបត្តិការក្នុងវិស័យប្រេងកាតផ្នែកអាប់ស្ទ្រីម។

នាយកដ្ឋានបច្ចេកវិទ្យាប្រេងកាត គាំទ្រកិច្ចប្រតិបត្តិការ និងសន្តិសុខថាមពល បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានប្រេងកាត លើការងារផ្នែកដោនស្ទ្រីម ដែលរួមមាន ការធ្វើប្រព្រឹត្តិកម្ម ការដឹកជញ្ជូន សន្និធិ ការនាំចូលប្រេងកាតនិងផលិតផលប្រេងកាត ការនាំចេញផលិតផលប្រេងកាត បច្ចេកទេសសុវត្ថិភាព និងសន្តិសុខថាមពល។

## ជំពូកទី៨
## អគ្គាធិការដ្ឋាន

**មាត្រា២២ _**

អគ្គាធិការដ្ឋាន បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែនិងថាមពលលើការងារអគ្គាធិការកិច្ច ដោយមានភារកិច្ចដូចតទៅ៖

- ធ្វើអធិការកិច្ចជាប្រចាំទៅលើការគ្រប់គ្រងអង្គភាពក្រោមឱវាទក្រសួងរ៉ែនិងថាមពល និង
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី អំពីការប្រព្រឹត្តទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចហើយ និងអំពីបញ្ហាបាយកែលម្អការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ។

## ជំពូកទី៩
## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា២៣.-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង បំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែនិងថាមពលលើការងារសវនកម្មផ្ទៃក្នុងដោយមានភារកិច្ចដូចខាងក្រោម៖

- អនុវត្តមុខងារសវនកម្មផ្ទៃក្នុងលើការពង្រឹងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់ក្រសួង
- វាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់អង្គភាពក្រោមឱវាទក្រសួង សំដៅពង្រឹងអភិបាលកិច្ចល្អ និង
- ធ្វើរបាយការណ៍ត្រង់ទៅប្រធានស្ថាប័ន ដោយផ្ញើច្បាប់ចម្លងទៅអាជ្ញាធរសវនកម្មជាតិ និងសម្របសម្រួលការងារជាមួយសមត្ថកិច្ចត្រួតពិនិត្យនានា។

## ជំពូកទី១០
## អង្គភាពថ្នាក់ក្រោមជាតិនៃក្រសួងរ៉ែនិងថាមពល

**មាត្រា២៤.-**

ក្រសួងរ៉ែនិងថាមពលមានអង្គភាពថ្នាក់ក្រោមជាតិដែលជាមន្ទីររ៉ែនិងថាមពលរាជធានី ខេត្ត ដើម្បីបំពេញមុខងារពាក់ព័ន្ធនឹងវិស័យរបស់ក្រសួងរ៉ែនិងថាមពលនៅថ្នាក់ក្រោមជាតិ។

## ជំពូកទី១១
## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា២៥.-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមលក្ខខណ្ឌនៃបទបញ្ញាកំណត់ក្នុងអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល។

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

**មាត្រា២៦.-**

អនុក្រឹត្យលេខ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងរ៉ែនិងថាមពលត្រូវទុកជានិរាករណ៍ រាល់លិខិតបទដ្ឋានគតិយុត្តដែលចែងយោងអនុក្រឹត្យនេះនៅតែមានសុពលភាពបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

**មាត្រា២៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៧ រោច ខែ អស្សុជ ឆ្នាំ ច សំរឹទ្ធិ ស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា២៧
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃព្រហស្បតិ៍ ១៣កើត ខែ ស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ត្រូវនឹងថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៨



## V. ឧបសម្ព័ន្ធទី៥ យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣

# រាជរដ្ឋាភិបាលកម្ពុជា

## គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣

បានទទួលការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា

នាថ្ងៃពុធ ៥កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦២

ត្រូវនឹងថ្ងៃទី ០៨ ខែឧសភា ឆ្នាំ ២០១៩

# បុព្វកថា

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព, ស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ប្រកបដោយកំណើនខ្ពស់ និងរឹងមាំ សម្រាប់រយៈពេល ៥ ឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តនូវ **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨** ប្រកបដោយជោគជ័យគួរជាទីមោទនៈ ដោយសម្រេចបានទាំងកំណើនចំណូល, ការពង្រឹងធនធានមនុស្ស, សមត្ថភាពស្ថាប័ន និងអភិបាលកិច្ច, ការសម្របសម្រួលក្រសួង-ស្ថាប័នគ្រប់គ្រង និងប្រមូលចំណូល និងការលើកកម្ពស់វប្បធម៌បង់ពន្ធរបស់ប្រជាពលរដ្ឋ ។ ជាក់ស្តែង ចំណូលចរន្តសរុបបានកើនឡើងពី ១៥,១% នៃ ផ.ស.ស. នៅឆ្នាំ ២០១៣ ដល់ ២២,០% នៃ ផ.ស.ស. នៅឆ្នាំ ២០១៨ ហើយមានកំណើនជាមធ្យមប្រមាណ ១,៤ ពិន្ទុភាគរយនៃ ផ.ស.ស. ក្នុងមួយឆ្នាំ ។ ភាពជោគជ័យដ៏កម្រក្នុងការកៀរគរចំណូលរបស់កម្ពុជា ត្រូវបានទទួលស្គាល់ និងវាយតម្លៃខ្ពស់ ដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ទាំងក្នុងតំបន់ និងសកលលោក ។

ជាមួយគ្នានេះ កំណើនចំណូលនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣** ដោយបានរួមចំណែកក្នុងការសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងអត្រាប្រមាណ ៧% ក្នុងមួយឆ្នាំ, ការកាត់បន្ថយភាពក្រីក្រមកក្នុងរង្វង់ ១០% ក្នុងឆ្នាំ ២០១៨, ការបង្កើតការងារសមរម្យជូនប្រជាពលរដ្ឋ, ការបន្តដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ, ការបង្កើនគុណភាពនិងពង្រីកវិសាលភាពសេវាសាធារណៈសំខាន់ៗ ទាំងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, អប់រំ, សុខាភិបាល និងសេវាមូលដ្ឋានចាំបាច់ផ្សេងទៀត រួមទាំងរបបសន្តិសុខសង្គម និងសុខុមាលភាពរបស់ប្រជាពលរដ្ឋទូទៅ និងការកាត់បន្ថយគម្លាតនៃការរីកចម្រើនរវាងទីក្រុង និងជនបទ ជាពិសេសការបន្តពង្រឹងភាពជាម្ចាស់ និងឯករាជ្យភាពកម្ពុជាក្នុងការគ្រប់គ្រងកិច្ចអភិវឌ្ឍរបស់ខ្លួន ។

**យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣** ជាការបន្តកែទម្រង់ជាយុទ្ធសាស្ត្រ មួយដំណាក់កាលទៀត ដែលកាន់តែមុតស្រួច និងកាន់តែស៊ីជម្រៅ ក្នុងការលើកកម្ពស់សមត្ថភាពរដ្ឋបាលប្រមូលចំណូល, ការបន្តពង្រឹងអភិបាលកិច្ច, ការលើកកម្ពស់គុណភាព, ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃសេវា និងការរៀបចំគោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធ សំដៅលើកកម្ពស់បរិយាកាសធុរកិច្ច, ពង្រឹងភាពប្រកួតប្រជែង និងជំរុញការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច និយាយជារួម និងជាឧបករណ៍នៃគោលនយោបាយរបស់រាជរដ្ឋាភិបាលមួយយ៉ាងសំខាន់ក្នុងការបន្តកៀរគរចំណូលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ដើម្បីបំពេញតម្រូវការហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលសម្រាប់ការអនុវត្តវិធានការកែទម្រង់នានា ជាពិសេសរួមចំណែកក្នុងការអនុវត្តឱ្យចេញជាផ្លែផ្កានូវ **កម្មវិធីនយោបាយ** និង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤** និយាយដោយឡែក ។ យុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងដោយប្រកាន់ខ្ជាប់នូវអភិក្រមចំនួន ៤ គឺ÷ (១)ធានាចីរភាពកំណើនសេដ្ឋកិច្ច, (២)រក្សាបាននូវចីរភាពចំណូលដែលឈានទៅដល់កម្រិតឧត្តមានុពល, (៣)ធានានូវយុត្តិធម៌ក្នុងការអនុវត្តគោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធ ព្រមទាំងការប្រមូលចំណូល និង (៤)ធានានូវសមធម៌សង្គម ដើម្បីចូលរួមចំណែកបន្ធូរបន្ថយបន្ទុកពន្ធដល់ប្រជាជនមានចំណូលទាប, បង្កើនសុខុមាលភាពប្រជាពលរដ្ឋ និងរក្សាការពារបរិស្ថាន ។

ជារួម យុទ្ធសាស្ត្រនេះមានចក្ខុវិស័យប្រែក្លាយប្រព័ន្ធចំណូលរដ្ឋឱ្យមានលក្ខណៈទំនើប ដែលអាចឆ្លើយតបទៅនឹងបរិការណ៍នៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាក្នុងដំណាក់កាលប្រែប្រួលថ្មីមួយទៀត ដោយធ្វើទំនើបភាវូបនីយកម្មរដ្ឋបាល និងគោលនយោបាយចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ស្របតាមគោលដៅរួមរបស់រាជរដ្ឋាភិបាល គឺ កសាងប្រព័ន្ធរដ្ឋបាលសាធារណៈមួយដែលកាន់តែមានភាពស្អាតស្អំ, ឆ្លាតវៃ និងមានសមត្ថភាពខ្លាំងពូកែ ដើម្បីសម្រេចឱ្យបាននូវឋានៈជាប្រទេសមាន **ចំណូលមធ្យមកម្រិតខ្ពស់** នៅឆ្នាំ ២០៣០ ។ ជាងនេះទៅទៀត យុទ្ធសាស្ត្រនេះបានកំណត់គោលដៅ ២ សំខាន់ៗគឺ៖ (១)ប្រមូលចំណូលចរន្តសរុបឱ្យកើនបានយ៉ាងតិច ០,៣ ពិន្ទុភាគរយនៃ ផ.ស.ស. ជាមធ្យមក្នុងមួយឆ្នាំ និង(២)បង្កើនគុណភាពសេវា និងផលិតភាពក្នុងការផ្តល់សេវាគ្រប់ប្រភេទនៃរដ្ឋបាលប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ។

ជាចុងក្រោយ តាងនាមឱ្យរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណចំពោះការខិតខំប្រឹងប្រែង ទាំងកម្លាំងកាយ និងកម្លាំងចិត្ត របស់ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានសហការគ្នាល្អក្នុងការអនុវត្ត **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨** ប្រកបដោយភាពជោគជ័យខ្ពស់ ។ ក្នុងរយៈពេល ៥ ឆ្នាំខាងមុខនេះ រាជរដ្ឋាភិបាលចាំបាច់ត្រូវបន្តអនុវត្តឱ្យមានប្រសិទ្ធភាពនូវការកែទម្រង់ស៊ីជម្រៅ លើគ្រប់វិស័យឱ្យកាន់តែមុតស្រួចជាងមុន និងលទ្ធផលជាក់ស្តែង សំដៅចូលរួមគាំទ្រដល់កិច្ចអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឱ្យមានភាពរុងរឿងជានិច្ចនិរន្តរ៍ ដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នា និងការរំពឹងទុកកាន់តែខ្ពស់របស់ប្រជាពលរដ្ឋកម្ពុជា ។ ក្នុងន័យនេះ ខ្ញុំជឿជាក់ថា គ្រប់តួអង្គពាក់ព័ន្ធទាំងអស់នឹងបន្តខិតខំប្រឹងប្រែងទ្វេដងប្រកបដោយសុឆន្ទៈ, បុរេសកម្ម, អន្តរសកម្ម និងស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវ **យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣** ដោយប្រកាន់ខ្ជាប់នូវអភិក្រម ៥ ប្រការគឺ "**ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល និង វះកាត់**" ។

ថ្ងៃព្រហ ៥កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែឧសភា ឆ្នាំ ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

៨២. ដើម្បីដោះស្រាយបញ្ហាខាងលើ រាជរដ្ឋាភិបាលត្រូវរៀបចំក្របខ័ណ្ឌគតិយុត្តថ្មីឱ្យស្របតាមការវិវឌ្ឍនៃសកម្មភាពសេដ្ឋកិច្ចកម្ពុជាជាក់ស្តែង ក្នុងន័យធ្វើឱ្យប្រសើរការអភិវឌ្ឍសហគ្រាសសាធារណៈ, ការបង់ចំណូលភាគលាភចូលថវិកាជាតិឱ្យបានត្រឹមត្រូវ និងការផ្តល់របាយការណ៍ដែលបានធ្វើសវនកម្មឯករាជ្យ ។

### ជ. គ្រឹះស្ថានសាធារណៈរដ្ឋបាល

៨៣. ការកែទម្រង់ការគ្រប់គ្រងគ្រឹះស្ថានសាធារណៈរដ្ឋបាល ផ្តោតសំខាន់លើការគ្រប់គ្រងប្រកបដោយតម្លាភាព, គណនេយ្យភាព និងសមធម៌ ដើម្បីពង្រីកសេវាសាធារណៈប្រកបដោយគុណភាព ព្រមទាំងអាចគ្រប់គ្រងបាននូវហានិភ័យ និងកាត់បន្ថយបន្ទុកចំណាយថវិការដ្ឋ ។ កន្លងមក ច្បាប់ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាលរួមទាំងបទប្បញ្ញត្តិគាំទ្រផ្សេងៗត្រូវបានរៀបចំ ប៉ុន្តែការអនុវត្តនៅមិនទាន់រលូនដោយសារសមត្ថភាពមន្ត្រី និងការយល់ដឹងពីនីតិវិធីថ្មីនៅមានកម្រិត ។

៨៤. ដើម្បីដោះស្រាយបញ្ហាខាងលើ គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវអនុវត្តតាមលក្ខន្តិកៈគតិយុត្ត និងនីតិវិធីហិរញ្ញវត្ថុថ្មី ឱ្យបានពេញលេញ ដើម្បីធានាតម្លាភាពនៃប្រតិបត្តិការរបស់គ្រឹះស្ថាន ។

### ឈ. វិស័យរ៉ែ និងថាមពល

៨៥. វិស័យរ៉ែនិងថាមពល ជាវិស័យមានសក្តានុពលមួយនាពេលអនាគត និងអាចជាប្រភពចំណូលបន្ថែមដ៏សំខាន់របស់រាជរដ្ឋាភិបាលកម្ពុជា ។ កន្លងមក ការប្រមូលចំណូលពីវិស័យរ៉ែ និងថាមពល មានកំណើនជាមធ្យម ៤១,១% ក្នុងមួយឆ្នាំពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៨ ។ ទោះបី រាជរដ្ឋាភិបាលដាក់អនុវត្តបទប្បញ្ញត្តិមួយចំនួនដើម្បីបង្កើនប្រសិទ្ធភាពគ្រប់គ្រងលើវិស័យនេះ ការប្រមូលចំណូលនៅប្រឈមនឹងបញ្ហាមួយចំនួនដូចជា÷ (១)កាតព្វកិច្ចហិរញ្ញវត្ថុដែលមាននៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមានមួយចំនួន នៅមិនទាន់សមស្របនឹងការវិវឌ្ឍសេដ្ឋកិច្ច, (២)ប្រសិទ្ធភាពនៃការកៀរគរការប្រមូលចំណូលពីសួយសារ សម្រាប់រដ្ឋនៅមានកម្រិត, (៣)កង្វះប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគ្រប់គ្រងកិច្ចសន្យា/កិច្ចព្រមព្រៀង និងអាជ្ញាបណ្ណរ៉ែ និងថាមពល, និង (៤)កង្វះមន្ត្រីក្នុងការចុះកៀរគរចំណូលឱ្យមានប្រសិទ្ធភាព ។

៨៦. ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចជា÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- សិក្សា និងធ្វើបច្ចុប្បន្នភាព កាតព្វកិច្ចហិរញ្ញវត្ថុនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន ឱ្យស្របតាមការវិវឌ្ឍសេដ្ឋកិច្ចកម្ពុជា និងផ្តល់ផលប្រយោជន៍ជូនភាគីរាជរដ្ឋាភិបាល,
- ពង្រឹងប្រសិទ្ធភាពនៃការកៀរគរការប្រមូលចំណូលពីសួយសារ,
- បន្តអនុវត្តលើការបង់ចំណូលពីវិស័យធនធានរ៉ែ ដោយតម្រូវឱ្យសម្បទានិកធ្វើការបង់ចំណូលដែលគ្រោងជាមុន ដោយផ្អែកលើផែនការផលិតកម្ម និងមធ្យោបាយផលិតកម្ម,

- រៀបចំប្រព័ន្ធព័ត៌មានសម្រាប់គ្រប់គ្រងកិច្ចសន្យា/កិច្ចព្រមព្រៀង និងអាជ្ញាបណ្ណ័ និងថាមពល ដើម្បីពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល,
- រៀបចំលិខិតបទដ្ឋាន ដើម្បីកំណត់ឱ្យក្រុមហ៊ុនអាជីវកម្មរ៉ែមានប្រធានការដ្ឋានដែលមានជំនាញច្បាស់លាស់នៅគ្រប់ការដ្ឋានរ៉ែ ។

### ៣. ចំណូលពីសកម្មភាពល្បែង

៨៧. ចំណូលពីសកម្មភាពល្បែងរួមមានចំណូលពីកាស៊ីណូ និងចំណូលពីអាជីវកម្មល្បែងផ្សងសំណាង ដែលចំណូលនេះមានចំណែកប្រមាណ ៧% នៃចំណូលមិនមែនសារពើពន្ធសរុបក្នុងឆ្នាំ ២០១៨ និងមានកំណើនជាមធ្យម ១៣,៤% ក្នុងមួយឆ្នាំ ពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៨ ។ វិស័យនេះមានការលូតលាស់ខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប៉ុន្តែការគ្រប់គ្រងបច្ចុប្បន្ននៅជួបប្រទះបញ្ហាមួយចំនួនដូចជា÷ (១)ច្បាប់ស្តីពីរមណីយដ្ឋានសមាហរណ និងល្បែងពាណិជ្ជកម្មនៅមិនទាន់អនុម័ត ដែលនាំឱ្យខ្វះមូលដ្ឋានគតិយុត្តគ្រប់ជ្រុងជ្រោយក្នុងការគ្រប់គ្រង និង (២) សកម្មភាពល្បែងខុសច្បាប់នៅបន្តកើតមាន ដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ។

៨៨. ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ វិធានការចាំបាច់មួយចំនួនត្រូវដាក់ចេញ ដូចជា÷

**វិធានការរយៈពេលខ្លី ២០១៩-២០២០÷**

- ពន្លឿនការអនុម័តច្បាប់ស្តីពីរមណីយដ្ឋានសមាហរណ និងល្បែងពាណិជ្ជកម្ម,
- បន្តពង្រឹងកិច្ចសហប្រតិបត្តិការរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ដើម្បីធានាប្រសិទ្ធភាពក្នុងការបង្ក្រាបអាជីវកម្មល្បែងខុសច្បាប់,
- បន្តខិតខំកៀរគរចំណូលឱ្យអស់ពីលទ្ធភាពពីសកម្មភាពល្បែងគ្រប់ប្រភេទ ដែលទទួលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលតាមបទប្បញ្ញត្តិជាធរមាន ។

**វិធានការរយៈពេលមធ្យម ២០២១-២០២៣÷**

- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងបទប្បញ្ញត្តិគាំទ្រដល់ការអនុវត្តច្បាប់ស្តីពីរមណីយដ្ឋានសមាហរណ និងល្បែងពាណិជ្ជកម្ម ។

### ៤. ចំណូលពីទ្រព្យសម្បត្តិរដ្ឋ

៨៩. ចំណូលពីទ្រព្យសម្បត្តិរដ្ឋមានប្រភពពីការជួលទ្រព្យសម្បត្តិរដ្ឋ និងសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ។ កន្លងមកការប្រមូលចំណូលពីទ្រព្យសម្បត្តិរដ្ឋ មានបញ្ហាប្រឈម ដូចជា÷ (១) លក្ខខណ្ឌនៃកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋមួយចំនួន មិនទាន់ឆ្លុះបញ្ចាំងពីការវិវឌ្ឍនៃសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន និង (២) ការត្រួតពិនិត្យលើការអនុវត្តកិច្ចសន្យា និងសៀវភៅបន្ទុកនៃសម្បទានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ (ដូចជាភាស៊ីផ្សារ, ចំណតរថយន្ត និងសម្បទានដទៃទៀត) នៅមិនទាន់មានប្រសិទ្ធភាព ។

## VI. ឧបសម្ព័ន្ធទី៦ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៩-២០២៣



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
# ២០១៩-២០២៣

ដើម្បីកំណើន បង្កើតការងារ ឆានាសមធម៌ និងប្រសិទ្ធភាព
ឆ្ពោះទៅប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ ឆ្នាំ២០៣០

# ព្រះរាជក្រម

នស/រកម/០៧១៩/០១១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩ - ២០២៣ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩ នាសម័យប្រជុំពេញអង្គលើកទី៣ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រ
## អភិវឌ្ឍន៍ជាតិ ២០១៩ - ២០២៣

**មាត្រា១.-**

អនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ដូចមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ នេះ។

**មាត្រា៣.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃព្រហស្បតិ៍ ៩រោច ខែ អាសាឍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៩

នស/រកម/០៧១៩/០១៤

សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**ឆាយ ថន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

ប្រព័ន្ធគ្រប់គ្រង សុវត្ថិភាពរបស់ប្រតិបត្តិការអាកាសយានដ្ឋាន ការផ្គត់ផ្គង់ទឹក ភ្លើងអគ្គិសនី និងកិច្ចការពារបរិស្ថាន ស្របតាមច្បាប់ និងបទប្បញ្ញត្តិអាកាសចរស៊ីវិលកម្ពុជា និងស្តង់ដា និងអនុសាសន៍របស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ។

- ត្រួតពិនិត្យការអនុវត្ត និងស្តង់ដាសម្រាប់គម្រោងកសាងអាកាសយានដ្ឋានដែលមានស្រាប់ និងអាកាសយានដ្ឋានថ្មី សិក្សាទីតាំងកិច្ចដំណើរការ(រួមមានទាំងសម្ភារៈនិងបរិក្ខារ) ការងារ វិស្វកម្ម និងជួសជុលថែទាំ។
- សិក្សានិងវាយតម្លៃលើសំណើសុំអាជ្ញាប័ណ្ណសម្រាប់សាងសង់អាកាសយានដ្ឋានថ្មី។
- សិក្សា និង វាយតម្លៃបច្ចេកទេសក្នុងការផ្តល់វិញ្ញាបនបត្រអាកាសយានដ្ឋាន។
- សិក្សានិងវាយតម្លៃបច្ចេកទេសក្នុងការផ្តល់វិញ្ញាបនបត្រចុះបញ្ជីនិងប្រតិបត្តិអាកាសយានដ្ឋាន
- ផ្តល់យោបល់ និងណែនាំស្តីពីឧបសគ្គទាំងឡាយណាដែលរំខានទាំងនៅក្នុងនិងក្រៅអាកាសយានដ្ឋាននិងអនុវត្តឲ្យបានសមស្របតាមស្តង់ដា និងការណែនាំ ដូចមានចែងអំពីសញ្ញានិងភ្លើងរំខាន។

**៦. ការអភិវឌ្ឍធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន៖** ដើម្បីធានាសុវត្ថិភាព សន្តិសុខឲ្យបានឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវការ។ មានមន្ត្រីមានសមត្ថភាព និងជំនាញអាកាសចរស៊ីវិលគ្រប់គ្រាន់ក្នុងការអនុវត្តការងារស្របតាមគោលការណ៍ណែនាំផ្សេងៗរបស់រដ្ឋាភិបាល ព្រមទាំងអាចលើកកម្ពស់ការងារគ្រប់គ្រងស្ថាប័ននិងជួយគាំទ្រដល់ការអនុវត្តការងារបច្ចេកទេស។

៤.១០០- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាល ទី៦នៃរដ្ឋសភា ***ក្រសួងរ៉ែ និង ថាមពល*** នឹងបន្តការងារអាទិភាពរបស់ខ្លួន ក្នុងការគ្រប់គ្រងនិងជំរុញការអភិវឌ្ឍវិស័យអគ្គិសនី ដើម្បីឈានទៅសម្រេចឲ្យបានការផ្គត់ផ្គង់ថាមពលអគ្គិសនីមួយគ្រប់គ្រាន់មានចីរភាព អាចទុកចិត្តបាន មានគុណភាព និងមានថ្លៃសមរម្យសម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ និងគ្រប់គ្រង និងជំរុញការអភិវឌ្ឍប្រសិទ្ធភាពថាមពលនិងសន្សំសំចៃថាមពល។ ក្រសួងក៏មានគោលដៅគ្រប់គ្រងនិងជំរុញការស្រាវជ្រាវ ការអភិវឌ្ឍ និងការប្រើប្រាស់ថាមពលបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម និងបច្ចេកទេសថាមពលបរមាណូ ក្នុងគោលបំណងសន្តិភាព សុវត្ថិភាព និងមានសន្តិសុខ។ ដើម្បីសម្រេចបាននូវការប្តេជ្ញាខាងលើ ក្រសួងបានដាក់ចេញនូវសកម្មភាពយុទ្ធសាស្ត្រមួយចំនួន ដូចខាងក្រោម៖

- ជំរុញការអភិវឌ្ឍវិស័យថាមពល និងថាមពលអគ្គិសនី ដោយបង្កើនការតភ្ជាប់អគ្គិសនីជូនប្រជាពលរដ្ឋប្រកបដោយគុណភាព ស្ថិរភាព និងថ្លៃសមរម្យដែលផលិតពីប្រភពផ្សេងៗ រួមទាំងវារីអគ្គិសនី ចំហេះ និងពន្លឺព្រះអាទិត្យ។
- ពង្រឹងការងារបច្ចេកទេសថាមពល និងស្តង់ដាអគ្គិសនីក្នុងអគារ និងលំនៅដ្ឋាន។

- ពង្រឹងការងារវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាថាមពលបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម និងបច្ចេកទេសថាមពលបរមាណូ។

## តារាងទី ៤.៩ សូចនាករសំខាន់ៗនៃវិស័យថាមពល

| ល.រ | សូចនាករ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|---|---|
| | | មូលដ្ឋាន | ប៉ាន់ស្មាន | ព្យាករណ៍ | ព្យាករណ៍ | ព្យាករណ៍ | ព្យាករណ៍ | ព្យាករណ៍ |
| ១ | ការផ្គត់ផ្គង់ថាមពលអគ្គិសនី | លាន គ.វ.ម. | ៩ ៣០៧ | ១០ ៨០៨ | ១២ ៩៦៩ | ១៥ ៣០៤ | ១៧ ៥៩៩ | ២០ ០៦៣ |
| ២ | ភាគរយនៃភូមិទទួលបានការផ្គត់ផ្គង់អគ្គិសនី | (%) | ៨៦,៨៥ | ៩៣,០ | ១០០,០ | ១០០,០ | ១០០,០ | ១០០,០ |
| ៣ | ការប្រើប្រាស់អគ្គិសនីរបស់ប្រជាជនម្នាក់ក្នុង១ឆ្នាំ | គ.វ.ម./១ នាក់ | ៥៧៩ | ៦៦៤ | ៧៨៦ | ៩១៥ | ១ ០៣៧ | ១ ១៦៥ |
| ៤ | ភាគរយនៃខ្នងផ្ទះដែលទទួលបានការផ្គត់ផ្គង់អគ្គិសនី | % | ៧២,១ | ៧៤,៦ | ៧៧,៤ | ៨៣,០៥ | ៨៧,៩ | ៩០,០ |
| ៥ | ភាគរយនៃប្រភពថាមពលអគ្គិសនីកកើតឡើងវិញ (អានុភាពតម្លើង) | % | ៥២,៦ | ៥១,១ | ៥២,១ | ៥៤,០៤ | ៥៥,២២ | ៤៨,២៣ |
| ៦ | ប្រវែងខ្សែបណ្តាញបញ្ជូនជាតិ១១៥/២៣០ គីឡូវ៉ុល | គ.ម. | ២ ១៤១ | ១ ៤៤១ | ២ ៤៤១ | ២ ៥៣៦ | ២ ៦១១ | ២ ៦១១ |
| ៧ | ប្រវែងខ្សែបណ្តាញបញ្ជូនជាតិ ៥០០គីឡូវ៉ុល | គ.ម. | ០ | ១៤០ | ១៤០ | ២៣០ | ២៣០ | ២៣០ |
| ៨ | រៀបចំច្បាប់ស្តីពីបរមាណូនៃព្រះរាជាណាចក្រកម្ពុជា | % | ២០ | ៤០ | ១០០ | | | |
| ៩ | រៀបចំបទដ្ឋានបច្ចេកទេស និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសន្តិសុខ សុវត្ថិភាព និងការការពារសុវត្ថិភាពនៃសារធាតុវិទ្យុសកម្ម និងបរមាណូ | ឯកសារ | - | ២ | ៥ | - | - | - |
| ១០ | គោលនយោបាយជាតិស្តីពីប្រសិទ្ធភាពថាមពល | % | - | ៤០ | ១០០ | | | |
| ១១ | អនុក្រឹត្យស្តីពីបទដ្ឋានបច្ចេកទេសអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់រៀបចំបណ្តាញអគ្គិសនីក្នុងអាគារនិងលំនៅដ្ឋាន | % | ៦០ | ៨០ | ១០០ | | | |
| ១២ | មជ្ឈមណ្ឌលបាញ់កាំរស្មីវិទ្យុសកម្មសម្លាប់មេរោគ | % | - | - | ៣០ | ៥០ | ១០០ | |

៤.១០១- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍*** នឹងបន្តការងារអាទិភាពរបស់ខ្លួនរួមឲ្យស្របតាមការវិវឌ្ឍរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដែលសកម្មភាពជាអាទិភាព រួមមាន៖

- បន្តការរៀបចំក្របខ័ណ្ឌគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត។
- បន្តរៀបចំវិស័យប្រៃសណីយ៍ឲ្យមានលក្ខណៈទំនើបស្របតាមស្តង់ដាអន្តរជាតិ ជាពិសេសការទទួលនិងចែកចាយបញ្ញើ ដើម្បីរុញច្រានវិស័យប្រៃសណីយ៍ឲ្យកាន់តែមានប្រសិទ្ធភាព និង វឌ្ឍនភាពក្នុងឆាកអន្តរជាតិ ដោយការចាប់ដៃគូពាណិជ្ជកម្មជាមួយក្រុមហ៊ុនក្នុងនិងក្រៅប្រទេស។

- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីជំរុញដល់ការបង្កើតទីផ្សារផលិតផលវប្បធម៌និងទីផ្សារការងារក្នុងវិស័យវប្បធម៌ និងសិល្បៈ។
- ពង្រីកទីផ្សារផលិតផលនិងសេវាកម្មវប្បធម៌ ដោយផ្តល់ឱកាសឲ្យបានទូលំទូលាយជូនដល់សិល្បករ ផលិតករ និងអ្នកប្រកបអាជីពក្នុងវិស័យវប្បធម៌ និង សិល្បៈ។
- បង្កលក្ខណៈលើកទឹកចិត្តនិងជំរុញដល់ការច្នៃប្រឌិតបង្កើតថ្មីស្នាដៃដើម ហើយថ្មីក្នុងផ្នែកតន្ត្រី សោតទស្សន៍ ភាពយន្ត សិល្បៈទស្សនីយភាព សិប្បកម្ម វិចិត្រកម្ម តម្បាញ ប្រពៃណី និងការរចនាច្នៃម៉ូដ។
- ជំរុញការរៀចំពិព័រណ៍ស្នាដៃច្នៃប្រឌិតបង្កើតថ្មីក្នុងវិស័យសិល្បៈវប្បធម៌និងឧស្សាហកម្ម។
- លើកកម្ពស់វិស័យភាពយន្តនៅកម្ពុជាដោយ ៖
  - អភិវឌ្ឍធនធានមនុស្សក្នុងវិស័យភាពយន្ត។
  - បង្កើនការផ្សព្វផ្សាយគ្រប់រូបភាព ដើម្បីទាក់ទាញក្រុមហ៊ុនបរទេសមកថតភាពយន្តនៅកម្ពុជា ប្រែក្លាយជាដែនដីស្វាគមន៍នៃការថតភាពយន្តបរទេស។
  - បង្កើនយន្តការសម្របសម្រួលក្នុងការស្នើសុំថតភាពយន្តតាមច្រកចេញចូលតែមួយ។
  - បន្តនយោបាយ "ម៉ោងមាស" សម្រាប់ភាពយន្តក្នុងស្រុក។
  - ប្រែក្លាយមេណឺយដ្ឋានបេតិកភណ្ឌវប្បធម៌ ទៅជាគោលដៅនៃការទាក់ទាញក្នុងការថតភាពយន្ត ការសម្តែងសិល្បៈនិងការវិនិយោគក្នុងវិស័យទេសចរណ៍។
- ជំរុញឲ្យកម្ពុជា ជាទីកន្លែងផ្សព្វផ្សាយផលិតផលវប្បធម៌
  - បង្កើតប្រព័ន្ធទិន្នន័យស្តីពីអង្គការ សមាគម និងសហគ្រាសវប្បធម៌។
  - ធ្វើអត្តសញ្ញាណកម្មវប្បធម៌ និងភូមិមួយផលិតផលមួយ។
- រៀបចំយន្តការសម្រួលការនាំចូលសម្ភារបច្ចេកវិទ្យាស្តង់ដានិងស្របច្បាប់ជូនដល់សហគ្រិនប្រកបមុខរបរលើវិស័យវប្បធម៌។

៤.១១២- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងរ៉ែ និង ថាមពល*** មានបេសកកម្មយ៉ាងធំធេងក្នុងការអភិវឌ្ឍវិស័យប្រេងកាតឲ្យអស់លទ្ធភាព តាមរយៈការស្វែងរុករក អភិវឌ្ឍផលិតកម្ម ប្រព្រឹត្តកម្ម ដឹកជញ្ជូនសន្និធិ និងការធ្វើពាណិជ្ជកម្ម ប្រេងនិងឧស្ម័ន ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងផលប្រយោជន៍យូរអង្វែងនៃប្រទេសជាតិ និងភាពល្អប្រសើរនៃជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។

៤.១១៣- ដើម្បីសម្រេចបាននូវបេសកកម្មខាងលើ ***ក្រសួងរ៉ែនិងថាមពល*** នឹងរៀបចំ ***គោលនយោបាយជាតិប្រេងកាត ឆ្នាំ២០២០-២០៣០*** និងដាក់ចេញផែនការសកម្មភាពសម្រាប់អនុវត្តឲ្យបានចប់សព្វគ្រប់នៅឆ្នាំ២០២០។ សកម្មភាពជាអាទិភាព រួមមានដូចខាងក្រោម៖

- កសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។
- កសាងសមត្ថភាព និងពង្រឹងស្ថាប័ន ទាំងផ្នែកអាប់ស្ទ្រីម និងដោនស្ទ្រីម
- បង្កើនចំណូលពីវិស័យប្រេងកាត។

- ជំរុញភាពទទួលខុសត្រូវសង្គម និងបរិស្ថានក្នុងប្រតិបត្តិការប្រេងកាត និងសន្តិសុខថាមពល។

៤.១១៤- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ក្នុងការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះ និងថ្មីៗ ***ក្រសួងពាណិជ្ជកម្ម*** នឹងអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម ៖

- អភិវឌ្ឍន៍ការធ្វើពិពិធកម្មផលិតផល៖ ១. សិក្សា និងចងក្រងអត្តសញ្ញាណផលិតផលសក្តានុពលកម្ពុជា ដើម្បីពង្រឹងកេរ្តិ៍ឈ្មោះ និងពង្រីកការនាំចេញផលិតផលទាំងនោះទៅទីផ្សារអន្តរជាតិ ២. បន្តការងារបង្កើត និងគ្រប់គ្រងមជ្ឈមណ្ឌលអចិន្ត្រៃយ៍ផលិតផលកម្ពុជា និងមជ្ឈមណ្ឌលជំរុញពាណិជ្ជកម្ម នៅក្នុងនិងក្រៅប្រទេស ៣. សហការជាមួយដៃគូជំរុញពាណិជ្ជកម្ម និងមជ្ឈមណ្ឌលពាណិជ្ជកម្មនៅក្រៅប្រទេសដើម្បីជំរុញផលិតផលកម្ពុជាទៅក្នុងទីផ្សារតំបន់ និងពិភពលោក។
- អភិវឌ្ឍការធ្វើពិពិធកម្មទីផ្សារនាំចេញ៖ ១. រៀបចំគោលនយោបាយជំរុញការនាំចេញ ២. រៀបចំបង្កើតប្រព័ន្ធត្រួតពិនិត្យ វាយតម្លៃនៃការអនុវត្តគោលនយោបាយពាណិជ្ជកម្ម និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយពាណិជ្ជកម្ម ៣. ពង្រឹងនិងពង្រីកការរៀបចំពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេស និងអន្តរជាតិ ៤. បន្តស្រាវជ្រាវ តាមដាន និងវិភាគការវិវឌ្ឍសេដ្ឋកិច្ចពាណិជ្ជកម្ម របាំងពាណិជ្ជកម្ម និងយុទ្ធសាស្ត្រពាណិជ្ជកម្មរបស់ប្រទេសត្រូវធ្វើពាណិជ្ជកម្ម ៥. ធ្វើឲ្យប្រសើរឡើងនូវកិច្ចសម្រួលពាណិជ្ជកម្មលើគ្រប់ប្រតិបត្តិការនៃដំណើរការនាំចេញ ៦. ពង្រឹង និងពង្រីកកិច្ចព្រមព្រៀងពាណិជ្ជកម្មក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី។

## ៤.៣- ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤

### ក- គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦

៤.១១៥- បដិវត្តន៍ឧស្សាហកម្មសកល បានធ្វើឲ្យមានការផ្លាស់ប្តូរយ៉ាងខ្លាំងនូវស្ថានភាពសង្គម-សេដ្ឋកិច្ចសកល ដោយសារនវានុវត្តន៍បច្ចេកវិទ្យា ហើយកំពុងស្ថិតក្នុងដំណាក់កាលផ្លាស់ប្តូរថ្មីមួយទៀត គឺបដិវត្តន៍ឧស្សាហកម្មទី៤។ ការណ៍នេះ តម្រូវឲ្យរាជរដ្ឋាភិបាលយកចិត្តទុកដាក់លើការរៀបចំខ្លួនចាប់យកកាលានុវត្តភាព និងការត្រៀមខ្លួនឆ្លើយតបនឹងបញ្ហាប្រឈមដែលកើតចេញពីវិស័យសេដ្ឋកិច្ចថ្មីៗ ការអភិវឌ្ឍសហគ្រាសធុនតូច និង មធ្យម ការលើកកម្ពស់ផលិតភាព និង ប្រសិទ្ធភាពវិស័យកសិកម្ម ការធ្វើឲ្យប្រសើរនូវប្រព័ន្ធសុខាភិបាល ការបង្កើនសមត្ថភាពរៀបចំខ្លួនសម្រាប់ទប់ទល់នឹងគ្រោះមហន្តរាយ ព្រមទាំងការរៀបចំនគរូបនីយកម្មប្រកបដោយ

សហគមន៍ក្នុងការការពារ និង ស្តារព្រៃឈើឡើងវិញ ព្រមទាំងការបង្ក្រាបបទល្មើស ព្រៃឈើ និង ការជួញដូរសត្វព្រៃ។

ទី៤-ការបន្តជំរុញការអភិរក្ស និង គ្រប់គ្រងធនធានជលផល តាមរយៈ ការបង្ក្រាបបទល្មើសជលផល ការធ្វើឲ្យប្រសើរឡើងនូវសហគមន៍នេសាទ និង ការបង្កើនវារីវប្បកម្ម។

ទី៥-ការលើកកម្ពស់ការថែរក្សាប្រព័ន្ធអេកូឡូស៊ី និង ការការពារតំបន់ធម្មជាតិ ដោយផ្តោតលើការការពារជីវៈចម្រុះ តំបន់ដីសើម និង តំបន់ឆ្នេរ ដើម្បីធានាគុណភាពដី និង ចីរភាពប្រភពទឹក។

ទី៦-ការបន្តអភិរក្ស និង អភិវឌ្ឍបេតិកភណ្ឌវប្បធម៌ ដោយជំរុញការចុះបញ្ជី ពង្រឹងការគ្រប់គ្រង ការសិក្សាស្រាវជ្រាវ និង ចងក្រង ព្រមទាំងការបង្កើត តម្លៃពីបេតិកភណ្ឌវប្បធម៌។

## ខ- សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព ធនធានរ៉ែ

៤.១៧៩- ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៦នៃរដ្ឋសភា ***ក្រសួងរ៉ែ និង ថាមពល*** នឹងបន្តអនុវត្ត ***គោលនយោបាយជាតិស្តីពីធនធានរ៉ែឆ្នាំ២០១៨-២០២៨*** ដោយពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងធនធាន និងអាជីវកម្មរ៉ែ ទន្ទឹមនឹងការជំរុញការចូលរួមពីសហគមន៍ដើម្បីកាត់បន្ថយផលប៉ះពាល់លើបរិស្ថានសង្គមនិងពង្រីកការប្រមូលចំណូលថវិកាជាតិ ពង្រឹងយន្តការគ្រប់គ្រងធនធាន និងអាជីវកម្មរ៉ែដោយកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ផ្នែកសង្គមនិងបរិស្ថាន។ ក្រសួងបានបន្តដាក់ចេញនូវយុទ្ធសាស្ត្រ ដែលមានចែងក្នុងគោលនយោបាយជាតិស្តីពីធនធានរ៉ែឆ្នាំ២០១៨-២០២៨ ដូចខាងក្រោម៖

- ពង្រឹងតួនាទីស្ថាប័នក្នុងការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានរ៉ែ ដោយផ្តោតសំខាន់លើការលុបបំបាត់អាជីវកម្មរ៉ែខុសច្បាប់ និងការប្រមូលចំណូលមិនមែនសារពើពន្ធជូនរដ្ឋ
- ជំរុញការធ្វើប្រតិបត្តិការធនធានរ៉ែប្រកបដោយចីរភាព និងការទទួលខុសត្រូវសង្គម បរិស្ថាន និងសេដ្ឋកិច្ច
- គ្រប់គ្រងនិងអភិវឌ្ឍសិប្បកម្មរ៉ែនិងអាជីវកម្មរ៉ែខ្នាតតូចតាមរយៈប្រតិភូកម្មអំណាចជូនថ្នាក់ក្រោមជាតិក្នុងការចេញអាជ្ញាបណ្ណ និងគ្រប់គ្រងអាជីវកម្មរ៉ែក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- គ្រប់គ្រងនិងដំណើរការការនាំចេញផលិតផលរ៉ែ។

### ការគ្រប់គ្រងធនធានជលផល និងអភិវឌ្ឍវារីវប្បកម្ម និង ការគ្រប់គ្រងនិងអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ

#### *ការគ្រប់គ្រងធនធានជលផល និងអភិវឌ្ឍវារីវប្បកម្ម*

VII. ឧបសម្ព័ន្ធទី៧៖ សំណើសុំអនុញ្ញាតឱ្យនិស្សិតចំនួន០២ រូបចុះស្រាវជ្រាវឯកសារ នៅក្រសួងរ៉ែ និងថាមពល

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
លេខ ៤៧៦.....ស.ភ.ន.វ.ស

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល**

កម្មវត្ថុ៖ សំណើសុំអនុញ្ញាតឱ្យនិស្សិតចំនួន០២រូប ចុះស្រាវជ្រាវឯកសារ។
យោង៖ សំណើរបស់សាមីនិស្សិតចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២។

តបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំសូមជម្រាបជូន ឯកឧត្តមរដ្ឋមន្ត្រី មេត្តាជ្រាបថា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចបាន និងកំពុងបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ។ អំឡុងពេលសិក្សាឆ្នាំបញ្ចប់និស្សិតយើងខ្ញុំចំនួន០២រូប ដូចមានបញ្ជីរាយនាមជូនភ្ជាប់មកជាមួយនេះ ត្រូវចុះស្រាវជ្រាវឯកសារ និងស្វែងយល់ពីការងារមួយចំនួនដែលទាក់ទងនឹងប្រធានបទស្តីពី «ការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល» នៅក្រសួងរ៉ែ និងថាមពល ចាប់ពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ដើម្បីសរសេរសារណា និងការពារបញ្ចប់ការសិក្សារបស់ខ្លួន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តមរដ្ឋមន្ត្រី មេត្តាពិនិត្យលទ្ធភាពអនុញ្ញាតឱ្យនិស្សិតយើងខ្ញុំបានចុះស្រាវជ្រាវឯកសារដោយក្តីអនុគ្រោះ។

សូម ឯកឧត្តមរដ្ឋមន្ត្រី មេត្តាទទួលនូវគារវកិច្ចដ៏ស្មោះពីខ្ញុំ

ថ្ងៃ សុក្រ ១៣រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២

**សាកលវិទ្យាធិការ**

**បណ្ឌិត លុយ ចណ្ណា**

Monivong Blvd. Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, Cambodia.
P.O. Box 842. Tel: (855) 23 214 703, Fax: (855) 23 214 953, E-mail: rector@rule.edu.kh, website: www.rule.edu.kh

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំអនុញ្ញាតចុះស្រាវជ្រាវឯកសារ

យើងខ្ញុំឈ្មោះ កោះ ច័ន្ទឫទ្ធិសក្តិ និង លាង លីឌឹរ ជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ឆ្នាំទី០៤ ជំនាន់ទី១៥ ឆ្នាំសិក្សា២០២១ - ២០២២ នៃសាកលវិទ្យាល័យកូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមគោរពជូន**

**ឯកឧត្តមសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

កម្មវត្ថុ៖ សំណើសុំអនុញ្ញាតចុះស្រាវជ្រាវឯកសារ។

តាមកម្មវត្ថុខាងលើ យើងខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាបថា បន្ទាប់ពីបានធ្វើការសិក្សាផ្នែកទ្រឹស្តី យើងខ្ញុំត្រូវសរសេរសារណា និងការពារបញ្ចប់ការសិក្សាដែលទាក់ទងនឹងប្រធានបទស្តីពី <<ការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល>> ដោយត្រូវចុះសិក្សាស្រាវជ្រាវឯកសារនៅក្រសួងរ៉ែ និងថាមពលចាប់ពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ ដល់ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២។

អាស្រ័យហេតុនេះសូម **ឯកឧត្តម** មេត្តាអនុញ្ញាតឱ្យយើងខ្ញុំបានចុះស្រាវជ្រាវឯកសារដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃអង្គារ ១០រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២

ហត្ថលេខា

កោះ ច័ន្ទឫទ្ធិសក្តិ　　លាង លីឌឹរ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**បញ្ជីរាយនាម**

**និស្សិតថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ**

**ឆ្នាំទី០៤ ជំនាន់ទី១៥ ក្រុមP4B1 ឆ្នាំសិក្សា២០២១ - ២០២២**

**ដែលត្រូវចុះសិក្សាស្រាវជ្រាវឯកសារនៅ ក្រសួងរ៉ែ និងថាមពល**

| ល.រ | គោត្តនាម-នាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | លេខទូរស័ព្ទ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | កោះ ច័ន្ទឫទ្ធិសក្តិ | ប្រុស | ០៣-កុម្ភៈ-២០០១ | ០៩៣ ៧៩ ៨២ ៦៧ | |
| ២ | លាង លីឌីរ | ប្រុស | ០២-ធ្នូ-២០០០ | ០៩៥ ៥០ ០១ ៦៨ | |

ថ្ងៃអង្គារ ១០រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២
**ប្រធានការិយាល័យស្រាវជ្រាវ**

**ញឹក_វុឌ្ឍី**

VIII. ឧបសម្ព័ន្ធទី៨៖ លិខិតបង្គាប់ការ លេខ០០២៩ រថ.បល.លបក ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ ស្ដីពីការអនុញ្ញាតឱ្យចុះស្រាវជ្រាវឯកសារ និងស្វែងយល់ពីការងារដែលពាក់ព័ន្ធនឹងប្រធានបទ "ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ:..០០២៩ រថ.បល.លបក

ថ្ងៃព្រហស្បតិ៍ ១២កើត ខែ ពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២

## លិខិតបង្គាប់ការ

យោងលិខិតលេខ៥២៦ ស.ភ.ន.វ.ស ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២២ របស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

និស្សិតឆ្នាំទី៤ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ចំនួន០២រូប ត្រូវបានអនុញ្ញាតឱ្យចុះស្រាវជ្រាវឯកសារ និងស្វែងយល់ពីការងារដែលពាក់ព័ន្ធនឹងប្រធានបទ "ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល" នៅនាយកដ្ឋាននីតិកម្មនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ រយៈពេល០៥ថ្ងៃ ចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ដូចមានរាយនាមខាងក្រោម៖

១. លោក **កោះ ច័ន្ទឫទ្ធិសក្តិ**

២. លោក **លាង លីឌីរ**

សាមីខ្លួនត្រូវអនុវត្តការងារស្រាវជ្រាវតាមការណែនាំរបស់ប្រធាននាយកដ្ឋាន។

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល:**
- សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- អគ្គនាយកដ្ឋានកិច្ចការទូទៅ
- នាយកដ្ឋាននីតិកម្ម
- សាមីខ្លួន
- ឯកសារ-កាលប្បវត្តិ

លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh Info@mme.gov.kh

IX. ឧបសម្ព័ន្ធទី៩៖ រូបភាពចុះសិក្សាស្រាវជ្រាវឯកសារ និងស្វែងយល់ពីការងារដែលពាក់ព័ន្ធនឹងប្រធានបទ "ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែ និងថាមពល" នៅនាយកដ្ឋាននីតិកម្ម នៃអគ្គនាយកដ្ឋានកិច្ចការទូទៅ នៃក្រសួងរ៉ែ និងថាមពល



